ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2012, 14:18
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៥៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊ឺរ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា**

លោក ច័ន្ទ តារាវស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDRATANA)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោក សាឡុត បាន (TCW-586) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី:- លោក សាឡុត បាន** (TCW-586)


សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី៖....................................................ទំព័រ០១

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី៖ ..................................................................ទំព័រ៤៧

សួរដោយលោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា ផ្តើមពី៖ ........................................ទំព័រ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ តាមកាលវិភាគដែលបានគ្រោងទុក និងបានសម្រេចរួចហើយ គឺអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី សាឡុត បាន។

អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហភាគីទាំងអស់។ សំណួរដំបូងខ្ញុំចង់សួរនេះ ចង់បន្តពីម្សិលមិញដែលយើងបានទៅលើឯកសារមួយ ដែលមានលេខ D267/5/1.1.25 ហើយកាលពីល្ងាចម្សិលមិញនេះ គឺយើងបានឈប់សម្រាក បន្ទាប់ពីលោកប្រធានបានអនុញ្ញាតឲ្យសាក្សីពិនិត្យមើលឯកសារនេះនៅព្រឹកនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវនេះ ជាបឋមខ្ញុំចង់សួរសំណួរទៅកាន់សាក្សី ដើម្បីចង់ដឹងថា តើគាត់បានពិនិត្យមើលឯកសារនេះរួចហើយឬនៅ? ហើយគាត់មាននឹកឃើញទេថា អ្នកស៊ើបអង្កេត នៃសហចៅក្រមស៊ើបអង្កេត បានបង្ហាញឯកសារនេះជូនគាត់ ឬក៏គាត់ទេកាលពីក្នុងអំឡុងកិច្ចស៊ើបសួរនោះ?

[០៩:០៤:០១]

**លោក សាឡុត បាន៖**

**ឆ៖** តាមអ្នកស៊ើបអង្កេតមកសាកសួរ ឯកសារនេះអត់បានឃើញទេ ខ្ញុំទើបនឹងបានឃើញពេលនេះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន មុននឹងធ្វើការសម្រេចទៅលើឯកសារនេះ ខ្ញុំសូមផ្តល់នូវការបំភ្លឺបន្ថែមដោយអាន

នូវកំណត់ហេតុលេខ D369/36 ពីព្រោះលោកសាក្សីអម្បាញ់មិញនេះ គាត់និយាយថា មិនធ្លាប់ឃើញឯកសារនេះទេ។ ក៏ប៉ុន្តែបើយើងពិនិត្យទៅលើសំណួរ៦១ និង៦២ នៃឯកសារលេខ D369/36 យើងឃើញថាច្បាស់ណាស់ គឺមានការសួរពីឯកសារនេះ។

ខ្ញុំសូមអនុញ្ញាតពីលោកប្រធានផ្តល់សាក្សី ហើយសូមអនុញ្ញាតបង្ហាញឯកសារដែលមានសំណួរទាំងពីរនេះនៅលើអេក្រង់។ ខ្ញុំគិតថាមន្ត្រីតុលាការកំពុងតែបង្ហាញទំព័រពាក់ព័ន្ធជូនសាក្សីរួចហើយ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ប្រហែលជាសហព្រះរាជអាជ្ញាគួរបង្ហាញលេខទំព័រថា តើទំព័រប៉ុន្មាន?

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ គឺជាសំណួរនិងចម្លើយ៦១, ៦២ នៅក្នុងឯកសារកំណត់ហេតុស្តាប់ចម្លើយលេខD369/36។ ខ្ញុំគិតថា បើយើងយោងទៅលើលេខសំណួរចម្លើយនេះ វាស្រួលជាងការបង្ហាញលេខ ERN ។ សំណួរទី៦១ ដូចតទៅនេះ ពាក់ព័ន្ធនឹងការប្រជុំធ្វើជីវទស្សន៍ យើងសូមយោងដល់ឯកសារដែលមានលេខ D267/5/1.1.25 ERN 00427859 ក្នុងនោះមាននិយាយអំពីជីវទស្សន៍សមមិត្ត ស៊ឹម។ “តើឈ្មោះ ស៊ឹម នេះជាអ្នកណា? ចម្លើយ៦១៖ ស៊ឹម ជាអ្នកធ្វើបាយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ។ សព្វថ្ងៃនេះគាត់រស់នៅខេត្តសៀមរាប”។ ហើយបន្ទាប់មកទៀត សំណួរ៦២ “តើលោកចាំទេអក្សរសរសេរនៅលើឯកសារនេះជារបស់អ្នក--អក្សររបស់អ្នកណា?” ចម្លើយ៦២ “ខ្ញុំមិនដឹងទេ”។

[០៩:០៧:០៤]

បន្ទាប់មកមានសំណួរចម្លើយផ្សេងទៀត ដែលសំណួរចម្លើយទាំងអស់នោះសុទ្ធតែពាក់ព័ន្ធទៅនឹងឯកសារនេះទាំងអស់។ ដូច្នេះ ជាពិសេសគឺសំណួរ៦៣ ដែលនិយាយអំពីផ្នែកផ្សេងៗនៅក្នុងឯកសារនេះ ហើយក៏យើងឃើញឈ្មោះដូចគ្នានេះនៅក្នុងឯកសារ។ ដូច្នេះ ចំពោះចម្លើយ៦២ នេះ គាត់ឆ្លើយថា មិនដឹងទេ ដូច្នេះច្បាស់ណាស់គឺថា មានការសួរសាក្សីនេះហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ហើយនៅពេលដែលគេសួរថា តើមានស្គាល់អក្សរនេះទេ ច្បាស់ណាស់គេត្រូវតែបង្ហាញឯកសារហើយ ដើម្បីឲ្យគាត់ឃើញនោះ។ ខ្ញុំសូមបញ្ជាក់ថា សរសេរនេះគឺសរសេរដៃជាអក្សរ។

**លោក សាឡុត បាន៖**

**ឆ៖** លោកសួរថា តើឃើញឯកសារនេះទេ? ខ្ញុំឆ្លើយថា អត់បានឃើញទេ ទើបតែឃើញនៅ

ពេលនេះ។ នេះសំណួរលោក។ ពេលដែលខ្ញុំ-- គេយកឯកសារមកឲ្យខ្ញុំមើល ឯកសារហ្នឹងវាមិនមាន ឯកសារនេះ ឯកសារជាសន្លឹក មួយសន្លឹក ពីរសន្លឹក។ មួយសន្លឹក ពីរសន្លឹកនោះក៏ខ្ញុំមិនបានថា ផ្ដិតមេដៃ ថា ខ្ញុំបានមើលឯកសារនេះហើយ ក៏ខ្ញុំអត់បានដែរ អត់បានផ្ដិតមេដៃដែរ។ ដល់យកឯកសារថ្មីមកទៀត ខ្ញុំអត់បានឃើញ ឲ្យខ្ញុំថាឃើញយ៉ាងម៉េច?

[០៩:០៩:០៥]

**ស៖** តើលោកអាចបញ្ជាក់បានទេថា ឯកសារពីរទំព័រដែលគេបង្ហាញជូនលោកនោះ គឺដូចនឹង ឯកសារដែលនៅនឹងមុខលោកដែរឬទេ?

**ឆ៖** ពេលនោះ បាទខ្ញុំចាំនៅពេលនោះ ឯកសារដែលឲ្យខ្ញុំឃើញមិនទម្រង់ដូចនេះទេ ហើយ ខ្ញុំក៏អត់បានផ្ដិតមេដៃអីថា ខ្ញុំបានឃើញឯកសារនោះដែរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

មុននឹងបន្តទៅការសួរសំណួរ ខ្ញុំចង់ស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីសួរសំណួរបន្ថែម មិន ត្រឹមតែសំណួរពីរបីដែលខ្ញុំបានបញ្ជាក់អំពីម្សិលមិញនោះទេ ខ្ញុំចង់បង្ហាញពីបញ្ជីសំណួរតែម្ដង ដែល សំណួរទាំងអស់នោះ គឺពាក់ព័ន្ធទៅនឹងឯកសារនេះទាំងស្រុង។ វាមិនមែនត្រឹមតែឯកសារ D369/36 ទេ។ មានឯកសារសំណួរទីមួយ ទីពីរ និងឯកសារ 233/9 ទៀតដែលបង្ហាញពីឯកសារនេះ។ ហើយ សំណួរដែលគេបានសួរគាត់កាលពីពេលនោះនោះ គឺមានន័យថាគេបង្ហាញឯកសារនោះជូនគាត់ហើយ។ ពីព្រោះថានៅក្នុងចម្លើយទីមួយ និងទីពីររបស់គាត់នៃឯកសារD233/9 នោះបានបង្ហាញឲ្យឃើញយ៉ាង ច្បាស់ថា ឯកសារគេបង្ហាញនោះ គឺជាឯកសារ ប-១ ហើយ ពីព្រោះគាត់ស្គាល់ឈ្មោះរបស់គាត់ ហើយ និងស្គាល់បទអន្តរាគមន៍របស់ វ៉ាន់ នៅក្នុងកិច្ចប្រជុំជីវទស្សន៍ដែលគាត់បានចូលរួម។

[០៩:១០:៥៥]

ហើយកិច្ចប្រជុំជីវទស្សន៍នេះ ក៏ជាផ្នែកមួយនៃឯកសារដែលដាក់ជូននៅថ្ងៃនេះ ដែលមាន២០ ទំព័រជាង ដែលប្រព្រឹត្តទៅនៅមន្ទីរប-១។ ខ្ញុំមិនដឹងថា តើខ្ញុំទទួលបានការអនុញ្ញាតក្នុងការបង្ហាញបែប នេះ ឬក៏យ៉ាងម៉េច។ ដូច្នេះ សូមអង្គជំនុំជម្រះសូមមេត្តាធ្វើសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងឯកសារមួយ នេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ប្រហែលមុននឹងបង្ហាញឯកសារ អាចនឹងចោទសួរសំណួរមួយចំនួនដូចជា។ នៅពេលដែលយើងមើលឯកសារ D369/6 គឺថាមានការបញ្ជាក់ថា មានការបង្ហាញឯកសារទៅគាត់ ហើយប៉ុន្តែគាត់បានឆ្លើយថា គាត់មិនបានឃើញឯកសារនេះទេ។ ប្រហែលជាក៏អាចនឹងតាំងសំណួរទៅលើទំព័រណាជាក់លាក់មួយ ថាតើបានឃើញទំព័រជាក់លាក់នេះទេ បាន លោកបានគេមានបានសួរសំណួរទាំងនេះទៅលោកទេ? ប្រហែលជាបញ្ហានេះ វាពាក់ព័ន្ធទៅនឹងភាពគួរឲ្យទុកចិត្តបាន យើងអាចតាំងសំណួរទៅលើទំព័រជាក់លាក់ ដើម្បីយកមកធ្វើជាសំអាងនេះ។ ប៉ុន្តែការច្របូកច្របល់នេះ គឺឯកសារប្រហែលជាមិនបានឲ្យបង្ហាញគាត់ទេ។ ហេតុដែលខ្ញុំបាទនិយាយដូច្នេះ គឺយ៉ាងដូច្នេះ ប្រសិនថា បើយើងមើលកិច្ចសម្ភាសចំនួនប្រាំ។ ចុះបើសិនណា ជាខ្ញុំគ្រាន់ប្រាប់ថា គ្រាន់តែប្រាប់ថាខ្ញុំបានបង្ហាញឯកសារនេះទៅសាក្សី ឯកសារនោះទៅសាក្សីតែគ្រាន់តែមិនបានបង្ហាញជាក់លាក់នោះ។ ហើយសាក្សីគាត់បានបញ្ជាក់ថា គាត់អត់បានស្គាល់ឯកសារនេះទេ។ ដោយមិនត្រឹមតែអនុញ្ញាតសាក្សី គាត់ពិនិត្យមើលឯកសារទាំងមូលនេះទេ ត្រូវតែលើកឡើងនូវទំព័រជាក់លាក់ណាមួយ។ ដូច្នេះសំណួរបច្ចេកទេស គួរសួរថាតើឯកសារនេះ គេបានផ្តល់ជូនលោកនៅទីណា? ហើយមានទំព័រណាមួយជាក់លាក់ដែរគេសាកសួរទេ?

[០៩:១៣:៣៥]

ខ្ញុំមិនជំទាស់ទៅនឹងសំណួរដែលចោទសួរទៅលើទំព័រជាក់លាក់ណាមួយនោះទេ។ ឯកសារ32-ឯកសារ D233/9 គឺនិយាយអំពី ចង្អុលបង្ហាញអំពីឯកសារជាក់លាក់មួយចំនួន ហើយខ្ញុំមិនដឹងថាឯកសារណានោះទេ ប្រហែលជាយើងធ្វើការសួរមួយដំណាក់ម្តងៗ ដើម្បីរកឲ្យឃើញថា តើវាមានអ្វីកើតឡើង? នេះប្រហែលជាមកពីបង្ហាញបច្ចេកទេសនៃការតាំងសំណួរ។ ខ្ញុំយល់ឃើញថា គួរតែបង្ហាញទំព័រជាក់លាក់នៃឯកសារនេះទៅដល់សាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី!

[០៩:១៤:២៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំ

ចង់ធ្វើការកត់សម្គាល់ពីរចំពោះបញ្ហាគួរឲ្យព្រួយបារម្ភនេះ ពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារ។ ការកត់សម្គាល់ទីមួយ គឺចង់បញ្ជាក់អំពីឯកសារនេះ។ ដូចលោកសហព្រះរាជអាជ្ញាបានបញ្ជាក់ហើយ នៅក្នុងឯកសារលេខ D369/36 គឺមានសំណួរ៦១ ដែលយោងទៅលើឯកសារនេះ។ ហើយបន្ទាប់មកទៀត សំណួរ៦២ គឺពាក់ព័ន្ធទៅនឹងអក្សរនៅក្នុងឯកសារ។ ដូច្នេះខ្ញុំយល់ថា ដូចជា វាជាឯកសារសរសេរដៃនៅក្នុងឯកសារនេះ។

ដូច្នេះយើងមានរបៀបពីរដែលថាអាចឲ្យសាក្សីបញ្ជាក់ថា គាត់ធ្លាប់ឃើញឯកសារ។ ប្រសិនបើគាត់មិនរកនឹកឃើញទេ យើងមានភស្តុតាងបង្ហាញ។ ខ្ញុំគិតថាសំណួរបន្តបន្ទាប់គ្នានេះគឺជាភស្តុតាងបញ្ជាក់ថាគាត់បានឃើញឯកសារនេះរួចមកហើយ។ នេះជាការកត់សម្គាល់ទីមួយ។

ការកត់សម្គាល់ទីពីរ អង្គជំនុំជម្រះបានសម្រេចរួចហើយទៅលើការដាក់ឯកសារ ដែលជាការសម្រេចគួរឲ្យព្រួយបារម្ភ ពីព្រោះថា ការពិភាក្សានៅក្នុងអង្គជំនុំជម្រះនេះគឺដើម្បីបង្ហាញពីការពិតនៃឯកសារនៅក្នុងសំណុំរឿង ហើយនៅក្នុងការជជែកដេញដោលនោះ យើងលើកពីភស្តុតាងសក្ខីកម្ម ហើយនិងភស្តុតាងជាឯកសារ។ ដូច្នេះយើងមិនអាចបំបែកចេញនូវភស្តុតាងសក្ខីកម្ម និងភស្តុតាងជាឯកសារនោះទេ។ ដូច្នេះ វាជាការចាំបាច់នៅក្នុងគ្រប់ករណីទាំងអស់ក្នុងការជជែកដេញដោលទៅលើឯកសារ ហើយដោយសារសាក្សីក្នុងពេលដំណាលគ្នានោះ។

[០៩:១៦:១៧]

ហើយខ្ញុំសួរអំពីឱកាសក្នុងការមិនអាចជជែកពិភាក្សាទៅលើឯកសារដោយមិនអាចមានវត្តមាននៅចំពោះមុខសាក្សីទេ។ ពីព្រោះគាត់ថា គាត់មិនបានឃើញឯកសារ។ ដូច្នេះយើងអាចបង្ហាញឯកសារជូនទៅកាន់សាក្សី គឺមិនមែនមានន័យថាឲ្យគាត់ធ្វើការស្មានៗទេ។ យើងបង្ហាញឯកសារជាភស្តុតាងជាក់ស្តែងឲ្យគាត់ឃើញ ហើយយើងសួរគាត់ថា តើគាត់ដឹងអ្វីខ្លះ? ហើយយើងដាក់ភស្តុតាងទាំងពីរនេះនៅចំពោះមុខគាត់។

ក៏ប៉ុន្តែយើងសម្រេចថា ឯកសារមិនអាចជជែកដេញដោល ហើយបង្ហាញជូនសាក្សីដោយសារតែសាក្សីនិយាយថា គាត់មិនធ្លាប់ឃើញនេះ គឺជាការកាត់ផ្តាច់ គឺជាការដកហូតនូវមធ្យោបាយភស្តុតាង ហើយ ខ្ញុំគិតថាទង្វើបែបនេះជាការគួរឲ្យសោកស្តាយណាស់។

**ប្រធានអង្គជំនុំះ**

អញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។

[០៩:១៧:៣៧]

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញា កុំអាលទាន់មានយោបល់អី ចាំស្តាប់មេធាវីសិន!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ការជជែកមកដល់ពេលនេះខ្ញុំយល់ឃើញថា-- (សូមទោស ភ្លេចបិទ)។

សាក្សីបានឆ្លើយដាច់អហង្ការថា លោកអត់បានស្គាល់នូវឯកសារនេះទេ។ ទាំងព្រះរាជអាជ្ញាទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបង្ខំ ខ្ញុំនិយាយពាក្យ "មិនត្រូវ" មិនត្រូវបង្ខំសាក្សីឲ្យឆ្លើយថាខ្លួនបានឃើញទេ វាផ្ទុយគ្នា។ ម្ល៉ោះហើយខ្ញុំសូមឲ្យតុលាការ-- បើកាលណាសាក្សីឆ្លើយថា អត់ទទួលស្គាល់ទេ តុលាការបានសម្រេចរួចហើយថានឹងដកឯកសារហ្នឹងចេញ។ ម្ល៉ោះហើយសូមឲ្យតុលាការសម្រេចទៅតាមការសម្រេចរបស់ខ្លួនតាំងពីពេលមុនមក។ សូមអរគុណ។

[០៩:១៩:០១]

**ប្រធានអង្គជំនុំ៖**

បញ្ហាដែលកើតឡើងនៅចំពោះមុខនេះ វាមានចរិតលក្ខណៈខុសពីអ្វីដែលអង្គជំនុំជម្រះបានអនុវត្តកន្លងមកនៅក្នុងការបង្ហាញឯកសារចំពោះសាក្សី នូវឯកសារថ្មី ដែលត្រូវបានបញ្ជាក់ថា តើសាក្សីធ្លាប់បានឃើញ បានស្គាល់ បានជួបប្រទះនូវឯកសារនោះពីមុនពេលដែលសាក្សីត្រូវបានកោះអញ្ជើញមកផ្តល់សក្ខីកម្មផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះនេះដែរឬទេ? ប្រសិនបើសាក្សីគាត់ឆ្លើយច្បាស់លាស់ថា មិនដែលធ្លាប់បានទទួល បានស្គាល់ បានជួបឯកសារនោះទេ គឺអង្គជំនុំជម្រះសម្រេចដកឯកសារនោះភ្លាម ទាំងឯកសារជាក្រដាសនៅចំពោះមុខសាក្សី ក៏ដូចជាការដកចេញពីប្រព័ន្ធព័ត៌មានវិទ្យា គឺចេញពីអេក្រង់កុំព្យូទ័រដែរ។ ប៉ុន្តែឯកសារនេះ វាមានលក្ខណៈចរិតដោយឡែកផ្សេងពីឯកសារទាំងនោះដោយសារខាងសហព្រះរាជអាជ្ញាដែលមានបំណងដេញដោលឯកសារនេះ គាត់បានផ្អែកទៅលើឯកសារ D369/36 ដែលបានជាកំណត់ហេតុស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហ

ចៅក្រមស៊ើបអង្កេត ដែលមានការពាក់ព័ន្ធទៅនឹងការចង្អុលបង្ហាញឯកសារនេះ ចំពោះមុខសាក្សីដែលមានព័ត៌មានសមល្មមជឿបានថា កិច្ចដំណើរការនីតិវិធីនៃការស្តាប់សាក្សីនាពេលនោះ គឺទំនងជាមានហេតុផលគ្រប់គ្រាន់បង្ហាញឯកសារនេះនៅចំពោះមុខសាក្សី នៅក្នុងការដេញដោលទៅលើខ្លឹមសារនៃសំណួរចម្លើយដែលមាន ដែលចង្អុលបង្ហាញដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ ហើយនៅក្នុងកំណត់ហេតុនេះមានបួនចំណុចដែលបានយោងចង្អុលទៅឯកសារ D267/5/1.1.25 ដែលកំពុងតែមានបញ្ហានេះ។

[០៩:២១:៣៥]

បញ្ហាដែលកើតឡើង ត្រង់ថា ឯកសារមួយដុំដែលជាកំណត់ដៃដែលអះអាងនៅក្នុងសំណុំរឿងថា ជាកំណត់ហេតុដែលយកបានពីក្រសួងការបរទេសសម័យនោះ យកមកនេះ គឺវាមិនបានបង្ហាញជូនទៅសាក្សីនៅក្នុងដំណាក់កាលស៊ើបអង្កេតហ្នឹងទាំងស្រុងទេ មានតែទំព័រមួយចំនួនប៉ុណ្ណោះ។ អ៊ីចឹងហើយវិធីដែលថាការបង្ហាញនេះ គឺត្រូវបង្ហាញនៅក្នុងកម្រិតពីរ។ ទីមួយ គឺបង្ហាញទាំងមូល។ បើអត់ទេ គឺទីពីរ គឺបង្ហាញនូវទំព័រជាក់លាក់ដែលមាននៅក្នុងកំណត់ហេតុនេះ។ ដើម្បីឲ្យជាក់ច្បាស់ថា តើបញ្ហាហ្នឹងវាមានមែន ឬក៏អត់? ហើយបើនៅតែអត់ទេ អាន់ុងយើងនឹងដំណើរការទៅមុខទៀត ពីព្រោះគោលបំណងខ្លឹមសារនេះ មិនមែនដេញដោលតែត្រឹមប៉ុណ្ណឹងទេ គឺខ្លឹម-- ដេញដោលទៅលើខ្លឹមសារនៃបញ្ហាដែលមានកត់ត្រានៅក្នុងលើទំព័រដែលយកមកដេញដោលនោះឯង។ សំណួរនោះ។ សំណួរមិនចប់ត្រឹមថា ឃើញទំព័រហ្នឹងដែរឬអត់? ឃើញ! ចប់ត្រឹមហ្នឹងទេ។ សួរសំណួរផ្សេងទៀត។ មិនមែនអ៊ីចឹងទេ! វាសំខាន់ផ្តុកទៅដោយបញ្ហាដែលមាននៅក្នុងកំណត់ត្រា នៅក្នុងទំព័រដែលមានការពាក់ព័ន្ធនេះ។ អ៊ីចឹងដំណោះស្រាយ គឺត្រូវតែច្បាស់លាស់បញ្ហាហ្នឹង ដើម្បីឲ្យទៅមុខទៀត។

[០៩:២៣:១២]

លោកតំណាងសហព្រះរាជអាជ្ញាអាចសួរបញ្ជាក់បានសាជាថ្មីម្តងទៀត ឬក៏បញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់លើដំណោះស្រាយ គឺឲ្យបានច្បាស់លាស់លើសាក្សីចំពោះការដែលគាត់បានដឹងថា តើឯកសាររួមទាំងដុំហ្នឹង គាត់-- គេបានឲ្យគាត់ដែរឬទេ? បើគាត់ឆ្លើយអត់ទេ ត្រូវសួរពាក់ព័ន្ធជាមួយនឹងទំព័រនីមួយៗដែលយោងបួនសំណួរនៅក្នុងឯកសារនេះ! ដើម្បីឲ្យគាត់បង្ហាញថា តើនៅក្នុងសំណួរដែលគាត់គេសួរហ្នឹង គាត់មានបាន-- គេមានបានបង្ហាញទំព័រនីមួយៗហ្នឹងសម្រាប់ឲ្យសាក្សីបានឃើញទេន៎! ដែលដើម្បីឲ្យសាក្សីឆ្លើយតបនឹងសំណួរដែលបានសួរដោយអ្នកស៊ើបអង្កេតនេះ។ ដើម្បីអង្គជំនុំជម្រះ

សម្រេច។ សម្រេចថាម៉េច? ប្រសិនបើនៅតែដោះស្រាយមិនបាន វាត្រូវទៅមុខទៀត។

[០៩:២៤:១៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមធ្វើម៉េចឲ្យច្បាស់ គឺនៅឯកសារលេខ D369/36។ ជាដំបូងគឺ មានសំណួរទី៥២ ដែលបង្ហាញអំពីឯកសារនេះ ហើយនិងបង្ហាញទំព័រ ERN ច្បាស់ណាស់។ គឺ ERN ជាភាសាខ្មែរ 00427826។ សំណួរទី៥២ នេះ គឺពាក់ព័ន្ធទៅនឹងគណៈដឹកនាំរបស់ក្រសួងការបរទេស។ ហើយគាត់បានឆ្លើយថា-- អង់គ្លេសជា-- មានលេខ ERN 00003250 រហូតទៅដល់ 00003252 មិនមាន ការបកប្រែជាភាសាអង់គ្លេសនៃសម្រង់នៃឯកសារ D267/5/1.1.25 នោះទេ។ ដូច្នេះខ្ញុំនឹងបន្តទៅទៀត។

ចំពោះសំណួរទី៥៣ នៅក្នុងឯកសារទំព័រដដែល ដូច្នេះគឺជាឯកសារដដែលដែលខ្ញុំបានលើកនេះហើយ។ ហើយនៅក្នុងសំណួរទី៥៤ ក៏ជាសំណួរបន្តដែរ បន្តដើម្បីចង់ដឹងពីខ្លឹមសារនៃឯកសារនេះ។ ហើយ សំណួរទី៥៥ មិនមានការបង្ហាញអំពីលេខ ERN ឲ្យបានច្បាស់ទេ។ ក៏ប៉ុន្តែគឺមានការយោងទៅលើប្រភេទនៃមនុស្សដែលហាមមិនអាចកែបាន ហើយនៅក្នុង-- យើងអាចឃើញពាក្យនេះដដែលនេះនៅទំព័រ 00427825 ជាភាសាខ្មែរ, ជាភាសាបារាំង 00657829 ហើយលេខអង់គ្លេស 00003249។ ចំពោះសំណួរទី៥៦ នៅក្នុងសំណួរនេះ គឺច្បាស់ណាស់គេនិយាយអំពីសមាជនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ៧៦។ ហើយដូច្នេះ មានសំណួរដែលពាក់ព័ន្ធទៅនឹងឯកសារ D267/5/1.1.25 ដែលពាក់ព័ន្ធទៅនឹងសមាជ ដែលមានចំណងជើងច្បាស់លាស់ថាជាសមាជ ឬក៏ជាសន្និបាត។

[០៩:២៧:៥៨]

ចំណងជើងពិតប្រាកដនោះ គឺថាសន្និបាតរបស់មន្ទីរ ប-១ នៅថ្ងៃទី១០ ខែកក្កដា ៧៦។ ហើយនៅមានលេខឯកសារ នៅទំព័រ 00427828 រហូតទៅដល់ 00427857 គឺថាមានប្រហែលជា៣០ទំព័រឯណោះដែលនិយាយអំពីសមាជនេះ ហើយជាភាសាអង់គ្លេស 000032--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យសហព្រះរាជអាជ្ញាប្រាប់ ERN ម្តងទៀត អ្នកបកប្រែតាមចាប់អត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាលឿនណាស់ អ្នកបកប្រែបកប្រែមិនទាន់ទេ។ លោកអាច

និយាយឡើងវិញ អ៊ីចឹងការឲ្យពេលវេលាលោកហ្នឹង គឺលោកមិនបានប្រើពេលវេលាហ្នឹងមានប្រសិទ្ធភាពទេ។ ការសុំបន្ថែមពេលវេលា គួរតែពេលវេលាដែលសុំបន្ថែមហ្នឹងប្រើប្រាស់យ៉ាងណាឲ្យមានប្រសិទ្ធភាពបំផុត។ ឥឡូវនិយាយឡើងវិញ! លេខERN ចុងក្រោយអំមិញ គឺអត់-- អ្នកបកប្រែបកប្រែអត់បានទេ។

[០៩:២៨:១៨]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្ទាឯលៈ**

សូមអភ័យទោសលោកប្រធាន។ ទំព័រដែលពាក់ព័ន្ធទៅនឹងសមាជនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ៧៦ នោះ ជាភាសាខ្មែរ គឺ 00427828 រហូតទៅដល់ 00427857 ហើយជាភាសាអង់គ្លេស 00003251 រហូតទៅដល់ 00003272 ជាភាសាបារាំង 00657831។ ឯកសារជាភាសាបារាំងនោះដូចទំព័រមិនតគ្នាទេ។ នៅក្នុងចម្លើយទី៥៦នេះ គឺពាក់ព័ន្ធទៅនឹងជនក្បត់ ហើយនិងការត្រួតពិនិត្យជីវប្រវត្តិ។ ដូច្នេះវាជាទំព័រជាក់លាក់ច្បាស់លាស់ណាស់។ ជាភាសាខ្មែរនោះ គឺ00427844 គឺនៅក្នុង ៣០ទំព័រជាងដែលខ្ញុំនិយាយអម្បាញ់មិញនេះ ក្នុងភាសាអង់គ្លេស 00003262 ហើយជាភាសាបារាំង 00657991។

[០៩:២៩:៤៦]

ខ្ញុំបានលើកឡើងអំពីសំណួរទី៦១ និងសំណួរទី៦២ ដែលបានលើកឡើងយ៉ាងច្បាស់នៅទំព័រជាភាសាខ្មែរ 00427859 ដែលពាក់ព័ន្ធនឹងភាសាអង់គ្លេសគឺ 00003272 រហូតទៅដល់ 73 ជាភាសាបារាំង 00657984។ គឺសំណួរទី៦២ នេះពាក់ព័ន្ធទៅនឹងអក្សរសរសេរដៃដែលបង្ហាញជូនទៅសាក្សី។

ចំពោះសំណួរទៅ៦៣ វិញ នៅក្នុងឯកសារនេះ គឺបាននិយាយថា "នៅមន្ទីរប-១ គេបែងចែកការងារជាប្រាំពីរផ្នែក ការអប់រំ ដាំដុះ ការិយាល័យនយោបាយ ពិធីការ លេខា និងអាកាសចរណ៍ស៊ីវិល។ យើងអាចឃើញផ្នែកទាំងប្រាំពីររបស់មន្ទីរប-១នេះ នៅក្នុងឯកសារដែលខ្ញុំបានដាក់ជូនសាក្សីនេះ គឺជាភាសាខ្មែរ 00427849 ជាភាសាអង់គ្លេស 00003247 ជាភាសាបារាំង 00657989។

ចំពោះសំណួរទី៦៥ នៅក្នុងសំណួរនេះ គឺយោងទៅលើឯកសារជាភាសាខ្មែរ 00427949 មានកំហុសពាក់ព័ន្ធទៅនឹងចំណុចមួយនេះ ពីព្រោះថាតាមពិតមិនមែន7849 គឺលេខ 7949។ ជាភាសាអង់គ្លេសគឺនៅទំព័រ 00003336 អត់មានការបកប្រែជាភាសាបារាំងទេ។

[០៩:៣២:០៤]

ចំពោះសំណួរទី៦៧ គឺនិយាយអំពីចំនួនមនុស្សនៅច្រាំងចំរេះ ហើយយើងឃើញស្ថិតិនៅក្នុងសំណួរនេះគឺនៅឯកសារខ្មែរ 00427928, ជាភាសាបារាំង 00657891, ជាភាសាអង់គ្លេស

00003321។ ចំពោះសំណួរទី៦៨ គឺនៅទំព័រដូចគ្នា ហើយបន្ទាប់មកបន្តទៅទំព័រផ្សេងទៀត។ សំណួរទី៧០ គឺនិយាយអំពីខ្មាំងរឹងក្បាល ដែលបញ្ជូនទៅមន្ទីរសន្តិសុខ ហើយខ្លឹមសារនោះគឺដូចគ្នាទៅនឹងទំព័រជាភាសាខ្មែរ 00427941 ផ្នែកទីមួយ ដែលពាក់ព័ន្ធទៅនឹងប្រភេទនៃជម្លោះ ឬក៏ទំនាស់។ ជាភាសាអង់គ្លេស 00003331។

ខ្ញុំសូមនិយាយអំពីឯកសារមួយទៀត ដែលលេខ D233/9 គឺមានសំណួរទី១ និងសំណួរទី២ ដែលបានចោទសួរទៅកាន់សាក្សី។ យើងអាចយល់បានឃើញច្បាស់ណាស់ គឺក្នុងនេះនិយាយអំពីកិច្ចប្រជុំជីវទស្សន៍។ ដូច្នេះខ្ញុំសូមអាននូវសម្រង់មួយចំនួននៅក្នុងឯកសារនេះ។ មិនមានការបង្ហាញឯកសារយោងនៅក្នុងសំណួរទាំងពីរនេះទេ។ ក៏ប៉ុន្តែនៅពេលដែលយើងអានទៅ យើងអាចឃើញច្បាស់ថា គឺឯកសារមួយផ្នែកដែលបានបង្ហាញជូននោះ គឺពិតជាឯកសារដែលលេខ D267/5/1.1.25 ហើយដែលនិយាយអំពីកិច្ចប្រជុំជីវទស្សន៍ កិច្ចប្រជុំទិតៀន នៅឆ្នាំ៧៦នោះ។ ហើយនៅក្នុងនោះមានទំព័រ 00427907 ជាភាសាខ្មែរ រហូតទៅដល់ 00427927 គឺប្រហែលជាមាន២០ទំព័រ។ ជាភាសាអង់គ្លេស 00003304 រហូតទៅដល់ 3320។ ជាភាសាបារាំង 00657875 ក៏ប៉ុន្តែនៅកន្លែងនេះទៀតគឺថាមានទំព័ររញ៉េររញ៉ៃណាស់ ច្រឡូកច្រឡំគ្នា ខ្ញុំមិនអាចផ្តល់លេខ ERN ឲ្យបានច្បាស់ទេ ចំពោះភាសាបារាំង។ ឃ្លាដែលសំខាន់ជាងគេនោះគឺ ចម្លើយទី១ សាក្សីបាននិយាយថា ខ្ញុំគិតថា ឯកសារនេះគឺពិតជាយោងទៅដល់កិច្ចប្រជុំមួយ ដែលប្រព្រឹត្តនៅក្រសួងការបរទេស គឺមានព័ត៌មានលម្អិតដែលបញ្ជាក់នោះ គឺមានឈ្មោះសមមិត្ត ហុង ក៏ប៉ុន្តែគឺក្នុងឯកសារបកប្រែនេះ បានន័យបញ្ជាក់ថា គឺផ្តល់ការណែនាំ ក៏ប៉ុន្តែតាមពិតបើសិនជាយើងមើលភាសាអង់គ្លេសវិញនោះ គឺថាសមមិត្ត វ៉ាន់ ទេ ជាអ្នកផ្តល់សេចក្តីណែនាំដល់សមមិត្ត ហុង ហើយបន្ទាប់មកទៀត គាត់និយាយថា គឺឯកសារនេះពិតជាមានមែន។

[០៩:៣៥:៥៨]

ឯកសារនេះបង្ហាញពីកិច្ចប្រជុំ ដែលប្រព្រឹត្តទៅនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៨ ពីព្រោះថា នៅក្នុងសម័យនោះគឺថា គ្រប់កិច្ចប្រជុំទាំងអស់ គឺត្រូវមានធ្វើជាកំណត់ហេតុ។ នៅពេលដែលយើងពិនិត្យមើលឯកសារនេះ ហើយនិងអ្វីដែលខ្ញុំបានលើកឡើងនៅក្នុងឯកសារដែលបានដាក់ជូនសាក្សី ដែលមាន២០ទំព័រ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំជីវទស្សន៍នោះ យើងអាចយល់បានយ៉ាងច្បាស់ថា ឈ្មោះរបស់សមមិត្ត វ៉ាន់ និងសមមិត្ត ហុង គឺមានមែន ហើយសមមិត្ត ហុង ហើយនិងសមមិត្តផ្សេងទៀត ដូចជា សមមិត្ត ជាម ជាដើម គឺបានធ្វើស្វ័យទិតៀន ហើយបន្ទាប់មកសមមិត្ត វ៉ាន់ គឺគាត់ធ្វើជាសេចក្តីសន្និដ្ឋាន ឬក៏ផ្តល់

នូវសេចក្តីណែនាំ។

[០៩:៣៦:៤៧]

ខ្ញុំគិតថា ចម្លើយដែលសាក្សីបានផ្តល់នៅក្នុងចម្លើយទី១ នោះគឺច្បាស់ណាស់ នៅពេលដែលគាត់និយាយថា ខ្ញុំគិតថា ឯកសារនេះពិតជាសំដៅទៅដល់កិច្ចប្រជុំ ដែលកើតឡើងនៅក្រសួងការបរទេស។ ដូច្នេះ ខ្ញុំមិនគិតថា ឯកសារនេះមិនបានបង្ហាញជូនសាក្សីទេ ពីព្រោះថា គាត់ខ្លួនគាត់ហ្នឹងក៏គាត់ឃើញថាឈ្មោះគាត់មាននៅក្នុងឯកសារនេះដែរ។ នេះជាអ្វីដែលខ្ញុំអាចពន្យល់បាន ពាក់ព័ន្ធនឹងឯកសារនេះ។

ហើយចំណុចចុងក្រោយនោះ នៅសំណួរទី២ នៃឯកសារ D233/9 គឺមានសួរថា "តើលោកអាចបញ្ជាក់បានទេថា អក្សរនៅក្នុងកំណត់ហេតុសរសេរដៃនេះ ជាអក្សររបស់អ្នកណា?" ហើយគាត់ក៏បានឆ្លើយថា "តាមខ្ញុំយល់អ្នកសរសេរកំណត់ហេតុកិច្ចប្រជុំនេះ អាចគាត់សូត្រឈ្មោះបួននាក់ គឺថាអាចមាន សួរ សែ, សួង ស៊ីគឿន, អ៊ិន សុភាព, ឬមួយទៀតក៏បង គាត ឈន់"។ ដូច្នេះ ខ្ញុំគិតថា គាត់មិនអាច១ថា ១ផ្តល់ឈ្មោះហើយដោយមិនអាចអានអក្សរនៅក្នុងឯកសារទេ។ ដូច្នេះនេះជាអ្វីដែលខ្ញុំអាចនិយាយបាន ពាក់ព័ន្ធនឹងផ្នែកមួយចំនួន ឬទំព័រមួយចំនួន ដែលអាចបង្ហាញជូនដល់សាក្សីនៅពេលស៊ើបសួរនោះ។ ខ្ញុំសូមអរគុណលោកប្រធាន។

[០៩:៣៨:២០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយលោកមិនសួរជាក់លាក់តែម្តងទៅ ថាតើសាក្សីយ៉ាងម៉េចដែរ?

សួរបញ្ជាក់ទៅថាឯកសារដែលលោកបានបង្ហាញរៀបរាប់អម្បាញ់មិញនេះ នៅក្នុងអំឡុងពេលនៃការដែលអ្នកស៊ើបអង្កេត នៃសហចៅក្រមស៊ើបអង្កេតបានយោង បានផ្អែកជាមូលដ្ឋានក្នុងការសួរដេញដោល តើគាត់ចងចាំដែរអត់?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** លោកសាក្សី ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំស្វ័យទិតៀន ឬក៏មានឈ្មោះសមមិត្ត ហុង, សមមិត្ត វ៉ាន់, សមមិត្ត ជាម ដែលមាននៅក្នុងឯកសារនោះ តើលោកមាននឹកឃើញទេថា អ្នកស៊ើបអង្កេតបានបង្ហាញនេះ ឯកសារដែលមាននៅចំពោះមុខលោកនេះ ជូនដល់លោកនៅពេលនោះ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំសូមជម្រាបម្ដងទៀត។ ដំបូង លោកសួរថា បានឃើញឯកសារហ្នឹងទេ? ខ្ញុំបានឆ្លើយថា ឯកសារមួយដុំនេះ ខ្ញុំមិនបានឃើញទេ ខ្ញុំទើបតែនឹងឃើញពេលនេះ ឯឯកសារដែលតុលាការស៊ើបអង្កេតដែលផ្ដល់ឲ្យខ្ញុំនេះ គឺមានពីរបីសន្លឹក ៗនោះ ខ្ញុំបានប្រាប់ថា នេះឯកសារនេះចុងក្រោយហើយៗ ខ្ញុំបានប្រាប់ថា អ៊ែ តើលោកចាំអក្សរលើឯកសារនេះជាអក្សររបស់អ្នកណា? ខ្ញុំឆ្លើយថា ខ្ញុំមិនដឹងទេ។ ប៉ុន្តែឯកសារពីរសន្លឹក ដែលតុលាការស៊ើបអង្កេតឲ្យខ្ញុំជាចុងក្រោយនោះពីរសន្លឹកមែន ខ្ញុំប្រាប់ថា ខ្ញុំអត់ដឹងទេ។ ហើយខ្ញុំមកមើលក្នុងនេះឯកសារពីរសន្លឹកហ្នឹង ក៏ខ្ញុំអត់ឃើញ យកឯកសារផ្សេងមកឲ្យខ្ញុំមើល។ ហើយអាឯកសារពីរសន្លឹកដែលខ្ញុំបានឃើញនោះ ក៏ខ្ញុំអត់បានផ្ចិតមេដៃទៀត អត់ឲ្យខ្ញុំមើលឃើញទៀត។ អានេះហើយបានខ្ញុំពិបាកឆ្លើយ បើខ្ញុំឆ្លើយអ៊ីចឹងទៅ ចប់ត្រឹមហ្នឹងទៅ មកសួរខ្ញុំទៀតទៅថា ផែនការដែលឃើញក្រដាសនេះទេ វាត្រឹមត្រូវទេ ដែលលោក ហុង ឯងមើលឃើញនេះត្រឹមត្រូវទេ? អាហ្នឹងបានខ្ញុំឆ្លើយទៅទៀតកើត។ សូមអរគុណបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ ឥឡូវខ្ញុំសាកល្បងចោទសំណួរមួយទៀត លោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សីខ្ញុំសួរថា សូមឲ្យលោកថា តើមានផ្នែកណាមួយឯកសារនេះត្រូវបានបង្ហាញជូនដែរឬទេ ពីព្រោះថានៅក្នុងកំណត់ហេតុស្ដាប់ចម្លើយលោកនោះ លោកបានទទួលស្គាល់ទាំងឈ្មោះលោក ហុង-- សមមិត្តហុង, សមមិត្តវ៉ាន់ ហើយនិងសមមិត្តជាម ដូចដែលមាននៅក្នុង-- សរសេរនៅក្នុងឯកសារនេះ។ តើសូមលោកមើលឯកសារ 00427914 ដែលជាទំព័រមួយពីរនៃកំណត់ហេតុប្រជុំស្វ័យទិតៀននេះ ហើយសូមឲ្យលោកប្រាប់មកខ្ញុំថា តើលោកបានឃើញឯកសារនេះដែរឬទេ?

[០៩:៤២:៣២]

**លោក ម៉ែខល កាណាវ៉ាស៖**

យើងគួរតែមានលេខដែលឲ្យវាស៊ីគ្នាទៅនឹងអ្វីដែលយើងមើលឃើញផង ដើម្បីឲ្យយើងបានតាមដាននីតិវិធីនេះទាន់។ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ជាភាសាអង់គ្លេស 00003310, ជាភាសាបារាំង 00657950។

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំនិយាយអំពីឯកសារដែលបង្ហាញទៅដល់សាក្សី។ តើសហព្រះរាជអាជ្ញាបង្ហាញសេចក្តីប្រកាសរបស់សាក្សីខ្លួនឯងផ្ទាល់ទៅដល់គាត់ ឬក៏បង្ហាញឯកសារពីរសន្លឹក? សេចក្តីប្រកាសលេខ 233/9 នោះគឺអ្នកស៊ើបអង្កេតមកពីអឺរ៉ុប ហើយឯកសារនេះគឺមិនមានលេខសម្គាល់នោះទេ ហើយក៏មិនមានលេខយោងទំព័រផងដែរ។ ដើម្បីបង្ហាញទៅដល់សាក្សីនោះ គាត់គួរតែប្រាប់លេខសម្គាល់ឲ្យយើងខ្ញុំផង ដើម្បីឲ្យយើងខ្ញុំតាមទាន់។ ហើយយើងអាចចោទសួរទៅលើបញ្ហានៃការស៊ើបអង្កេតនាពេលនោះផង ទោះបីជាឯកសារនោះយ៉ាងណាក៏ដោយ សូមអរគុណ។

[០៩:៤៣:៥១]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ម៉ែខល កាណាវាស។ សូមតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញនូវអត្តសញ្ញាណឯកសារ ឬក៏ទំព័រឲ្យបានជាក់ច្បាស់ជាពីរភាសា ឬជាបីភាសា ដែលយើងបានយកមកប្រើប្រាស់ និងបាននឹងកំពុងតែអនុវត្តនៅក្នុងកិច្ចដំណើរការដោះស្រាយរឿងក្តីនេះតាំងពីដើមរហូតមក។ យើងត្រូវប្រកាន់ខ្ជាប់នូវបញ្ហានេះ ពីព្រោះភាគីដែលពាក់ព័ន្ធហ្នឹងគឺមានប្រើប្រាស់បីភាសា មានខ្មែរ មានអង់គ្លេស ហើយនិងមានបារាំង។ ចៀសវាងបញ្ហាហ្នឹងដដែលៗហ្នឹង គឺគួរតែត្រូវបានចងចាំ ហើយអនុវត្តរបៀបដដែលនេះ និយាយតែម្តងគឺអាចចាំរហូតទាល់តែដោះស្រាយបញ្ហាហ្នឹងរឿងក្តីនេះចប់តែម្តង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន។ ទំព័រជាភាសាខ្មែរនោះគឺដែលខ្ញុំឲ្យយោងហើយៗគឺជាវគ្គមួយដែលមានចំណងជើងថា "ការអត្ថាធិប្បាយរបស់សមមិត្តហុង" ពាក់ព័ន្ធនឹងសមមិត្តហុង។ ខ្ញុំនិយាយអម្បាញ់មិញនេះ គឺថា 00003310-- រហូតដល់ អ្ហ៎! 339 ដល់ 3310។ ជាភាសាខ្មែរទំព័រជាបន្តបន្ទាប់នោះ បើសិនជាលោកសាក្សីគាត់បើកទំព័របន្តទៀតនោះ គឺថាមានចំណងជើងនៅទំព័រ 00427914 ជាភាសាអង់គ្លេស គឺ 00003310 ជាបារាំង គឺថា 00657950។ នេះគឺមានចំណងជើង "មតិពាក់ព័ន្ធរបស់សមមិត្តហុង-- អ្ហ៎! សមមិត្តវ៉ាន់ ដើម្បីជួយដល់សមមិត្ត ហុង។" បាទ សូមបំភ្លឺជាភាសាបារាំង គឺនេះវាមានលក្ខណៈស្មុគស្មាញ។ សេចក្តីអត្ថាធិប្បាយរបស់សមមិត្តហុងនៅទំព័រ 00657881 ហើយសេចក្តីអត្ថាធិប្បាយរបស់សមមិត្តវ៉ាន់ គឺថា 00657950។

[០៩:៤៦:៤១]

បាទ អ្វីដែលខ្ញុំដឹងគឺថា សូមលោកសាក្សីបំភ្លឺទាក់ទងនឹងទំព័រជាក់លាក់នេះ តើទំព័រទាំងអស់នេះ លោកបានឃើញដែរឬទេ ថាអ្នកស៊ើបអង្កេតបានបង្ហាញដល់លោកដែរឬទេ ពេលស៊ើបអង្កេតនោះ? ពីព្រោះថា ដោយហេតុថា លោកបាននិយាយថា លោកមានស្គាល់ឈ្មោះមួយចំនួន ហើយចំពោះខ្ញុំ ខ្ញុំគិតថាឯកសារនេះទំនងជាបានបង្ហាញជូនលោកហើយ?

**ឆ៖** បាទ ឯកសារនេះអត់បានបង្ហាញឲ្យខ្ញុំដឹងទេ។ ខ្ញុំទើបនឹងដឹងពេលនេះដែរ។ ហើយឯកសារនេះទៀត ខ្ញុំស្គាល់តែឈ្មោះខ្ញុំមួយ ហើយខ្ញុំមិនមែនសរសេរដោយខ្លួនឯងទៀត។ ឈ្មោះសមមិត្ត ហុង មតិពាក់ព័ន្ធរបស់សមមិត្ត ហុង។ ខ្លឹមសារទាំងអស់នេះ ខ្ញុំសូមបដិសេធ ព្រោះខ្ញុំមិនបានផ្តិតមេដៃនៅក្នុងឯកសារនេះទេ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្បាងលេ៖**

បាទ លោកប្រធាន ខ្ញុំមានអារម្មណ៍ថា យើងមិនទៅមុខសោះ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចទាក់ទងនឹងបញ្ហានេះ ហើយដើម្បីធ្វើយ៉ាងណាឲ្យយើងអាចបន្តទៅចោទសំណួរផ្សេងទៀតបាន។

[០៩:៤៨:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សី សាក្សីពិនិត្យឯកសារចំនួនបួននេះ។ មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារនេះទៅជូនសាក្សីពិនិត្យ ពិនិត្យតាមលំដាប់លេខរៀងដូច្នេះទៅ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

សាក្សីនៅអាចចងចាំបានទេថា ឯកសារទាំងបួនទំព័រដែលយើងបានដាក់ជូនលោកពិនិត្យអម្បាញ់មិញនេះ តើលោកចងចាំទេថាលោកបានធ្លាប់ បានឃើញ ឬក៏លោកត្រូវអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់លោកនៅដំណាក់កាលនោះ តើគេបានបង្ហាញចំពោះលោកដែរឬទេ នៅក្នុងខណៈពេលដែលគេសួរចម្លើយលោកនោះ?

[០៩:៥០:០០]

**លោក សាឡុត បាន៖**

នៅក្នុងការសួរចម្លើយនោះ បានយកឯកសារឲ្យខ្ញុំពីរបីសន្លឹក។ ប៉ុន្តែខ្ញុំមើលទៅឃើញថា ដូចជា

មិនមាននៅក្នុងឯកសារទាំងបួននេះទេ។ ខ្ញុំការចងចាំហ្នឹងគឺអ៊ីចឹង បានយកមកឲ្យខ្ញុំ។ ហើយខ្ញុំថា ខ្ញុំមិនដឹងទេ អក្សរពីណាទេ ខ្ញុំបានជម្រាបលោកអ៊ីចឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ជាការពិតណាស់ដែលលោកបានឆ្លើយយ៉ាងជាក់ច្បាស់នៅក្នុងកំណត់ហេតុ ដែលស្តាប់សក្ខីកម្មរបស់លោក នៅក្នុងអំឡុងពេលស៊ើបអង្កេត ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងឯកសារ D369/36 លោកបានបញ្ជាក់ច្បាស់ថា លោកមិនស្គាល់អ្នកសរសេរទេ មិនដឹងថានរណាទេ។ បាទ គឺលោកបានជាក់ច្បាស់ណាស់។ ប៉ុន្តែឯកសារនៅក្នុងចំណោមឯកសារទាំងអស់ហ្នឹង គឺមានឯកសារបួននេះ ដែលសំណួរគេពាក់ព័ន្ធយោងចង្អុលតែម្តង។ បានន័យថា នៅពេលដែលគេយោងចង្អុលបង្ហាញរបៀបនេះ ទំនងជាអ្នកស៊ើបអង្កេតហ្នឹងគេបង្ហាញឯកសារ បានគេ គេសរសេរនៅក្នុងការបង្ហាញឯកសារជាក់ច្បាស់នៅក្នុងសំណួរតែម្តង។

[០៩:៥១:២២]

ឧទាហរណ៍អំមិញហ្នឹងគឺសំណួរថា តាមឯកសារ D267/5/1.11.25 ERN 00427849 “ថ្នាក់ដឹកនាំក្រសួងមាន វ៉ាន់ ជាលេខា ហុង ជាអនុលេខា វឿន, វ៉ែន និង ជាម ជាសមាជិក តើលោកយល់យ៉ាងណា? រចនាសម្ព័ន្ធនេះត្រឹមត្រូវដែររទេ?” លោកចម្លើយថា “បាទ ត្រឹមត្រូវ។ ប៉ុន្តែរចនាសម្ព័ន្ធចាស់”។ នេះគ្រាន់តែឲ្យគិតដែលលោកថា បញ្ហាយើងញែកជាពីរ១បញ្ហាត្រង់ថាអាចអ្នកស៊ើបអង្កេតផ្អែកលើឯកសារទាំងមូលសួរលោក។ ប៉ុន្តែមានតែចំណុចបួនទំព័រប៉ុណ្ណោះ ដែលគាត់បានយោងជាក់ច្បាស់ ហើយបានដាក់បញ្ហានោះគឺ នៅក្នុងទំព័រនោះ នៅក្នុងសំណួរដែលគាត់សួរ ដែលខ្ញុំ-- ដែលយើងបានដាក់ជូនលោកពិនិត្យនេះ។ គ្រាន់តែឲ្យមានការចងចាំប៉ុណ្ណឹងទេ យើងអត់ចង់ដឹងរឿងថា ខ្លឹមសារយ៉ាងម៉េចទេ។ ថាតើមានអ៊ីចឹងមែនទេ អាបញ្ហាបួនទំព័រនេះ?

**លោក សាឡុត បាន៖**

ខ្ញុំសូមបញ្ជាក់ថា ឯកសារដែលយកឲ្យខ្ញុំមើលហ្នឹង មិនមែនឯកសារទាំងបួននេះទេ។ ប៉ុន្តែឥឡូវនេះ ឯកសារទាំងបួនេះ ទើបតែនឹងឃើញ។ ឯការចងចាំរបស់ខ្ញុំ វាមានរចនាសម្ព័ន្ធឈ្មោះខ្ញុំ ឈ្មោះអីយ៉ាងដូច្នេះមែន។ ក៏ប៉ុន្តែការដែលថា ខ្លឹមសារដែលសរសេរនេះ គេសរសេរយ៉ាងម៉េច១ ខ្ញុំអត់បាន--កាលជំនាន់នុំងគេអត់ឲ្យបានមើលទេ។ ដូចខ្ញុំ ១មិនមានធានា ១ថា គេសរសេរហ្នឹងត្រឹមត្រូវតាម--តាមចំណងរបស់ខ្ញុំដែលនេះទេ។ ដូច្នេះវាគ្មានការអីដែលឲ្យខ្ញុំធានាហ្នឹង បានខ្ញុំព្រួយ។ អ៊ីចេះ បានខ្ញុំព្រួយ

ហ្នឹងណ៎ា។ ឆ្លើយទៅចេះថាទទួលហើយអ៊ីចឹងទៅ ខ្ញុំខុសហើយ ពីព្រោះមិនដឹងជាសរសេរយ៉ាងម៉េច អ្នកសរសេរហ្នឹងគេអត់ឲ្យខ្ញុំមើលផង អត់ឲ្យខ្ញុំផ្តិតមេដៃផង។ គេសរសេរទៅ ជំនាន់នោះគេសរសេរទៅ គេយកទៅទុកទៅ ហើយយកទៅវាយការណ៍ឲ្យថ្នាក់លើទៅ។ ខ្ញុំ បើគេសរសេរខុសហ្នឹង ខ្ញុំក៏ងាប់ទៅ។

[០៩:៥៤:00]

**ប្រធានអង្គជំនុំ៖**

ម៉េច? អាចៗមានការភ័ន្តច្រឡំបន្តិច។ បញ្ហាដែលអង្គជំនុំជម្រះមានបំណងដាក់ឯកសារបង្ហាញនេះ ថាប្រសិនបើលោកធ្លាប់ឃើញ ព្រោះឯកសារនេះជាឯកសារដែលមិនមែនសរសេរដោយលោកទេ សរសេរដោយអ្នកផ្សេងទៀត។ អ៊ីចឹងប្រសិនបើលោកធ្លាប់ឃើញ ធ្លាប់ដឹង ហើយធ្លាប់បាន ត្រូវបានដេញដោលនៅដំណាក់មុនៗ ដូចជាអ្នកស៊ើបអង្កេតអ៊ីចឹង គឺគ្រាន់តែជាមូលដ្ឋានក្នុងការបន្តការដេញដោលតទៅទៀត។ ផ្អែកលើឯកសារនេះប៉ុណ្ណោះ មិនមែនមានន័យថា ឲ្យតែលោកទទួលខុសត្រូវលើខ្លឹមសារ ដែលផ្ទុកនៅក្នុងឯកសារនោះទេ។ ពីព្រោះឯកសារនោះ មិនមែនជាឯកសារដែលលោកសរសេរទេ។ ហ្នឹងណ៎ា!

ហើយបើលោកសរសេរក៏អង្គជំនុំជម្រះមិនអនុញ្ញាត-- អ៎! មិនតម្រូវឲ្យលោកទទួលខុសត្រូវដែរ។ ណ៎ា មិនទទួលខុសត្រូវទេ គ្រាន់តែជាមូលដ្ឋានក្នុងការដេញដោលបន្តប៉ុណ្ណោះ។

លោកមន្ត្រីរដ្ឋបាលតុលាការអាចយកឯកសារបួនទំព័រអំមិញមកវិញ!

ជាបន្តអង្គជំនុំជម្រះសូមជម្រាបលោកតំណាងសហព្រះរាជអាជ្ញាថា ឥឡូវនេះឃើញថា គាត់ភ្លេចមិនចងចាំទេ ប៉ុន្តែផ្អែកលើមូលដ្ឋាននៃសំណួរចម្លើយដែលបានធ្វើរួចហើយដោយអ្នកស៊ើបអង្កេតដែលមាននៅក្នុងសំណុំរឿងលោកអាចតាំងសំណួរទូទៅពាក់ព័ន្ធនឹងបញ្ហានោះចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីកាលពីម្សិលមិញលោកបាននិយាយថា នៅពេលប្រជុំនៅមន្ទីរប-១ ពុំមានកិច្ចប្រជុំណាដែលប្រមូលផ្តុំបញ្ញាជន និងអ្នកដែលនៅក្រោមការទទួលខុសត្រូវរបស់លោក។ ឧទាហរណ៍ ដូចជា អ្នកដែលធ្វើការខាងផ្នែកបង្កបង្កើនផលដែលជាកសិករនោះទេ។ តើលោកបានចូលរួមក្នុងសន្និបាត

ក្រសួងដែលបានរៀបចំនៅក្រសួងដែលមានលោក អៀង សារី ជាអធិបតីដែរឬទេ?

[០៩:៥៦:៣៨]

**លោក សាឡុត បាន៖**

**ឆ៖** បាទ មាន។

**ស៖** បាទ សូមលោករៀបរាប់ទាក់ទងទៅនឹងសមាជ ឬក៏សន្និបាតនេះ តើអ្នកណាខ្លះមានវត្តមាននៅទីនោះ? តើកម្មាភិបាលទាំងអស់មានវត្តមាន? សមាជិកមន្ទីរប-១ នៃក្រសួងទាំងអស់មានវត្តមាន? ឬក៏គ្រប់ប្រភេទបុគ្គលិកទាំងអស់មានវត្តមាននៅទីនោះ?

**ឆ៖** ខ្ញុំចាំមិនអស់ទេ។ ពេលខ្លះមានភារកិច្ចទៅក្រៅប្រទេស ពេលខ្លះមានភារកិច្ចដោយបន្ទាន់ទៅណាៗទៅ ក៏ខ្ញុំចាំមិនអស់ដែរ។ ក៏ប៉ុន្តែជាក់ស្តែង គឺមានគណៈមន្ទីរទាំងអស់ចូលរួម។

**ស៖** សូមអរគុណ។ តើលោកមានចាំអំពីសមាជ-- មហាសន្និបាតដែលធ្វើឡើងនៅខែកក្កដា ឆ្នាំ១៩៧៦ ដែរឬទេ?

**ឆ៖** ខ្ញុំអត់ចាំទេ។

[០៩:៥៨:២០]

**ស៖** រាល់ពេលមានមហាសន្និបាត តើមហាសន្និបាតទាំងអស់នោះប្រព្រឹត្តឡើងក្នុងរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** សន្និបាតប្រព្រឹត្តទៅតាមសភាពការណ៍។ កំណត់ថា កន្លះខែជួនកាលបានតែមួយអាទិត្យពីព្រោះសភាពការណ៍វាប្រែប្រួល មិនទៀងទេបាទ។ ជួនកាលមួយខែ ជួនកាលមួយអាទិត្យ។

**ស៖** លោកបានធ្វើដំណើរទៅក្រៅ ក៏ប៉ុន្តែលោកបានចូលរួមមហាសន្និបាតចំនួនប៉ុន្មានដងនៅក្រសួងហ្នឹង ចន្លោះខែមេសា ៧៥ ដល់ខែមករា ឆ្នាំ៧៩នោះ? ចំនួនប្រហាក់ប្រហែលបាទ សូមអញ្ជើញជម្រាប!

**ឆ៖** អត់យល់សំណួរ។ សូមទៅម្តងទៀត!

**ស៖** បាទ ខ្ញុំចង់ដឹងថា តើលោកបានចូលរួមក្នុងកិច្ចប្រជុំប្រភេទនេះ គឺថាសន្និបាតនៅក្រសួងការបរទេសនេះ ថាលោកបានចូលរួមក្នុងមហាសន្និបាតបែបនេះ នៅចន្លោះឆ្នាំ៧៥ ដល់ ៧៩នេះ ចំនួនប៉ុន្មានដង? ទោះបីជាលោកបានប្រាប់យើងហើយថាលោកធ្លាប់ជាប់រវល់ចេញទៅក្រៅខ្លះ។ អ៊ីចឹងសូមលោកប្រាប់ចំនួន ដែលលោកបានចូលរួមទៅមហាសន្និបាតទាំងអស់នេះ ហើយដែលមានលោក អៀង

សារី ជាអធិបតី?

**ឆ៖** ប្រហែលជាពីរដងតែប៉ុណ្ណឹងទេ មិនច្រើនជាងបីដងទេបាទ។

**ស៖** នៅខែកក្កដា ឆ្នាំ១៩៧៦ តើមានការចាប់មនុស្សនៅក្នុងក្រសួងការបរទេសដែរឬទេ? ការចាប់មនុស្សច្រើននៅក្រសួងការបរទេស?

**ឆ៖** បាទ ខ្ញុំអត់ចាំថ្ងៃទេ ដឹងថាមកចាប់។

[១០:០១:២១]

**ស៖** តើលោកចាំអំពីមូលហេតុនៃការចាប់ខ្លួនដែរឬទេ? ពីព្រោះនៅក្នុងចម្លើយទី៥៧ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ D369/36។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធានសូមអនុញ្ញាតបង្ហាញឯកសារនេះទៅដល់សាក្សី ដែលលោកបានរៀបរាប់នៅក្នុងឯកសារនេះមានការចាប់ទ្រង់ទ្រាយធំ។

បាទ ក្នុងចម្លើយទី៥៧ បាទសូមអនុញ្ញាតចាក់បញ្ចាំងឯកសារនេះទៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១០:០២:២០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ សំណួរខ្ញុំ គឺចង់ដឹងថាតើហេតុអីបានមានការចាប់មនុស្សទ្រង់ទ្រាយធំនៅពេលនោះ គឺថានៅខែ ក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៦នេះ?

**លោក សាឡុត បាន៖**

**ឆ៖** តាមចម្លើយខ្ញុំនេះ ខ្ញុំមកពិនិត្យ ទ្រង់ទ្រាយធំនេះគឺទូទាំងប្រទេសទេ មិនមែនក្នុង ប-១ ទាំងមូលទេបាទ។

**ស៖** បាទ ខ្ញុំយល់ គឺថានៅក្នុងមន្ទីរប-១ ហើយនិងទូទាំងប្រទេសតែម្តង។ តើលោកអាចផ្តល់មូលហេតុនៃការចាប់ខ្លួននេះដែរឬទេ? បើសិនជាលោកដឹង សូមអញ្ជើញជម្រាបជូនអង្គជំនុំជម្រះ។

**ឆ៖** ខ្ញុំមិនដឹងមូលហេតុទេ។ ប៉ុន្តែខ្ញុំភ្លាប់សភាពការណ៍ គឺវៀតណាមកាន់តែបុកកៀកចូលមកភ្នំពេញហើយ។

[១០:០៤:00]

**សៈ** តើផលពិបាកនៃការវាយប្រហាររបស់វៀតណាមមកលើប្រទេសកម្ពុជានោះ គឺជាអ្វី? តើមានការចាប់ខ្លួនដែលមានទំនាក់ទំនងជាមួយនឹងការប្រហារពីសំណាក់វៀតណាម ឬក៏យ៉ាងម៉េច?

**ឆៈ** ខ្ញុំមិនដឹងយ៉ាងណាទេ ខ្ញុំដឹងរួមៗ តាមព័ត៌មានយោធាដែលគេមកពីព្រំដែន គេថាមកកៀកៗហើយ។ វ៉ៃគ្នាខ្លាំងណាស់នៅព្រំដែន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**សៈ** នៅពេលដែលយើងស្វែងរកចារកម្មវៀតណាមនៅក្នុងក្រសួងនោះ តើមានការស្វែងរកតាមចាប់ចារម្មនោះទេ?

**ឆៈ** ខ្ញុំបាននិយាយពីម្សិលមិញហើយ ខ្ញុំអត់អ្នកជំនាញខាងហ្នឹងទេ។ ខ្ញុំគ្រាន់តែអប់រំបងប្អូនប្រយ័ត្នប្រយ៉ែង នៅឲ្យស្ងៀម កុំទាក់ទងរហេតរហូត ពីព្រោះគេប្រយ័ត្នប្រយ៉ែងទូទៅណាស់។

**សៈ** បាទសូមអរគុណ។ នៅក្នុងសមាជមួយក្នុងក្រសួងដែលលោកបានចូលរួម តើលោកមិនដែលធ្លាប់បានឮលោក អៀង សារី និយាយថា ប្រទេសត្រូវបាន-- ត្រូវមានអ្នកជនក្បត់ ឬក៏រូងស៊ីរូងផ្ទៃក្នុង ពីមួយទៅប្រាំភាគរយ ហើយត្រូវតែតាមដានប្រវត្តិរូប ហើយនិងតាមធ្វើការជីវទស្សន៍។ តើលោកធ្លាប់បានឮលោក អៀង សារី និយាយយ៉ាងដូច្នេះដែរឬទេ?

**ឆៈ** ពាក្យពេចន៍អស់ទាំងនេះ ខ្ញុំអត់ចាំទេ ប៉ុន្តែខ្ញុំចាំជារួមថា ឲ្យត្រូវប្រុងប្រយ័ត្នៗបដិវត្តន៍ឲ្យខ្ពស់។ កុំឲ្យ ពួដ៏ផ្ទៃក្នុងយើងនេះ ខូចទឹកចិត្តរវើរវាយអំពីទស្សនៈស្នេហាជាតិ។ ខ្ញុំយល់តែប៉ុណ្ណឹង។

[១០:០៦:៥៧]

**សៈ** តើការប្រយ័ត្នផ្នែកសន្តិសុខនៅក្នុងមន្ទីរសន្តិសុខ ប-១ តើនេះបានន័យថាត្រូវរកខ្មាំងស៊ីរូងផ្ទៃក្នុង ឬក៏យ៉ាងម៉េច?

**ឆៈ** សំណួររបស់លោកនេះ ដូចជាខ្ញុំពិបាកឆ្លើយដែរ។ វាត្រូវតែរកខ្មាំង ឯខ្មាំងហ្នឹងគឺខ្មាំងអី ជាទីមួយ គឺខ្មាំងពួដ៏ផ្ទៃក្នុងខ្លួនឯងហ្នឹង ខ្ញុំបានប្រាប់ពីម្សិលមិញហើយតើ។ បើរកខ្មាំងខ្លួនឯងឃើញហើយរកខ្មាំងខាងក្រៅឃើញហើយ។

**សៈ** តើលោកចាំអំពីវគ្គមួយ ដែលស្ត្រីពីរនាក់ត្រូវបានគេឃើញកំពុងបំពេញសកម្មភាពក្បត់នៅក្នុងក្រសួងការបរទេសដែរឬទេ? ខ្ញុំមានមូលដ្ឋានផ្អែកលើឯកសារ ហើយខ្ញុំមិនបានបង្ហាញឯកសារនេះទេលោកប្រធាន។

[១០:០៨:៣៣]

**ឆ៖** ខ្ញុំអត់បានចងចាំទេ។

**ស៖** តើលោកធ្លាប់បានឮគេនិយាយថាលោក អៀង សារី នៅសមាជមហាសន្និបាត ឬក៏ក្នុងកិច្ចប្រជុំជីវទស្សន៍ ដែលលោក អៀង សារី ថាត្រូវតែបង្កើនការប្រុងប្រយ័ត្នចំពោះអ្នកដែលមានសញ្ញាបត្រ ឬក៏បញ្ញាជន?

**ឆ៖** ពាក្យពេចន៍នេះគ្មានទាល់តែសោះ។

**ស៖** តើនៅក្នុងកិច្ចប្រជុំប្រភេទនេះ គាត់ធ្លាប់បាននិយាយថានៅក្នុងផ្នែកបញ្ញាជននោះ ខ្វះកម្មាភិបាលកសិករ ឬក៏កម្មករ ដើម្បីបង្កើតឲ្យមានលំនឹងនៅក្នុងផ្នែកបញ្ញាជននេះដែរឬទេ?

[១០:១០:០២]

**ឆ៖** គាត់-- ខ្ញុំអត់ចាំទេ ប៉ុន្តែខ្ញុំឮថា ត្រូវតែទៅមុខទៀត ត្រូវតែបង្រៀនកុមារ កូនអ្នកក្រីក្រឲ្យចេះធ្វើការងារដូចបញ្ញាជន។

**ស៖** តើលោកស្គាល់សមមិត្ត មឿន ដែរឬទេ? ខ្ញុំអាន អ៊ឹម-អូ-អ៊ី-អ៊ុយ-អ៊ិន (MOEUN) គាត់ធ្វើការនៅក្រសួងការបរទេស លោកស្គាល់គាត់ដែរឬទេ?

**ឆ៖** ភេទអី? សមមិត្តមឿន ដែលលោកសួរអំមិញហ្នឹងភេទអី?

**ស៖** ខ្ញុំមិនដឹងថាគាត់ប្រុស ឬស្រីនោះទេ ក៏ប៉ុន្តែគាត់ជាកម្មាភិបាលនៃក្រសួងនេះ។ តើលោកចាំថា មានកម្មាភិបាលណាមួយឈ្មោះមឿន ដែរឬទេ?

**ឆ៖** បើលោកអត់ស្គាល់ភេទ ខ្ញុំក៏មិនបាច់ឆ្លើយបានដែរ។

[១០:១១:៤៣]

**ស៖** លោកសាក្សីនៅពេលប្រជុំជីវទស្សន៍ តើមានអ្នកណាម្នាក់ដែលទទួលបន្ទុកក្នុងការធ្វើការកត់ត្រាដែរឬទេ? នៅពេលដែលកម្មាភិបាលធ្វើការស្វ័យទិតៀន ហើយនិងការកត់សម្គាល់ ឬក៏ការទាញការសន្និដ្ឋានរបស់លោក អៀង សារី នៅពេលបញ្ចប់កិច្ចប្រជុំ។ តើមានការកត់ត្រាទុកជាឯកសារដែរឬទេ?

**ឆ៖** ឯកសារមានការកត់ត្រាខ្លះ ខ្លះអត់មានការកត់ត្រាទេ។ ឯកសារណាសំខាន់ៗកត់ត្រា ឯកសារណាមិនសំខាន់ទេ អត់កត់ត្រាទេ។

**ស៖** តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការធ្វើកំណត់ហេតុនៅក្រសួងការបរទេសក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំស្វ័យទិតៀននេះ?

**ឆ៖** អត់មានកំណត់នរណាមួយទេ គឺអ្នកណាកត់បានប៉ុនណាយកប៉ុនណ្ណឹង ហើយទុកដាក់ខ្លួនគេទៅ។

**ស៖** ក៏ប៉ុន្តែលោកទើបតែបាននិយាយថា មានកំណត់ហេតុដែលគេសរសេរពេលមានកិច្ចប្រជុំ ហើយមានអ្នកចូលរួមជាច្រើន។ តើមានកំណត់ហេតុដែលត្រូវតែសរសេរដែល*ដាក់ទីឡូ* ហើយសរសេរក្នុងម៉ាស៊ីនជាដើម ឬក៏ជា-- ដោយដៃ?

[១០:១៣:៤០]

**ឆ៖** ពាក្យថា ប្រជុំធំៗ ដូចជាប្រជុំទៅបរទេស សុន្ទរកថាអីផ្សេងៗនុ៎ង ក្រសួងផ្នែកបរទេសគេកត់ត្រាៗជាសំខាន់។ ឯផ្នែកខ្ញុំណោះ ខាងជីវភាពឯណោះអត់ទេ អត់មានកត់ត្រាអីជាសំខាន់ទេបាទ។

**ស៖** នៅពេលសមាជ ឬមហាសន្និបាតនេះ តើមិនដែលមានកម្មាភិបាលណាដែលមករៀបរាប់រាយការណ៍ថា ប្រជាជននោះមានទុរភិក្ស មិនមានបាយហូប តើធ្លាប់មានដែរឬទេ?

**ឆ៖** ធ្លាប់មាន ដូចជាខ្ញុំជាដើម។

**ស៖** ហើយការរាយការណ៍នេះ រាយការណ៍នៅពេលណា ជាលើកដំបូងបំផុតនោះ?

**ឆ៖** រាយការណ៍ប្រហែលជាមួយខែ ឬបីអាទិត្យពេលវៀតណាមចូលស្រុក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំមិនដឹងថា ខ្ញុំអាចទាញការសន្និដ្ឋានដែរឬទេ? គឺថានៅក្នុងឯកសារមួយ គឺលេខឯកសារ អ្ហឺ! គឺថាតាមពិតទៅ គឺថាបើតាមឯកសារខ្ញុំនោះ-- គឺថាតាំងពីឆ្នាំ១៩៧៦ មកម្ល៉េះមិនមែនថាពីឆ្នាំ១៩៧៨ នោះទេ?

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកយល់សំណួរខ្ញុំដែរឬទេ?

**លោក សាឡូត បាន៖**

**ឆ៖** សុំម្តងទៀត។

[១០:១៦:២៣]

**ស៖** តើនៅក្នុងឆ្នាំ១៩៧៦ នៅពេលប្រជុំនៅក្នុងក្រសួងការបរទេសនោះ មានកម្មាភិបាលដែលរៀបរាប់អំពីការព្រួយបារម្ភរបស់ខ្លួនដែលថា ដោយសារប្រជាជនពុំមានអ្វីបរិភោគនោះ តើលោកធ្លាប់បានឮការនិយាយបែបនេះទេ តាំងពីឆ្នាំ១៩៧៦នោះ ហើយមិនមែនដូចអ្វីដែលលោកបាននិយាយថាចាប់

ពីខែកញ្ញា ឆ្នាំ១៩៧៨នោះទេ តើលោកគិតយ៉ាងម៉េចដែរ?

**ឆ៖** បញ្ហានេះ ការអត់ឃ្លាន ជាទូទៅគឺអត់ឃ្លានហើយសង្គ្រាម ប៉ុន្តែការដែលមិនអនុវត្តនយោបាយរបស់បក្សកន្លែងខ្លះ ដែលធ្វើឲ្យប្រជាជនអត់ឃ្លាន ផ្នែកមូលដ្ឋានគេគេរាយការណ៍ ខ្ញុំមិនដឹងទេ ចំពោះខ្ញុំៗរាយការណ៍ ខ្ញុំមិនសូវធ្លាប់ដើរ ដល់ខ្ញុំដើរទៅឃើញ ខ្ញុំច្រើនតែនៅមន្ទីរ ដល់ដើរទៅឃើញ ខ្ញុំក៏រាយការណ៍ដែរ។ រាយការណ៍ហ្នឹង កំណត់ហេតុជាថ្ងៃជាខែ ដូចខ្ញុំជម្រាបហើយ។

**ស៖** បាទ អរគុណលោកសាក្សី។ តើលោកធ្លាប់បានធ្វើទស្សនកិច្ចជាញឹកញាប់នៅជនបទ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ? តើហើយលោកអាចជម្រាបឲ្យជាក់លាក់ថា នៅពេលណាដែលលោកបានចុះទៅមូលដ្ឋានដោយផ្ទាល់នោះ?

**ឆ៖** ពាក្យទស្សនកិច្ច ខ្ញុំមិនមានទេ ពេលនោះមានតែធ្វើការងារ។ ប៉ុន្តែខ្ញុំបានជូនភ្ញៀវខ្លះៗ ភ្ញៀវតូចតាច ភ្ញៀវជាកាសែត ជាអីហ្នឹង។ ដល់ទៅប្រជាជនចេះតែមកប្រាប់ខ្ញុំថា មានកម្មាភិបាលធ្វើបាបឯលិចឯកើតអ៊ីចឹងទៅ។ ខ្ញុំកន្លែងខ្លះក៏អត់ ស្បៀងអី អាហារអីហូបចុក។ ខ្ញុំក៏មករាយការណ៍ទៅ។

[១០:១៩:០៣]

**ស៖** តើចាប់ពីឆ្នាំណាទៅដែលលោកជូនដំណើរប្រតិភូ-- គណៈប្រតិភូអន្តរជាតិដែលមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា? ហើយនៅពេលនោះ តើលោកបានធ្វើដំណើរនៅក្នុងប្រទេសកម្ពុជាតើចាប់ពីឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនចាំដំណើរខ្ញុំប៉ុន្មានដងៗទេ។ ប៉ុន្តែមួយឆ្នាំ ម៉េចក៏មានពីរដងដែរ ជូនភ្ញៀវបាទ។

**ស៖** អ៊ីចឹងពីរដងក្នុងមួយឆ្នាំ អ៊ីចឹងលោកចង់និយាយថា ចាប់តាំងពីឆ្នាំ១៩៧៥ ឬក៏ពេលក្រោយមកហើយទេ?

**ឆ៖** ចាប់តាំងពីមានភ្ញៀវមកដល់ស្រុក ចូលមកបោះទីតាំងនៅស្រុកជាទូត ជាអីហ្នឹងបាទ។

**ស៖** តើលោកបានជូនដំណើរគណៈប្រតិភូចិននៅក្នុងប្រទេសកម្ពុជាដែរឬទេ? ហើយលោកអាចជម្រាបបានទេថា ប្រហែលនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់មានដែលបានជូនប្រតិភូចិនទេ។ ក្រៅពីនោះខ្ញុំជូន។

**ស៖** តើលោកអាចរៀបរាប់អំពីសញ្ជាតិគណៈប្រតិភូដែលបាន-- លោកបានជូនដំណើរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ថាមិនចាំបាច់រៀបរាប់ទាំងអស់ទេ គ្រាន់តែឲ្យមួយចំនួនមកក៏បានដែរ។

**ឆ៖** កាសែត ដូចជាកាសែតអាមេរិក កាសែតជប៉ុន NHK។ កាសែតអាមេរិកខ្ញុំមិនស្គាល់ឈ្មោះទេ។

[១០:២១:៤៦]

**ស៖** តើលោកធ្លាប់បានជូនដំណើរគណៈប្រតិភូប៊ែលហ្ស៊ិក ដែលជាសមាគមមិត្តភាពរវាងកម្ពុជានិងប៊ែលហ្ស៊ិកដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានជូន។

**ស៖** តើនៅក្នុងឱកាសនេះ គឺថានៅពេលចុងបញ្ចប់នៃទស្សនកិច្ចនោះ លោកធ្លាប់ទៅជាមួយគណៈប្រតិភូនោះទៅមន្ទីរ ក-១ ដើម្បីជួប ប៉ុល ពត ដែរឬទេ?

**ឆ៖** ខ្ញុំចាំអត់បានបាទ។

**ស៖** តើលោកធ្លាប់បានជូនដំណើរគណៈប្រតិភូឡាវដែលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៧ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានជូនទេ។ ទេៗ ដូចខ្ញុំបានជូនដែរបាទ ទៅកំពង់សោម បាទទៅកំពង់សោម។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលៈ**

លោកប្រធាន ខ្ញុំចង់បង្ហាញរូបថតមួយចំនួន ដែលអាចបំភ្លឺយើង គឺឯកសារថ្មី ឯកសារដែលយើងបញ្ចូលទៅក្នុងសំណុំរឿងនៅខែមេសា ឆ្នាំមុននេះ។

រូបថតទីមួយដែលខ្ញុំចង់បង្ហាញ គឺP00513612។ អ៊ីចឹង ខ្ញុំសូមបង្ហាញរូបទាំងបីនេះទៅសាក្សីតែម្តង។ រូបថតទីពីរ គឺ P00513592, រូបថតទីបី គឺ P00513420។ បាទ ខ្ញុំសូមលោកប្រធានអនុញ្ញាតបង្ហាញរូបថតទាំងបីនេះនៅលើអេក្រង់ ហើយនិងសូមជូនឯកសារចម្លងទៅសាក្សី។

[១០:២៤:២២]

**ប្រធានអង្គជំនុំៈ**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ជូនទៅសាក្សីពិនិត្យ! ហើយនិងអនុញ្ញាតឲ្យបង្ហាញរូបថតនេះនៅលើអេក្រង់កុំព្យូទ័រ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលៈ**

ខ្ញុំចាប់ផ្តើមនិយាយអំពីរូបថតទីមួយ។ លោកសាក្សីសូមមើលរូបថត 00513612 ដែលមាននៅ

លើអេក្រង់នេះ។ តើលោកស្គាល់អ្នកណារូបចាប់ពីខាងស្តាំមក រូបនុ៎ងជារូបអ្នកណា?

**ឆ៖** ទីមួយ ខ្ញុំឃើញដូចជាក៏មិនសូវច្បាស់ដែរទេ ប្រហែលជាបង អៀង សារី។ នៅខាងក្រោយគេនោះ មួយ ពីរ បី មកក៏មិនសូវច្បាស់ដែរ គ្រាន់តែប្រហែលបង នួន ជា។ បានមកមកនេះមកបានបង ខៀវ សំផន បាទ។ ច្បាស់តែប៉ុណ្ណឹងទេបាទ។

**ស៖** តើលោកស្គាល់រូបលោកផ្ទាល់នៅលើរូបថតនេះដែរឬទេ?

**ឆ៖** ដូចជាគ្មានរូបខ្ញុំទេ ពេលនោះ ខ្ញុំអ្នកទទួលបាយទឹក។ គ្មានពេលអីមកត្រង់នេះទេបាទ។

**ស៖** តើអ្នកណាដែលថា អ្នកដែលមានរូបរាងសង្ហានេះ នៅខាងស្តាំទាំងអស់ដែលរូបគាត់ហ្នឹងដាច់ពាក់កណ្តាល តើលោកស្គាល់រូបថតនុ៎ងដែរឬទេ?

[១០:២៦:៥៧]

**ឆ៖** ខ្ញុំដូចមិនស្គាល់ទេ។ រូបនេះវាដូចតារាដែរ ដូចអត់ស្គាល់បាទ។

**ស៖** រូបៗទីពីរ សូមលោកប្រាប់យើង P00513592 ហើយយើងឃើញមានរូបមនុស្សដែលដើរចុះកាំជណ្តើរ តើលោកមានស្គាល់អ្នកណាទេនៅក្នុងរូបថតនេះ? តើមនុស្សនៃរដ្ឋាភិបាលកម្ពុជាហើយនិងគណៈប្រតិភូដែលមកទស្សនកិច្ចនៅប្រទេសខ្មែរ?

**ឆ៖** ប្រតិភូឡាវនេះ ខ្ញុំភ្លេចឈ្មោះហើយ។ បន្ទាប់ពីនេះមកខ្ញុំស្គាល់តែបង ខៀវ សំផន។ ក្រោយមកទៀតវាមិនសូវច្បាស់ ខ្ញុំមិនអាចកំណត់ថា នរណាបានទេបាទ។

**ស៖** តើលោកដឹងថា រូបថតនេះ ថតនៅកន្លែងណាដែរឬទេ? នេះជារូបថតគណៈប្រតិភូបើតាមរូបថតនុ៎ង អ៊ីចឹងលោកអាចសន្និដ្ឋានថា ថតកន្លែងណាដែរឬទេ?

[១០:២៨:៥១]

**ឆ៖** បាទខ្ញុំបែបអត់ៗដឹងទេបាទ។ ជំនាន់នុ៎ងភារកិច្ចដាំបាយចុះពីកប៉ាល់ហោះមក ទៅរៀបរយបាយទឹកហើយ។

**ស៖** ឥឡូវរូបថតទីបី ដែលថាក្នុងរូបថតនុ៎ងមានមនុស្សដដែលទេ គឺឯកសារ P00513420។ ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតនេះ ហើយតើលោកស្គាល់កន្លែងដែលគេថតរូបនេះទេ? រូបថតជាផ្លូវការនេះ? មើលទៅឃើញថា នៅក្នុងផ្ទះដ៏ធំមួយ។

**ឆ៖** រូបថតនេះ បើខ្ញុំមិនច្រឡំទេ ប្រហែលជាគេហៅថា ផ្ទះលេខ១ *វ៉េស៊ីដង់* ចាស់នោះបាទ។

[១០:៣០:០៦]

**ស៖** នេះជាគណៈប្រតិភូឡាវដដែល ឬក៏យ៉ាងម៉េច? ហើយលោកស្គាល់សមាជិករដ្ឋាភិបាល ឬក៏គណៈកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យដែរឬទេ នៅលើរូបថតនេះ?

**ឆ៖** ប្រតិភូឡាវខ្ញុំមិនស្គាល់ទេ ឯរូបមានបង អៀង សារី, បង ខៀវ សំផន ក្រៅពីនេះហ្នឹង ខ្ញុំអត់ច្បាស់ទេ មើលអត់ច្បាស់ មិនដឹងនរណា។ អ៊ូ! មានម្នាក់ទៀត នេះខាងស្រី បង អៀង ធីរិទ្ធ, បង យុន យ៉ាត ឯនារីម្នាក់នេះទៀតខ្ញុំក៏អត់ស្គាល់ដែរ។

**ស៖** អ្នកដែលនៅក្បែរនារីទីបីនេះ តើហ្នឹងជារូបលោក ឬក៏យ៉ាងណា?

[១០:៣១:៣៤]

**ឆ៖** ដូចអ្នកបម្រើ មិនមែនរូបខ្ញុំទេ។

**ស៖** លោកសាក្សី លោកគិតថា នេះជារូបអ្នកបម្រើនៅលើរូបថតជាផ្លូវការ។ លោកប្រាកដទេ ក្នុងការដែលទាញការសន្និដ្ឋានបែបនេះនោះ?

**ឆ៖** ពេលនោះ គឺគេប្រមូលអ្នក ខ្ញុំយល់ថា គេប្រមូលអ្នកដែលធ្វើការនៅជុំហ្នឹង ខ្ញុំពិបាកពន្យល់ណាស់។ គឺថាពេលនោះ អ្វីៗស្មើគ្នាទាំងអស់។ អ្នកណាមានភារកិច្ចសន្តិសុខ គឺមិនអាចមកអឺចឹងបានទេ។ ដូចខ្ញុំខាងសន្តិសុខ អត់មកឈរអឺចឹងបានទេ ពិតមែនឋានៈធំ។ ដូច្នេះបែបមានប្រតិភូអីគេ ចង់ថា អ៎ អ្នកបម្រើមក ថតអីជាមួយខ្ញុំអឺចឹង គេស្មើភាពគ្នា វាខុសពីអីរ៉ុប។ បាទ សូមជ្រាប។

**ស៖** បាទ សូមអរគុណ។ បាទ ទាក់ទងនឹងគណៈប្រតិភូឡាវដែលបានមកប្រទេសកម្ពុជា តើលោក អៀង សារី បានជូនដំណើរពួកគាត់ដែរឬទេ ទៅ-- ចុះទៅមូលដ្ឋាន? ព្រោះថាគាត់បានទៅសៀមរាប។ ហើយជាទូទៅតើលោកដឹង បានដឹងថា អៀង សារី ធ្លាប់បានជូនដំណើរគណៈប្រតិភូសំខាន់ៗ ចុះទៅមើលមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាដែរឬទេ?

[១០:៣៣:៤១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ លើកលែងតែមានការ-- នេះជា ដូចជាសំណួរដែលមានពាក់ព័ន្ធទៅរូបីនេះ គឺជាពិសេសសំណួរចុងក្រោយ យើងបានដឹងហើយផ្នែកទី១ ផ្នែកទី២ ផ្នែកទី៣ គឺសាក្សីបាន

ឆ្លើយរួចទៅហើយ។ ខ្ញុំយល់ឃើញថា គួរតែបំបែកសំណួរនេះឲ្យវាមានលក្ខណៈងាយស្រួល។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:៣៤:២៩]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជិតដល់ពេលសម្រាកហើយ ឥឡូវនេះខ្ញុំសូមកាត់សំណួរខ្ញុំឲ្យខ្លីៗ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** នៅពេលដែលលោកទៅសៀមរាបជាមួយនឹងគណៈប្រតិភូឡាវនោះ តើលោករដ្ឋមន្ត្រី អៀង សារី នោះមានវត្តមាននៅទីនោះដែរ ឬក៏អត់?

**លោក សាឡុត បាន៖**

**ឆ៖** មិនចងចាំទេ តែខ្ញុំអត់បានជូនប្រតិភូនេះទៅសៀមរាបទេ។

**ស៖** បាទ សូមអភ័យទោស គឺថាលោកបានជម្រាបអម្បាញ់មិញ គឺថាលោកថាទៅកំពង់សោមទេ។ អ៊ីចឹងៗនៅពេលដែលលោកទៅកំពង់សោមនោះ តើ អៀង សារី ទៅជាមួយលោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ចងចាំដែរ។

**ស៖** ឥឡូវនេះខ្ញុំចោទសំណួរទូទៅវិញ។ តើលោក អៀង សារី ធ្លាប់ជូនគណៈប្រតិភូសំខាន់ៗ ឧទាហរណ៍ដូចជា រដ្ឋមន្ត្រី ឬក៏ប្រមុខរដ្ឋបរទេស ដែលមកទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងចន្លោះខែមេសា ៧៥ ដល់ មករា ៧៩?

**ប្រធានអង្គជំនុំ៖**

ចាំៗ អត់ទាន់ក្បាលមីក្រូ។

**លោក សាឡុត បាន៖**

**ឆ៖** ភារកិច្ចលោកជាអ្នកទទួលភ្ញៀវ គឺលោកត្រូវតែទទួលប្រតិភូ ប៉ុន្តែថ្ងៃ ខែណាៗ ខ្ញុំអត់ចាំទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹងគាត់បានទទួលគណៈប្រតិភូ។ តើគាត់បានចុះទៅមូលដ្ឋានជាមួយគណៈប្រតិភូទាំងអស់នោះដែរឬទេ? នេះជាសំណួររបស់ខ្ញុំ។

**ឆ៖** គាត់-- ខ្ញុំមិនចងចាំទេ គាត់ចុះមូលដ្ឋាន ប៉ុន្តែពេលណាៗខ្ញុំមិនដឹងដែរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទអរគុណលោកប្រធាន ខ្ញុំឃើញថាពេលវេលាកាន់តែទៅមុខហើយ ឥឡូវម៉ោងដប់សែសិបនាទីហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកសមរម្យសម្រាប់សាក្សីនៅបន្ទប់សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ រួមជាមួយនឹងមេធាវីប្រឹក្សារបស់គាត់នៅវេលាម៉ោងដប់មួយ។

សូមអញ្ជើញលោកមេធាវី!

[១០:៣៧:៥៣]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាពហើយដែលលោក អៀង សារី ពិបាកក្នុងការបន្តអង្គុយនៅទីនេះ លោកស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះសម្រាប់មួយថ្ងៃនេះពេញតែម្តង ប៉ុន្តែសូមចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេចតាមសំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ អង្គុយចុះ! បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ពី-- សម្រាប់អំឡុងពេលសវនាការសម្រាប់ថ្ងៃនេះ។ ដោយបញ្ហាមូលហេតុសុខភាព អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ច

ដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ដំណើរការសវនាការពេញមួយថ្ងៃនេះ ចាប់ពីពេលនេះទៅរហូតដល់ចប់សវនាការនៅពេលរសៀល។

[១០:៣៩:១៤]

តែក្រុមមេធាវីការពារក្ដីត្រូវប្រគល់មកអង្គជំនុំជម្រះភ្លាម នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់លោក អៀង សារី។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់កិច្ចដំណើរការសវនាការជាបន្តសម្រាប់ថ្ងៃនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០០នាទី)*

[១១:០០:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីការសវនាការ និងសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះ លោកបាននិយាយថាលោករាយការណ៍ទៅ អៀង សារី

ពាក់ព័ន្ធទៅនឹងភាពអត់ឃ្លានដែលលោកបានកត់សម្គាល់ឃើញនៅមូលដ្ឋាន នៅពេលដែលលោកធ្វើដំណើរនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីមានការរាយការណ៍ជូនរដ្ឋមន្ត្រីរួចហើយ តើមានគោលនយោបាយថ្មីអ្វីទេ ពាក់ព័ន្ធនឹងបញ្ហានេះ?

[១១:០១:៣១]

**លោក សាឡុត បាន៖**

**ឆ៖** បាទ គឺមាននយោបាយធ្វើជាសារាចរ ជាច្បាប់ តាមខ្ញុំចាំ។ ដោយត្រួសៗនោះ ទីមួយ មូលដ្ឋានត្រូវមានឲ្យបាយៗប្រជាជនហូបឲ្យគ្រប់គ្រាន់។ ទីពីរ ការដែលត្រូវចោទថា អ្នកណាៗមានទោសយ៉ាងណាៗ? ត្រូវឲ្យទៅតាមថ្នាក់ ប្រាំពីរថ្នាក់។ ថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ភូមិភាគ ថ្នាក់ប្រទេស និងថ្នាក់មជ្ឈិម សម្រេចបានៗ។

**ស៖** នៅពេលដែលលោកនិយាយថា ចំពោះសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការចោទប្រកាន់ចំពោះបទល្មើសនោះ។ តើវាជាសេចក្តីសម្រេចយកទៅសម្លាប់ចោល ឬក៏យ៉ាងណា? សូមលោកបញ្ជាក់ឲ្យបានបន្តិចទៅមើល។

**ឆ៖** សូមលោកជ្រាប មិនមែនសម្រេចទៅសម្លាប់ចោលទេ។ គឺខ្ញុំនិយាយថា ត្រួតពិនិត្យឲ្យបានប្រាំពីរថ្នាក់ ឲ្យបានប្រាំពីរថ្នាក់នេះ តើទោសនោះ យ៉ាងណាៗ? ខ្ញុំក៏មិនដឹងដែរ គ្រាន់តែថា បានប្រាំពីរថ្នាក់សិន។ ឯទោសទៅមុខទៀត អីយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមយោងទៅលើឯកសារមួយ ដែលជាកំណត់ហេតុ លេខ D91/14។ សូមផ្តល់ជូនលេខ ERN ជាភាសាខ្មែរ 00204097 ជាភាសាបារាំង 00503936 ជាភាសាអង់គ្លេស 00361011។ សូមការអនុញ្ញាតបង្ហាញឯកសារនេះ នៅលើអេក្រង់។

[១១:០៤:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:០៥:០៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមអានម្តងទៀតជាភាសាខ្មែរ 00204097 ប្រហែលជានៅចុងទំព័រ។ ជាភាសាអង់គ្លេសគឺ

ទំព័រ 00223593។ ខ្ញុំសូមកែចំពោះលេខ ERN ដាក់ជាភាសាអង់គ្លេសដែលខ្ញុំបានផ្តល់មុននេះ។ នៅក្នុងចម្លើយនេះ ប្រហែលជានៅពាក់កណ្តាលលោកបាននិយាយថា លោកបានជូនដំណើរភ្ញៀវទៅខេត្តសៀមរាប ហើយនៅពេលនោះ ខ្ញុំបានឃើញប្រជាជនជួបការលំបាកជាខ្លាំង។ ហើយពេលនោះ ក៏ខ្ញុំបានជួបឪពុករបស់ខ្ញុំនៅកំពង់ធំ គាត់ក៏ជួបការលំបាកដូចគ្នាដែរ។ ពេលត្រឡប់មកវិញ ខ្ញុំបានរាយការណ៍ជូនលោក អៀង សារី អំពីទុក្ខវេទនារបស់ប្រជាជននេះ ហើយលោក អៀង សារី ក៏បានរាយការណ៍ទៅមជ្ឈិម។ ចាប់បីពេលនោះមក គណៈមជ្ឈិមបក្សបានរៀបចំនយោបាយថ្មី កំណត់ថាកម្មាភិបាលណាដែលបានឲ្យប្រជាជនហូបបបរ គឺកម្មាភិបាលនោះជាអ្នកក្បត់ប្រជាជន។ ការសម្រេចសម្លាប់ប្រជាជនណាម្នាក់លុះត្រាតែមានការសម្រេចពីថ្នាក់ភូមិ ឃុំ ស្រុក តំបន់ ភូមិភាគ និងសមាជិកគណៈមជ្ឈិមបក្សបីនាក់ទើបអាចធ្វើទៅបាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

**សៈ** លោកសាក្សី តើលោកនៅតែរក្សាចម្លើយដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុនេះដែរឬទេ?

[១១:០៧:១៦]

**លោក សាឡូត បាន៖**

**ឆៈ** បាទ ខ្ញុំរក្សាចម្លើយតាមនេះ ប៉ុន្តែសូមបញ្ជាក់ មិនទាន់អនុវត្តទេ មិនទាន់អនុវត្តបានទេ។ វៀតណាមចូលស្រុក បែកបាក់គ្នាតែម្តង។

**សៈ** សូមអរគុណ។ នេះគឺជានយោបាយថ្មីដែលហាក់ដូចជាតឹងតែងជាងមុន។ តើៗគោលនយោបាយពីមុននោះជាគោលនយោបាយបែបណាពាក់ព័ន្ធទៅនឹងការកំណត់អំពីជនក្បត់ ហើយនិងការសម្រេចថាសម្លាប់អ្នកណាម្នាក់នោះ?

**ឆៈ** ខ្ញុំអត់បានយល់បញ្ហានេះទេ។

[១១:០៨:២៨]

**សៈ** ចំពោះគោលនយោបាយថ្មីនោះ លោកនិយាយថាត្រូវមានការព្រមព្រៀងពីថ្នាក់ប្រាំពីរជាន់ ហើយលោកមិនដឹងអំពីគោលនយោបាយចាស់ទេថា តើមានការសម្រេចពីប៉ុន្មានថ្នាក់ដែរទើបអាចចាប់ខ្លួនមនុស្សនោះ?

**ឆៈ** ខ្ញុំអត់ដឹងគោលនយោបាយពីដើមយ៉ាងម៉េចទេ ស្រាប់តែឃើញគេមកចាប់ៗអ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរសំណួរមួយចំនួនទៀត ដើម្បីទទួលការបានបញ្ជាក់ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន? នៅក្នុងសវនាការលោកបានបញ្ជាក់ថា ទាំង ខៀវ សំផន និង ប៉ង់ គឺកាន់មុខងារនៅមន្ទីរ៨៧០។ យើងទាំងអស់គ្នាដូចជាមិនច្បាស់ទេថា តើភាពខុសគ្នារវាងការទទួលខុសត្រូវរបស់បុគ្គលទាំងពីរនាក់នេះនៅក្នុងមន្ទីរ៨៧០ នោះ យ៉ាងម៉េចដែរនៅពេលគេទាំងពីរធ្វើការជាមួយគ្នា?

[១១:០៩:៣៧]

**ឆ៖** សូមបញ្ជាក់ថា ទទួលខុសត្រូវនោះ វាមិនជាត្រឹមត្រូវប៉ុន្មានទេ វាគ្រាន់តែថាឃើញនៅក្នុងមន្ទីរនុំងហើយ ខ្ញុំមើលឃើញមន្ទីរហ្នឹងហើយ ខ្ញុំយល់ឃើញថាទទួលខុសត្រូវទៅ។ ពាក្យថា “ទទួលខុសត្រូវទៅ” ប៉ុន្តែបើខ្ញុំពិចារណាមកថា ទេ ពាក្យនេះមិនទទួលខុសត្រូវទេពាក្យទៅជួយ។ ខ្ញុំបានកែតម្រូវពីមុនមកហើយ ជួយ។ ជួយធ្វើនេះ ជួយធ្វើនោះ។ ឯពាក្យថាទទួលខុសត្រូវហ្នឹង ដូចថាវាជាប់ទៅពាក្យនយោបាយដូចវាធូន់ពេក។ ខ្ញុំមើលថាទៅជួយ។

ហើយពេលនោះទៀត ក៏គេមិនបានប្រាប់ខ្ញុំថា អ្នកនេះ ឋានៈនេះ ឋានៈនោះអីឲ្យខ្ញុំដឹងទេ អត់បានដឹងទេ។ ខ្ញុំនិយាយថា ទទួលខុសត្រូវៗអ៊ីចឹងទៅ។ នេះទីមួយ។

[១១:១០:៤០]

ទីពីរបង ខៀវ សំផន នៅក្នុងមន្ទីរនោះ ខ្ញុំពាក្យថា និយាយពាក្យថា ទទួលខុសត្រូវនោះ ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង មិនដឹងជាមានភារកិច្ចអីទេ ៨៧០ ក៏មិនដឹង តែក្នុង៨៧០ ហើយ គេហៅថា ៨៧០ទាំងអស់គ្នាហើយ ជាទូទៅជំនាន់នោះ។ មន្ទីរ៨៧០ អ្នកណាក្នុងមន្ទីរ៨៧០ ហ្នឹងគឺសុទ្ធតែ៨៧០ តែទាំងអស់ហ្នឹង។ អាហ្នឹងទម្លាប់និយាយ។ ដូច្នេះយកពាក្យទម្លាប់មកនិយាយ យកមកជាពាក្យបានការក្នុងពេលឥឡូវនេះ ខ្ញុំឃើញថាក៏វា វាមិនសត្យានុម័ត វាមិនយុត្តិធម៌ដែរ។ ដូច្នេះ ខ្ញុំនិយាយពាក្យថា ជួយទៅ ជំនួយការអីអ៊ីចឹងទេ។ ឃើញគាត់ជួយតែរឿងកំប៉ិកកំប៉ុក ចែកនេះចែកនោះតែប៉ុណ្ណោះ។

[១១:១១:៥០]

**ស៖** ចំពោះអ្នកទាំងពីរនេះ តើអ្នកណាទទួលខុសត្រូវកិច្ចការខាងក្នុង និងខាងក្រៅនោះ?

**ឆ៖** អ្នកទាំងពីរនោះមានឈ្មោះអី?

**ស៖** ខ្ញុំត្រឡប់មកសំណួរដំបូងនោះ គឺខ្ញុំសួរអំពី ខៀវ សំផន និង ប៉ង់។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើមានអ្នកណាធ្វើការខាងកិច្ចការសម្រាប់ខាងក្រៅ ហើយអ្នកណាធ្វើការសម្រាប់ខាងក្នុងដែរឬទេ?

**ឆ៖** លោក ខៀវ សំផន នៅតែខាងក្នុងភាគច្រើន។ ខ្ញុំទៅជួបម្ដងម្កាល ឃើញតែគាត់នៅខាងក្នុងទេ ហើយខាងក្រៅគាត់ទៅណាៗខ្ញុំមិនដឹងទេ។ លោក ប៉ង់ បានទៅខាងក្រៅ ឃើញជិះម៉ូតូទៅនេះទៅនោះ។ ឃើញតែតាមផ្លូវទេ។

**ស៖** ដូច្នេះ លោកបានជួប ខៀវ សំផន នៅមន្ទីរ៨៧០ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកបានជួបគាត់ទេនៅពេលដែលគាត់មកក្រសួងការបរទេសម្ដងម្កាលនោះ? ពីព្រោះកាលពីថ្ងៃចន្ទនោះលោកបានបញ្ជាក់ថា គាត់បានមកក្រសួងការបរទេស ពាក់ព័ន្ធនឹងរឿងបញ្ហាសំបុត្រកប៉ាល់ហោះ។ អ៊ីចឹងលោកធ្លាប់ឃើញគាត់ទេនៅពេលនោះ-- ធ្លាប់ជួបគាត់ទេ?

[១១:១៣:៤៨]

**ឆ៖** បាទ ធ្លាប់ជួបគាត់។ ប៉ុន្តែខ្ញុំមិនប្រាស្រ័យទាក់ទងនឹងគាត់ទេ។ គាត់ជួបខាងផ្នែកបញ្ហាជនទាក់ទងខាងបរទេស។

**ស៖** តើ ខៀវ សំផន មកក្រសួងការបរទេសដើម្បីទទួលបានព័ត៌មាន ដើម្បីគាត់យកទៅធ្វើជាសុន្ទរកថាទេ?

**ឆ៖** រឿងនេះខ្ញុំមិនដឹងច្បាស់លាស់ទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាងលេ៖**

លោកប្រធាន ខ្ញុំចង់បង្ហាញនូវចម្លើយ៣០ របស់សាក្សីនៅក្នុងឯកសារ D369/36។ សូមការអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញនៅលើអេក្រង់ ហើយសូមជូនឯកសារនេះទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១១:១៥:២៨]

**ស៖** ចម្លើយទី៣០។ សូមអរគុណ។ សំណួរបានសួរថា "ពេលដែលលោក ខៀវ សំផន មកកាន់ការជំនួស តើគាត់ធ្វើការអ្វីខ្លះ? លោកបានឆ្លើយនៅចម្លើយទី៣០ថា "គាត់មករកព័ត៌មាននិងសួរថាតើគួរលើកបញ្ហាអ្វីនៅពេលធ្វើសុន្ទរកថា?" តើលោកមាននៅចងចាំទេ នូវចម្លើយដែលលោកបានឆ្លើយនេះ? ហើយលោកមានអីត្រូវបន្ថែមទេ?

**ឆ៖** បាទ នៅចងចាំ។ អត់មានអីជាចម្លើយជាបន្ថែមទេ។

**សៈ** តើគាត់មកសួររកព័ត៌មានហ្នឹងនៅពេលដែល អៀង សារី មានវត្តមានដែរឬទេ?

**ឆៈ** ពេលគាត់មកដូចជា មិនបានមានវត្តមានបង អៀង សារី ទេ។

[១១:១៦:៥៧]

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកក្រោយបន្តិចវិញ គឺចង់និយាយអំពីរយៈពេលមុនខែមេសា ៧៥ គឺពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន។ មុនខែមេសា ឆ្នាំ១៩៧៥ តើ ខៀវ សំផន មានតួនាទី ឬក៏មុខងារអ្វីដែរ នៅក្នុងបដិវត្តន៍? គឺនៅពេលដែលគាត់ធ្វើការនៅក្នុងព្រៃតស៊ូនោះ តើគាត់ធ្វើការសម្រាប់រណ-- ដើម្បីឱ្យរណសិរ្ស ឬក៏ធ្វើការឱ្យបក្សកុម្មុយនីស្តកម្ពុជា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសូមជំទាស់ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ពីព្រោះថាជាសំណួរនេះជាសំណួរនាំមុខ។ សូមឱ្យគាត់រៀបចំសំណួរឡើងវិញលោកប្រធាន។

[១១:១៨:០៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាងឯល៖**

**សៈ** ដើម្បីកុំឱ្យខាតពេល ខ្ញុំចង់សួរសំណួរទីមួយ ដើម្បីឱ្យដឹងថាតើលោកមានដឹងទេអំពីតួនាទីនិងមុខងារពិតប្រាកដរបស់លោក ខៀវ សំផន នៅក្នុងបដិវត្តន៍មុនខែមេសា ឆ្នាំ៧៥?

**លោក សាឡុត បាន៖**

**ឆៈ** ខ្ញុំអត់បានដឹងទេ។

**សៈ** កាលពីម្សិលមិញ លោកបានរក្សានូវខ្លឹមសារចម្លើយទី៣៩ នៃឯកសារ D369/36។ ជាពិសេសលោកបាននិយាយថា គឺលោកបាននិយាយនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។ យើងនិយាយអំពី ខៀវ សំផន។ “នៅពេលចូលព្រៃដំបូងគាត់ធ្វើការក្នុងមន្ទីរមួយ ហៅថាមន្ទីររណសិរ្ស។ មិនមែនជាមន្ទីរគណៈមជ្ឈិមទេ ប៉ុន្តែគាត់តែងតែចុះឡើងៗមកមន្ទីរមជ្ឈិម”។ លោកបាន-- ម្សិលមិញនេះលោកបានរក្សាចម្លើយនេះ។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ ថា

មន្ទីររណសិរ្សនេះ មានន័យថា យ៉ាងម៉េចដែរ? គឺជាមន្ទីរអ្វី?

[១១:១៩:៥៣]

**ឆ៖** ពេលនោះ ខ្ញុំទទួលខុសត្រូវខាងការពារ។ ខ្ញុំដឹកនាំទៅធ្វើមន្ទីរ។ មានបងប្អូនប្រហែលជាប្អូនដប់នាក់អីអឺចឹងទៅ ហើយគេថា មន្ទីរអីៗ គេថា មន្ទីររណសិរ្សៗ ខ្ញុំក៏ថាតាមគេអឺចឹងទៅ មន្ទីររណសិរ្ស បាទ។

**ស៖** តើវាមានទំនាក់ទំនងជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ? ឬក៏គ្រាន់តែជាមន្ទីរសមរភូមិមុខនោះ?

**ឆ៖** រចនាសម្ព័ន្ធ ឬការទាក់ទងរវាងរណសិរ្ស និងរណសិរ្ស បុគ្គលណាៗ ខ្ញុំអត់បានដឹងទេ។ ការងារអ្នកណា អ្នកណាដឹង ដឹងតែការងារឯងបានហើយ។ នេះជាទ្រឹស្តីដើម្បីការពារសន្តិសុខរួម។

[១១:២១:៤៥]

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាអ្នកណាគេខ្លះធ្វើការនៅមន្ទីររណសិរ្សនេះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់។ ប៉ុន្តែដូចជា ឥស្សរជនសំខាន់ៗខ្លះ ដូចជា ភ្លេចឈ្មោះទៅទៀត ហើយនិងនែ ព្រះរាជបុត្ររបស់សម្តេចឪខ្លះ ខ្ញុំក៏ភ្លេចឈ្មោះទៅទៀត។ សូមទោសបាទ។

**ស៖** តើទីតាំងមន្ទីររណសិរ្ស និងមន្ទីរមជ្ឈិមនៅឯណាដែរ?

**ឆ៖** ខ្ញុំដឹងរួមៗថា នៅព្រំដែនកំពង់ចាម កំពង់ធំ។ ឯមន្ទីររណសិរ្សនៅឆ្ងាយពីមន្ទីរខាងមជ្ឈិម។ ត្រូវធ្វើដំណើរប្រហែលពីរថ្ងៃបានដល់។

**ស៖** សូមអរគុណ។ ខ្ញុំចង់ត្រឡប់មកចំណុចដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងផ្ទះ ឬក៏ខ្ទមរបស់ គឹម នៅពេលដែលលោកនៅទីនោះ។ លោក គឺជាអង្គរក្ស ឬកងការពាររបស់ ប៉ុល ពត។ នៅពេលដែលលោកទៅឃុំពាម នៅខាងលិចឧដុង្គ លោកបានអមដំណើរ ប៉ុល ពត តើលោកមានធ្លាប់ឃើញ ខៀវ សំផន ទេ? ធ្លាប់ឃើញគាត់មកកន្លែងហ្នឹងទេ? ហើយធ្លាប់ឃើញគាត់ចូលរួមក្នុងកិច្ចប្រជុំអីដែរទេ?

[១១:២៤:៣៣]

**ឆ៖** សូមទោសខ្ញុំមិនច្បាស់អី គឹម, គឹម ហ្នឹងយ៉ាងម៉េច គឹម? ឈ្មោះ គឹម អំមិញ លោកថាឈ្មោះ គឹម?

**ស៖** ខ្ញុំចង់និយាយអំពីទីតាំងមួយដែលមានឈ្មោះថា ឃុំពាម គឺថានៅខាងលិចឧដុង្គគឺកន្លែង

នុ៎ងហើយ ដែលលោកបានស្ថិតនៅៗមុនពេលវ៉ៃចូលភ្នំពេញជាមួយ ប៉ុល ពត។ ខ្ញុំចង់ថាតើនៅឃុំពាមនោះ ខៀវ សំផន ធ្លាប់មកទេ? ហើយបន្ទាប់ថាតើធ្លាប់-- គាត់ធ្លាប់ចូលរួមកិច្ចប្រជុំអីនៅទីនោះដែរឬទេ?

**ឆ៖** ខ្ញុំឃើញបង ខៀវ សំផន ធ្លាប់នៅ ហើយការប្រជុំមិនមានជាការប្រជុំអីធំដុំទេ។ ខ្ញុំឃើញគាត់ជួយធ្វើបញ្ជីៗហ្នឹងប្រហែលបញ្ជីគ្រាប់រំសេវអីហើយតាមមើល ធ្វើតែបញ្ជីទេ។ ឯការប្រជុំក៏ខ្ញុំមិនដឹងប្រជុំអីដែរ បាទ។

**ស៖** តើលោក ខៀវ សំផន មានការទទួលខុសត្រូវខាងផ្នែកយោធាអីដែរទេ នៅមុនវ៉ៃចូលភ្នំពេញ?

**ឆ៖** មិនមានទេ។

**ស៖** ហេតុអីបានជាគាត់ទៅជាទទួលខុសត្រូវខាងបញ្ជីគ្រាប់រំសេវទៅវិញនោះ ប្រសិនបើគាត់អត់មានតួនាទីអីខាងយោធាទេ?

[១១:២៦:៣៤]

**ឆ៖** តាមខ្ញុំយល់ ក៏ទាញគាត់ទៅ គាត់ចេះលេខចេះអក្សរ ហើយខ្ញុំវាមិនសូវចេះធ្វើបញ្ជីអីៗហ្នឹង គឺថាមកជួយសិនមក ជួយគ្នាសិនមក ជួយគ្នាទៅវិញទៅមក គេអត់ប្រកាន់ទេ ជំនាន់នុ៎ងគេអត់ប្រកាន់ទេ ឲ្យតែការងារអីធ្វើបាន ធ្វើនុ៎ងហើយ។

**ស៖** តើលោកមានធ្លាប់ឃើញ នួន ជា មកកន្លែងដែលហ្នឹងដើម្បីមកជួយ ប៉ុល ពត ដែរឬទេគឺថានៅក្នុងឃុំពាមនុ៎ង?

**ឆ៖** ពេលនោះខ្ញុំដូចធ្លាប់ឃើញម្តងម្កាលដែរ មិនមែនថាអត់ទេ។

**ស៖** លោកដឹងទេថា មានមន្ទីរ ឬក៏មានផ្ទះផ្សេងទៀតរបស់បក្ស ឬក៏មូលដ្ឋានយោធាផ្សេងទៀតនៅជិតឧដុង្គ នៅដើមឆ្នាំ៧៥ រហូតដល់ការវាយយកភ្នំពេញបាន?

**ឆ៖** គ្មានខ្ទមត្រង់ណាទៀតទេ មានតែមួយ។

[១១:២៨:១៥]

**ស៖** នៅក្នុងខ្ទមហ្នឹង តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការឲ្យ ប៉ុល ពត?

**ឆ៖** មានខ្ញុំនៅជាប្រចាំ មានអ្នកដាំបាយម្នាក់ មានការពារពីរនាក់តែប៉ុណ្ណោះ។ ខ្ញុំសូមជម្រាបទីនោះមិនមានព្រៃទេ ព្រៃរបោះ។ បើសិនជាប៉ានធ្វើអីធំដុំ ខ្មោចហើយ អាទ្រង់ជ្រួកមកលេងអស់ហើយ។

ដូច្នេះស្រាល ហើយស្ងាត់ ហើយចល័តជាប់។

**ស៖** តើ ជាម ដែលក្រោយមកធ្វើការជាអនុរបស់លោកនៅក្រសួងការបរទេសនោះ តើ ជាម មានធ្វើការនៅកន្លែងហ្នឹងដែរទេជាមួយលោក នៅជិត ប៉ុល ពត នោះ?

[១១:២៩:៣៤]

**ឆ៖** ជាម ទៅម្ដងម្កាលដែរ ធ្វើជានីរសារ រកត្រី រកសាច់ ផ្ដល់ជូនខ្មមនោះ។

**ស៖** តើគាត់ធ្វើជានីរសាររបស់អ្នកណាដែរ?

**ឆ៖** គាត់ធ្វើនីរសាររបស់មន្ទីរ៨៧០។

**ស៖** នៅពេលដែល ប៉ុល ពត និងអ្នកដឹកនាំផ្សេងទៀត ចេញដំណើរទៅទីក្រុងភ្នំពេញ លោកបាននិយាយថា លោកបានបន្ដយាមផ្ទះនោះ នៅពេលដែលពួកគាត់អវត្តមាន? តើមានសារៈសំខាន់អ្វី ក្នុងការយាមផ្ទះនោះ ក្នុងខណៈដែលពួកគាត់បានចេញទៅហើយ ហើយជាពិសេសគឺថាគ្រាន់តែជាខ្ទមតែប៉ុណ្ណោះ?

**ឆ៖** សារៈសំខាន់ដែលខ្ញុំយាម គឺនៅជុំវិញខ្ទមមានកប់គ្រាប់ សម្រាប់ប្រយុទ្ធនឹងខ្មាំង។

**ស៖** បាទ សូមអរគុណ ខ្ញុំយល់។ ទាក់ទងទៅនឹងការដណ្ដើមបានទីក្រុងភ្នំពេញ លោកបាននិយាយថា លោកបានឮទាហានបាននិយាយពីការដែលចារកម្មបានចូលទីក្រុងភ្នំពេញរាប់ពាន់នាក់ ហើយពួកគេបានធ្វើ ហើយពួកគេបានធ្វើសកម្មភាពវិទ្ធង្សនា ហើយតើលោកបានឮទាហានទាំងអស់នេះនិយាយអំពីរឿងចារកម្ម កិច្ច-- គិញទាំងអស់នេះ ដែលធ្វើចារកម្មហ្នឹង នៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនមែនជាអ្នកស៊ើបការណ៍ខាងចារកម្មទេ។ ខ្ញុំមិនអាចស៊ើបអីដឹងថាគិញហ្នឹង នៅទីណាៗទេ។ ក៏ប៉ុន្តែជាច្បាប់ តាមខ្ញុំយល់ខ្លះៗទេ មកដល់ឥឡូវទេ បានខ្ញុំយល់ ពីដើមខ្ញុំមិនយល់ទេ។ ជាច្បាប់ដែលមើលទូរទស្សន៍មើលស្អីទៅ គឺចារកម្មហ្នឹង អីរ៉ុបហ្នឹងពូកែណាស់។

ឥឡូវវាចេះធ្វើកប៉ាល់ហោះទៀតណោះ អត់មានមនុស្សជិះទៀត ហើយជំនាន់ខ្ញុំហ្នឹង អត់មានទេទូរស័ព្ទ។ សូមលោកជ្រាប បើលោកសួរអ៊ីចឹង វាមិនយល់ពីរឿងពីដើមរបស់ខ្ញុំទេ។ សូមទោសលោក ខ្ញុំប្រតិកម្មបន្តិច។ ខ្ញុំសូមអភ័យទោសបាទ។

[១១:៣៣:០៦]

**ស៖** នៅពេលដែលលោកឮថា មានគិញដែលចូលមកទីក្រុងភ្នំពេញរាប់ពាន់នាក់នេះ។ តើពេលនោះ លោកបានឮដែរឬទេ អំពីមូលហេតុដែលទីក្រុងត្រូវតែជម្លៀសមនុស្សចេញនោះ?

**ឆ៖** ខ្ញុំដឹងថា មូលហេតុជម្លៀសចេញប្រជាជនចេញពីទីក្រុង គឺមូលហេតុពីរឿងហ្នឹងឯង។ គឺថាច្បាស់ជាមាននយោបាយចាញ់របស់លោក លន់ នល់ ហើយ។ នយោបាយចាញ់នេះ គឺដើម្បីស្តារឲ្យឈ្នះវិញ គឺត្រូវប្រើចារកម្មសម្ងាត់ បង្កប់នៅក្នុងក្រុង។

**ស៖** តើការជម្លៀសនោះ ស្ថិតនៅក្នុងក្របខ័ណ្ឌគោលនយោបាយបក្សដែលសំដៅ បង្កើតឲ្យមានភាពស្មើគ្នា ហើយនិងការកម្ទេចវណ្ណៈដែលមានបុព្វសិទ្ធ ដូចជាវណ្ណៈសក្តិភូមិ ឬក៏មូលធនជាដើម។ តើលោកបានឮគេនិយាយអំពីបញ្ហានេះដែរឬទេ?

[១១:៣៤:៤៨]

**ឆ៖** ខ្ញុំមិនឮពាក្យដែលលោកនិយាយហ្នឹងទេ។ លោកនិយាយនេះគឺថា សួរខ្ញុំខាងទស្សនវិជ្ជាវិញហើយ។ គឺខ្លាំងមក ត្រូវធ្វើម៉េចៗ មានវិធានវិធីអីយ៉ាងម៉េចៗ គឺថាខ្ញុំពិបាកឆ្លើយ។

**ស៖** បាទសូមអរគុណ។ ឥឡូវខ្ញុំសូមនិយាយឲ្យជាក់លាក់ ហើយខ្ញុំនិយាយអំពីក្រសួងការបរទេស ហើយនិងរយៈពេលពីខែមេសា ៧៥ ដល់ខែមករា ៧៩។ តើនៅក្នុងរយៈពេលនេះក្រសួងការបរទេសបានអំពាវនាវឲ្យបញ្ញាជនដែលនៅបរទេស ឲ្យត្រឡប់ចូលមកប្រទេសកម្ពុជាវិញ។

**ឆ៖** សូមលោកបញ្ជាក់ ៧៥, ៧៩ អីម៉េច? ខ្ញុំឮដូច ៧៥, ៧៩ អីចឹងអី?

**ស៖** បាទត្រូវហើយ។ ខ្ញុំចង់ដឹងថាតើនៅក្នុងរយៈពេលហ្នឹងគឺថា ជាពិសេសគឺដំបូងនៃរយៈនៅពេលដែលថា ក្រសួងទើបនឹងចាប់ផ្តើមនោះ តើមានការអំពាវនាវហៅបញ្ញាជនដែលរស់នៅបរទេសនោះឲ្យត្រឡប់ចូលមកប្រទេសកម្ពុជាដើម្បីជួយកសាងប្រទេសវិញដែរឬទេ?

**ឆ៖** នេះមុន៧៥ ឬ?

**ស៖** ទេៗ គឺថានៅពេលដែលក្រសួងការបរទេសនោះចាប់ផ្តើមដំណើរការហើយ។ តើក្រសួងការបរទេសដែលលោកធ្វើការនោះ ជាមួយនឹងលោក អៀង សារី តើក្រសួងនេះបានធ្វើការអំពាវនាវទៅដល់បញ្ញវន្តដែលរស់នៅបរទេសដែរឬទេ?

**ឆ៖** តាមខ្ញុំដឹងដូចគ្មានឮអំពាវនាវអីទេ។ គឺតាមដែលនរណាស្ម័គ្រចិត្តមក គឺគេមក។

[១១:៣៧:៤២]

**ស៖** បាទ លោកបានលើកឡើងកាលពីដើម គឺកាលនៅថ្ងៃចន្ទនោះ លោកបានធ្វើដំណើរជាមួយលោក អៀង សារី ម្តងទៅសហរដ្ឋអាមេរិកដើម្បីចូលរួមសមាជនៅអង្គការសហប្រជាជាតិ។ តើនៅក្នុងឱកាសនៃការធ្វើដំណើរនោះ ឬក៏ពេលធ្វើដំណើរមួយទៀត លោកបានឈប់នៅទីក្រុងប៉ារីសដើម្បី

ជួបជនជាតិកម្ពុជាដែលរស់នៅប្រទេសបារាំង។ តើដែលធ្លាប់មានអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ធ្លាប់មានអ៊ីចឹង។

**ស៖** តើការធ្វើបែបនេះ កើតមានឡើងតែម្តងទេ ឬក៏ច្រើនដង?

**ឆ៖** មានតែម្តង។

[១១:៣៨:៥៤]

**ស៖** នៅពេលដែលលោកទៅទីក្រុងប៉ារីស ដើម្បីជួបជនជាតិកម្ពុជាដែលរស់នៅទីនោះ។ តើ អៀង សារី បាននិយាយអ្វីខ្លះទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ? តើគាត់បានផ្តល់ព័ត៌មានអ្វីខ្លះទៅជនជាតិខ្មែរដែលនៅទីនោះ ទាក់ទងទៅនឹងអ្វីដែលកើតមានឡើងនៅក្នុងប្រទេស?

**ឆ៖** ខ្ញុំអត់បានដឹងទេ ខ្ញុំអ្នកមើលវ៉ាលិស។

**ស៖** បើតាមដែលលោកដឹង តើមានបញ្ញាជន ឬក៏និស្សិតខ្មែរដែលនៅបរទេសប៉ុន្មាននាក់ដែលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ មកដោយខ្លួន-- តែម្នាក់ឯង ឬក៏ជាមួយគ្រួសាររបស់គាត់ ក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ដើមខែមករា ឆ្នាំ១៩៧៩?

**ឆ៖** អស់ហើយ។

**ស៖** លោកអាចឆ្លើយម្តងទៀតបានដែរឬទេ លោកខ្ញុំ ចម្លើយរបស់លោកអម្បាញ់មិញនេះ អ្នកបកប្រែស្តាប់អត់ឮទេ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯលៈ**

ឥឡូវនេះ ខ្ញុំសូមរំឭកឲ្យលោកចងចាំ នៅក្នុងឯកសារ D91/14 ដែលខ្ញុំសូមអនុញ្ញាតបញ្ចាំងជាភាសាខ្មែរ គឺ 00204097 ហើយនិងជាភាសាបារាំង 00503936។ មានករណីពិសេស គឺថាពុំមានការបកប្រែជាភាសាអង់គ្លេសទេ។ មានខ្វះមួយផ្នែកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ ជាភាសាអង់គ្លេស។ ហើយសំណួរក៏ពុំមានការបកប្រែ ចម្លើយក៏មិនមានការបកប្រែដែរ។ គ្រាន់តែជាឃ្លាដ៏ខ្លីមួយតែប៉ុណ្ណោះ។ ខ្ញុំសូមរំឭកឃ្លានេះទៅសាក្សីលោកប្រធាន។

[១១:៤២:០២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯលៈ**

បាទ សំណួរនោះ ទាក់ទងទៅនឹងការត្រឡប់ចូលនូវបញ្ញវន្ត ហើយនិងនិស្សិតមកប្រទេសកម្ពុជា

វិញ។ លោកនិយាយថា មានមនុស្សរាប់វាយនាក់ដែលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ។ តើលោកចាំទេថា លោកបាននិយាយយ៉ាងដូច្នេះ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ចាំ។

**ស៖** តើអ្នកណាអ្នកទទួលបន្ទុកក្នុងការទទួលបញ្ញាជនទាំងអស់នេះ នៅពេលដែលពួកគាត់មកដល់ព្រលានយន្តហោះពោធិ៍ចិនតុង?

**ឆ៖** ដល់ព្រលានយន្តហោះពោធិ៍ចិនតុង មានខាងផ្នែកយោធាពោធិ៍តុងគេអ្នកទទួល មើលខុសត្រូវនៅពោធិ៍តុង។ មកដល់ក្រុង ខាង ប៉ង់ ឯខាងសម្ភារៈ គេយកមកទុកនៅក្រសួងការបរទេស។

[១១:៤៣:២៨]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំនិយាយអំពីទំព័រដដែល គឺថា D91/14 បាទ មិនមានលេខ ERN ជាភាសាអង់គ្លេសដដែល គឺមានតែជាភាសាបារាំង គឺថា 00503936 ហើយជាភាសាខ្មែរ គឺថា 00204097។ ខ្ញុំគិតថាលោកមានឯកសារនេះហើយ ខ្ញុំសូមអានអ្វីដែលលោកបានឆ្លើយ។ នេះគឺជាសំណួរទាក់ទងទៅនឹងតួនាទីរបស់លោក អៀង សារី ដែលបានធ្វើការអំពាវនាវទៅនិស្សិតខ្មែរនៅបរទេស។ ចម្លើយរបស់លោក ដូចតទៅនេះ "គាត់បានអំពាវនាវទៅឲ្យបញ្ញាជន និងនិស្សិតនៅបរទេសដើម្បីឲ្យត្រឡប់មកជួយកសាងប្រទេសវិញ។ នេះអ៊ីចឹងមែន កាលណោះខ្ញុំមានតួនាទីជាអ្នកទទួលបន្ទុកទទួលពួកគាត់នៅពោធិ៍តុង មាននិស្សិតជាចំនួនជាច្រើនរយនាក់។ បញ្ញវន្តទាំងនោះបានទៅរស់នៅមន្ទីរបឹងត្របែកដែលមានឈ្មោះ ហ៊ីង អ៊ុន ជាអ្នកគ្រប់គ្រង"។ ហើយលោកបានបញ្ជាក់ផងដែរថា ប៉ង់ក៏ជាអ្នកទទួលខុសត្រូវដែរ។ តើឥឡូវនេះ លោកច្បាស់ដែរឬទេនូវ-- អំពីចម្លើយរបស់លោកហ្នឹង ហើយលោករក្សាចម្លើយនេះរបស់លោកដែរឬទេ?

[១១:៤៥:០៤]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់បន្តិច ពាក្យថា "អំពាវនាវ" នេះពាក្យអាឌែងគេហៅថា ពាក្យនិយាយហ្នឹង "អំពាវនាវ" ប៉ុន្តែបើតាមខ្ញុំចាំនៅពេលនោះគឺថាគ្រាន់តែថា បងប្អូនណេះ! បងប្អូនដាក់ស្តែងហ្នឹងឃើញថាបងប្អូនចង់ៗចូលស្រុក។ ប៉ុន្តែម្នាក់ពីរនាក់ទេ មកនិយាយ។ លោកប្រាប់ទៅវិញថា អ៊ូ! ពិបាកណាស់កុំអាលអីអ្នី! កុំអាលទៅអី! អ្ហេ! គាត់ថាទេ លំបាកម៉េចក៏ដោយក៏ទៅដែរ។ នេះ ខ្ញុំចង់ថា "អំពាវនាវ" ហ្នឹងរបៀបអ៊ីចឹងណ៎ះ! រូបភាពអំពាវនាវហ្នឹងវាអ៊ីចឹងទេ។ មិនមែនដាក់មីក្រូ ដាក់អីទេ

បាទ។ មីក្រូមីអី ឬបោះអាខែងគេហៅថា កាសែត ឬក៏ឃោសនាអីធំដុំទេ អត់ទេ។ ដូច្នេះ ខ្ញុំយល់ឃើញថា នរណាចង់មកក៏មកទៅ ប៉ុន្តែពិបាកបន្តិចហើយ មិនទាន់រៀបចំអីស្រួលបួលទេ។ និស្សិតអស់ទាំងនោះ ខ្លះថា ទេមករួម ណ៎ះ!មករួម។ ដូច្នេះមកដល់-- អ្នកខ្លះមកហ្នឹងទៅតាមកប៉ាល់ហោះអីចឹងទៅ ការទាក់ទងអីជាមួយ ប៉ង់ ដូចខ្ញុំបាននិយាយលើកមុនអីចឹង។

[១១:៤៦:៣៣]

**ស៖** បាទសូមអរគុណ។ តើកាលនោះ គេយក*ប៉ាស្ព័រ*របស់បញ្ញាជនទាំងអស់នោះធ្វើអ្វីនៅពេលដែលគាត់មកដល់ព្រលានយន្តហោះហើយនោះ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនដឹងទេ។ ខាងសន្តិសុខ ខាងយោធានៅពោធិ៍ចិនតុងពេលនោះ។ គេដឹកជញ្ជូនទៅណាក៏ខ្ញុំមិនដឹង។ ប៉ុន្តែសម្ភារៈរបស់គេ គេយកមកទុកនៅក្រសួងការបរទេស មានអីៗមិនដឹងទេ។ អត់ប៉ានផែកមើលទេ។ ទុក។

[១១:៤៧:៥៧]

**ស៖** ហេតុអ្វីក៏យកអីវ៉ែអីវ៉ាន់របស់គាត់ជាបុគ្គលទៅវិញនៅពេលដែលគាត់មកដល់នុ៎ង?

**ឆ៖** ខ្ញុំមិនដឹងហេតុផលអីដែរ ឃើញតែគេយមកទុកនៅនុ៎ង។ គេប្រាប់ថា រក្សាឲ្យស្រួល ខាងខ្ញុំមិនប៉ានបើកអីមើលទេ។

**ស៖** បាទ ខ្ញុំទើបតែអានចម្លើយរបស់លោកអម្បាញ់មិញហ្នឹង ដែលថានៅក្នុងចម្លើយហ្នឹងលោកថា បញ្ញាជនទាំងអស់នោះបានបញ្ជូនទៅបឹងត្របែកក្រោមការទទួលខុសត្រូវរបស់លោក ហ៊ឹងអ៊ុន។ តើបញ្ញាជនទាំងអស់នោះ អាចឆ្លងផុតពីការបញ្ជូនទៅបឹងត្របែកដោយមិនចាំបាច់ឆ្លងកាត់តាមក្រសួងការបរទេសដែរឬទេ?

**ឆ៖** តាមខ្ញុំចាំនៅពេលនោះ អត់មានឆ្លងកាត់ក្រសួងការបរទេសទេ។

**ស៖** ទាក់ទងនឹងបញ្ញាជនដែលលោក អៀង សារី បានជួបពីមុននៅប្រទេសចិន តើមានអ្នកណាខ្លះដែលបានធ្វើការនៅក្រសួងការបរទេសនៅពេលក្រោយមកដែរឬទេ?

**ឆ៖** ខ្ញុំចាំបានតែម្នាក់ឈ្មោះ អ៊ិន សុភាព តែប៉ុណ្ណោះ។

**ស៖** ហើយអ្នកដែលមិនបានមកធ្វើការនៅក្រសួងការបរទេសហ្នឹង គេបញ្ជូនពួកគាត់ទៅណាវិញទៅ?

[១១:៥០:១៧]

**ឆ៖** ខ្ញុំនិយាយនេះ គឺថាការទាក់ទងដែលផ្ទាល់មុនគេ លោក អ៊ិន សុភាព នេះ។ ដល់គេមកដល់បឹងត្របែកហើយ បានគេចែកលោក ប៉ង់ ហ្នឹងយកមក អ្នកនេះអ្នកនោះ មិនដឹងចែកហ្នឹងចែកតាមការប្រជុំអីយ៉ាងម៉េចៗ ខ្ញុំមិនដឹងទេ។ ដល់មកចូលក្នុងក្រសួងការបរទេស ឃើញម្នាក់ពីរនាក់ យូរៗម្នាក់ពីរនាក់ហ្នឹងចេះតែចូលមក។ តែប៉ុណ្ណឹងទេ។

[១១:៥១:១៦]

**ស៖** បាទ យើងនិយាយ អម្បាញ់មិញនេះ យើងនិយាយពីបឹងត្របែក។ ហេតុអ្វីក៏ចាំបាច់ផ្ញើបញ្ជូនបញ្ញាជនទាំងអស់នោះទៅបឹងត្របែក? តើលោកអាចពន្យល់ពីមូលហេតុបានដែរឬទេ? នេះទៅជារបៀបអប់រំគាត់ឡើងវិញ ឲ្យគាត់បង្ហាញពីការប្រឹងប្រែងរបស់គាត់ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់ដឹងរឿងការងារគេទេ។ ខ្ញុំដឹងតែរឿងការងារខ្ញុំ។

**ស៖** តើលោក អៀង សារី ហើយលោកផ្ទាល់បានទៅបឹងត្របែកដែរទេ? ហើយបើសិនជាធ្លាប់ទៅនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ស្គាល់បឹងត្របែកទេ។ ខ្ញុំស្គាល់បឹងត្របែក តាមខ្ញុំចាំទៅជាមួយបង អៀង សារី នៅពេលប្រហែលជាមិនដល់កន្លះខែទេ យួនចូលស្រុក។

**ស៖** តើមានទំនាក់ទំនងរវាងបឹងត្របែក ហើយនិងក្រសួងការបរទេសដែរឬទេ នៅពេលដែល ប៉ង់ ជាអ្នកដឹកនាំបឹងត្របែក ដោយហេតុថាបញ្ញា-- នៅទីនោះសុទ្ធតែជាបញ្ញាជនដែលធ្វើការនៅកន្លែងនោះ?

[១១:៥៣:២៤]

**ឆ៖** ខ្ញុំមិនបានឃើញការទាក់ទងទេ។

**ស៖** តើអាចមានកម្មាភិបាលនៃក្រសួងការបរទេស ដែលបានចុះទៅដល់បឹងត្របែកដើម្បីបង្រៀន ឬក៏បំពាក់បំប៉នបញ្ញាជនដែលធ្វើការនៅទីនោះ? ហើយមុនពេលដែលបឹងត្របែកបានផ្ទេរមកឲ្យចូលចំណុះនៅក្រសួងការបរទេសវិញ?

**ឆ៖** តាមខ្ញុំចាំអត់មានទេ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី!

[១១:៥៤:២៣]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ប្រហែលគិតគួរសំណួរនេះឡើងវិញ ដើម្បីកុំឲ្យសាក្សីហ្នឹងគាត់ឆ្លើយដោយស្មាន១បែបនេះ។ សូមអរគុណ។

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសួរថាតើជន-- សាក្សីនេះដឹងពីការដែលកម្មាភិបាលមួយចំនួនអាចនឹងទៅបឹងត្របែកនៅពេលដែលបឹងត្របែកនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ នៅឡើយ។ ហើយគាត់ទៅបឹងត្របែកនោះដើម្បីបញ្ចូលមនោគមន៍វិជ្ជា ឬអប់រំបញ្ញាជនទាំងអស់នោះ តើគាត់ដឹងអំពីបញ្ហានេះដែរឬទេ លោកសាក្សី?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមលើកឡើងឆាប់ទេ។ ខ្ញុំពេញចិត្តណាស់ បើសិនណាជាសហព្រះរាជអាជ្ញាគាត់មានការប្រុងប្រយ័ត្នដោយសួរសំណួរឲ្យសាក្សីធ្វើការប៉ាន់ស្មាន១តែប៉ុណ្ណោះ។ ដូច្នេះ ការធ្វើបែបនេះ គឺមិនត្រឹមត្រូវ។ ដូច្នេះគាត់គួរណាស់តែរៀបចំសំណួរឡើងវិញ ហើយគាត់បានអះអាងថានេះ គឺជាអង្គហេតុហើយ។ ដូច្នេះ គាត់កំពុងតែសួរសំណួរនាំមុខរបស់សាក្សីនេះ ដើម្បីឲ្យសាក្សីផ្តល់សក្ខីកម្មតាមរយៈសំណួរនាំមុខនេះហើយ។

[១១:៥៥:៥៥]

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសូមបន្តទៅសំណួរផ្សេងមួយទៀត ពីព្រោះថាខ្ញុំមានពេលវេលាខ្លីណាស់។ នៅពេលដែល អៀង សារី បានទៅបឹងត្របែក តើគាត់បានធ្វើអ្វីខ្លះនៅទីនោះ?

**លោក សាឡូត បាន៖**

**ឆ៖** ដូចខ្ញុំបានជម្រាប ខ្ញុំទៅជាមួយលោកក្នុងពេលដែលមិនលើស-- មិនលើសពីពីរអាទិត្យទេដែលយួនចូលស្រុក។ គាត់ទៅនេះ គាត់ទៅដើម្បីរៀបចំបងប្អូនកុំឲ្យតក់ស្លុត ហើយត្រៀមពេលណាយើងទប់ទល់មិនបាន យើងត្រូវតែជម្លៀស ហើយគាត់បន្ទុកបណ្តាក់ខ្ញុំ ឲ្យខ្ញុំទទួលខុសត្រូវជម្លៀសប្រជាជនអស់នោះ។

**ស៖** តើនៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ តើលោកបានទទួលការណែនាំអំពីលោក អៀង សារី

ក្នុងការជម្លៀសបញ្ជាជនចេញពីបឹងត្របែកដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ គឺអត់មានទេ ទាល់តែគឺថាប្រថុចញ៉ុចណាស់ មើលឃើញសភាការណ៍វៀត-ណាមចូលមកស្រុកខ្មែរប្រហែលជាមួយអាទិត្យជាងមុនហ្នឹង បានគាត់ឲ្យខ្ញុំទៅរៀបរយ។ យីដូចដដែលហើយនេះ។

[១១:៥៨:២០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំនៅសល់សំណួរតែពីរទៀតទេ ក៏ប៉ុន្តែខ្ញុំចង់បង្ហាញ-- សូមអនុញ្ញាតលោកប្រធានបង្ហាញចម្លើយរបស់លោកសាក្សី គឺថាឯកសារ D91/14 នៅទំព័រជាភាសាខ្មែរគឺ 00204097 ហើយជាភាសាបារាំងគឺ 00503936។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បាទ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ពុំមានលេខERN ជាភាសាអង់គ្លេសទេ។ នេះជាផ្នែកមួយដែលពុំមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយគាត់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកសាក្សីទាក់ទងនឹងប្រធានបទនេះ។ គាត់និយាយដូចតទៅនេះ "នៅពេលដែលវៀតណាមជិតមកដល់ លោក អៀង សារី បានឲ្យខ្ញុំប្រមូលផ្តុំបញ្ជាជនទាំងនោះឲ្យឡើងរទេះភ្លើងដើម្បីចេញដំណើរទៅទិសខាងលិច"។ លោកសាក្សី តើលោករក្សាចម្លើយរបស់លោកនេះទេ?

[១១:៥៩:៤៣]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយ។

**ស៖** តើវាមានសារៈសំខាន់អ្វីដែលបញ្ជាជនទាំងអស់នេះត្រូវទៅតាមខ្មែរក្រហម នៅពេលដែលខ្លួនបាក់ទ័ពនោះ រត់ចេញពីទីក្រុងភ្នំពេញ?

**ឆ៖** បញ្ហានេះខ្ញុំទៅអប់រំផ្ទាល់។ គេស្ម័គ្រចិត្តចេញ អត់បង្ខំទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមដកសម្រង់ចុងក្រោយ សូមអនុញ្ញាត។ ដោយសារលោកសាក្សីថា ពុំមានទំនាក់ទំនងរវាងបឹងត្របែកជាមួយនឹងក្រសួង មុនពេលដែលបឹងត្របែកដាក់មកចូលក្នុងចំណុះក្រសួងមុនពេលដែល-- ក្រោយពេលដែល ប៉ង់ បានស្លាប់ទៅ គឺឯកសារ 233/2, ជាភាសាបារាំងលេខERN គឺលេខ 00404454 (ស៊ីក), ជាភាសាខ្មែរ 00357528, ជាភាសាអង់គ្លេសទំព័រទី៤ គឺ 00361011។

បាទ សូមអនុញ្ញាតបញ្ចាំងទំព័រនេះទៅលើអេក្រង់។ សូមអរគុណលោកប្រធាន។

[១២:០១:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សំណួរដែលចោទសួរនោះគឺដូចតទៅនេះ៖ “នៅក្នុងកាលពីអតីតកាល លោក ហ៊ីង អ៊ុន បានគ្រប់គ្រងបឹងត្របែកជាមួយនឹង ប៉ង់ ហើយគាត់ធ្វើការនៅក្នុងផ្នែកជាច្រើន កន្លែងជាច្រើន។ នេះយើងនៅអតីតកាលទេ។ ចម្លើយ៖ លោក ហ៊ីង អ៊ុន ជាបញ្ញាជន ហើយគាត់គ្រង់គ្រងបឹងត្របែកជាមួយលោក ប៉ង់ បើតាមខ្ញុំដឹង មានតែអង្គភាពបឹងត្របែកមួយនេះទេ។ លោក ហ៊ីង អ៊ុន គាត់រាយការណ៍មកក្រសួងការបរទេស។ ចំណែកខាងរដ្ឋបាលលោក ប៉ង់ រាយការណ៍ឲ្យមជ្ឈិម មានទំនាក់-- ដូចជាបញ្ហាចាប់ចង ឬបញ្ហាស្បៀងជាដើម។ លោក ហ៊ីង អ៊ុន ពុំមានសិទ្ធិអ្វីទេ គាត់គ្រាន់តែជាអ្នកសម្របសម្រួលប៉ុណ្ណោះ។ សិទ្ធិខាងនយោបាយ សិទ្ធិខាងចាត់តាំង ក៏អត់មានដែរ”។

ហេតុអីលោក ហ៊ីង អ៊ុន រាយការណ៍ទៅក្រសួងការបរទេសនៅពេលដែលបឹងត្របែកនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ ទេ ហើយក្នុងខណៈដែលលោកនិយាយថា ពុំមានទំនាក់ទំនងអ្វីរវាងច្រាំងចំរេះ ហើយនិងក្រសួង-- អ៎ បឹងត្របែក ហើយនិងក្រសួងការបរទេសនេះ?

[១២:០៣:២៧]

**ឆ៖** បញ្ហានេះ ខ្ញុំដឹងក្រោយដែលយួនចូលស្រុក ខ្ញុំជួបនឹងលោក ហ៊ីង អ៊ុន។ លោក ហ៊ីង អ៊ុន ប្រាប់ខ្ញុំអ៊ីចឹងបាទ។ ឯខ្ញុំពីមុនមកគ្មានទំនាក់ទំនងអី ទាក់ទងនឹងរឿងបឹងត្របែក និងក្រសួងការបរទេសទេ។ ដូច្នេះ ខ្ញុំដឹងក្រោយ ដែលយួនចូលមកទេ បានស្គាល់លោក ហ៊ីង អ៊ុន ច្បាស់នោះបាទ។

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន ដែលបានផ្ដល់ពេលវេលាបន្ថែមឲ្យយើងនៅព្រឹកនេះនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណមេធាវី និងសាក្សី។

ឥឡូវនេះ ដល់សមល្មមនឹងសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកដើម្បី អ៎ សម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសូមឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលកន្លែងសម្រាកសមរម្យសម្រាប់សាក្សី សម្រាកនៅបន្ទប់រៀបចំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ និងមេធាវីប្រឹក្សាមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅរសៀលនេះ នៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០៥:១១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្ដីរបស់ខ្ញុំលះបង់សិទ្ធិរបស់គាត់ មិនចូលរួមក្នុងដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការនេះទេ។ គាត់សូមចូលទៅបន្ទប់ដែលមានបំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បានស្ដាប់-- អង្គុយចុះ!

បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ ស្នើសុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលដំណើរការសវនាការនៅរសៀលនេះ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅ សុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅ

ក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលរសៀលនេះ។

[១២:០៦:១៦]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងរយៈពេលកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ និងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយឲ្យរក្សាទុកលោក នួន ជា ឲ្យនៅក្នុងបន្ទប់ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ តាមកាលវិភាគដែលបានគ្រោងរសៀលនេះ ដល់ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទទួលសិទ្ធិ អាចមានឱកាសក្នុងតាំងសំណួរដេញដោលចំពោះសាក្សី។

អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិ ដើម្បីអាចតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[១៣:៣២:៥០]

សួស្តីលោកសាក្សី។ ពីរថ្ងៃកន្លងមកនេះ ខ្ញុំបានឃើញថា លោកបានបំភ្លឺនូវចំណុចមួយចំនួនយ៉ាងល្អ និងច្បាស់លាស់ជូនអង្គជំនុំជម្រះ។ ដូច្នេះ ថ្ងៃនេះ ខ្ញុំសូមឲ្យលោកជូនបំភ្លឺនូវចំណុចមួយចំនួនទៀតបន្ថែមទៀត ដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ តាមដែលលោកអាចធ្វើបាន។ សូមអរគុណលោកទុកជាមុន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកសាក្សីពីព្រឹកមិញ លោកបានឆ្លើយចំពោះមុខសហព្រះរាជអាជ្ញាថា លោកបានដឹងឮចំពោះសេចក្តីអំពាវនាវរបស់ អៀង សារី ក្នុងការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនកម្ពុជាពីបរទេស។ នៅលើចំណុចនេះ ខ្ញុំចង់បញ្ជាក់ថា តើហេតុអ្វីបានជាខាងលោក នៅពេលដែលបងប្អូននេះ មកដល់វាលយន្តហោះ ព្រលានយន្តហោះពោធិ៍ចិនតុង លោកបានដកហូតប៉ាស្ព័រ និងសម្ភារៈមួយចំនួន?

**លោក សាឡុត បាន៖**

**ឆ៖** បាទរឿងនេះ ដូចខ្ញុំបានជម្រាប។ បងប្អូនមកដល់ព្រលានយន្តហោះ ខាងកងទ័ពនៅ កងទ័ពការពារព្រលានយន្តហោះដកប៉ាស្ព័រ មិនមែនក្រសួងការបរទេសទេ។ ហើយមនុស្សនោះ ក៏មិនបញ្ជូនមកកាន់ក្រសួងការបរទេសដែរ គឺខាងលោក ប៉ង់ គាត់យកទៅណា ខ្ញុំក៏មិនដឹងដែរ។ ខ្ញុំទទួលតែសម្ភារៈជាវ៉ាលិសយកមកទុកនៅក្រសួងការបរទេស។ ខ្ញុំមិនប៉ានបើកមើលទេ សម្ភារៈអស់ទាំងនោះ។

**ស៖** សូមអរគុណលោក។ ហើយពីម្សិលម៉្ងៃទៀត-- សូមទោស! ពីម្សិលម៉្ងៃលោកបានឆ្លើយនៅមុខសហព្រះរាជអាជ្ញាថា លោកជាអ្នកគ្រប់គ្រងបញ្ញាជនទាំងនោះ-- ជាអ្នកគ្រប់គ្រងបញ្ញាជនដែរ តើបញ្ញាជនទាំងនោះ លោកមានដឹងទេថាមកពីប្រទេសណាខ្លះ? ក្រៅពីប្រទេសបារាំង និងប្រទេសអាមេរិក។

**ឆ៖** បាទ ខ្ញុំបានកែតម្រូវពាក្យ "គ្រប់គ្រង" គ្រាន់តែជួយដល់ការងារបងប្អូនដែលមកភ្នំពេញប៉ុណ្ណោះ។ អ្នកដែលមកមានខាងបារាំង ខាងអាមេរិក ខ្ញុំដឹងតែពីរហ្នឹងទេ។ ឯខាងឯណាៗទៀតហ្នឹង ខ្ញុំ

មិនសូវដឹងដែរ បាទ។

[១៣:៣៦:២០]

**ស៖** អរគុណ ចាស! តើលោកបានដឹងទេ បញ្ញាជនដែលមកហ្នឹងមានខាងការទូតទេ?

**ឆ៖** បាទ ខ្ញុំដឹង អ្នកដែលមកហ្នឹង មានខាងការទូតខ្លះដែរ។

**ស៖** សូមអរគុណលោក។ តើលោកមានចាំឈ្មោះទេ អ្នកដែល បញ្ញាជនដែលមកនោះ ដែលជាខាងអង្គការទូត មានឈ្មោះអ្នកណាខ្លះ? លោកមានចាំឈ្មោះទេ ចាស?

**ឆ៖** បាទ ដូចជាលោក តូច ខាំឌឿន, លោក ហោ ណាំហុង តែប៉ុណ្ណឹង។ អ្នកដទៃទៀតមក ខ្ញុំមិនដឹងឋានៈអី បាទដឹងតែពីរនាក់នេះច្បាស់ បាទ។

**ស៖** អរគុណលោក។ តើអ្នកក្នុងចំណោមអ្នកទាំងនោះ តើមានលោក មានឈ្មោះលោក ហ្ងួត សម្បត្តិ និង នរោត្តម ភូរីស្សារា ទេ?

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះ តែមុខមិនស្គាល់ទេ។

**ស៖** អរគុណលោក។ ពេលពួកបញ្ញាជនទាំងនោះ និងអង្គទូតទាំងនោះដែលជាប្រជាជនខ្មែរ ហើយត្រឡប់មកពីបរទេស តើខាងក្រសួងលោក ក្នុងនាមលោកជាអគ្គលេខា តើលោកនាំអ្នកទាំងនោះទៅកាន់ទីកន្លែងណាខ្លះ?

**ឆ៖** ដូចខ្ញុំបានជម្រាប។ ខ្ញុំមិនបាននាំអ្នកទាំងនោះទៅណាទេ។ លោក ប៉ង់ យកទៅ។ បានខ្ញុំនៅក្រសួងការបរទេស ឃើញលោកអស់ទាំងនោះមកដល់ក្រសួង បាន-- ទើបបានខ្ញុំឃើញ។

[១៣:៣៩:១៣]

**ស៖** អរគុណលោក។ តើលោកមានដឹងទេថា លោក ប៉ង់ យកអ្នកទាំងនោះទៅណាដែរ?

**ឆ៖** ខ្ញុំមិនបានដឹងថាលោក ប៉ង់ យកទៅទីណាទេ ក្រោយដែលវៀតណាមជិតចូលមកស្រុកខ្មែរបានខ្ញុំដឹង ថាមានកន្លែងមួយនោះ គឺលោក ប៉ង់ យកទៅដាក់ គឺនៅបឹងត្របែកនេះឯង។ កន្លែងដទៃទៀត ខ្ញុំក៏មិនបានដឹងដែរ។

**ស៖** អរគុណលោក។ ក្រៅពីការយកទៅដាក់នៅបឹងត្របែក តើខាងលោកមានយកទៅដាក់កន្លែងណាផ្សេងទៀតទេ? តើមានចូលធ្វើការនៅក្រសួងការបរទេស ឬនៅក្រសួងផ្សេងទៀតទេ?

**ឆ៖** ខ្ញុំមិនដែលយកបងប្អូនមកពីក្រៅប្រទេសទៅដាក់កន្លែងណាផ្សេងទៀតទេ។ ខ្ញុំទទួលបានតែគេយកមកដាក់ក្នុងក្រសួងការបរទេស។

**ផ៖** អរគុណលោក។ ក្នុងចំណោមបងប្អូនដែលមកពីបរទេស តើនៅក្នុងហ្នឹងលោកចាំទេមានឈ្មោះលោក គាត ឈន់ ទេ? ហើយនិង អ៊ិន សុកាន ទេ?

**ផ៖** បាទ ខ្ញុំបានដឹង។ ខ្ញុំបានស្គាល់លោក គាត ឈន់ និង អ៊ិន សុកាន។

**ស៖** អរគុណលោក។ តើក្រោយមកលោក គាត ឈន់ លោកដឹងទេ ថាលោក គាត ឈន់ បានមកធ្វើការនៅក្រសួងការបរទេសជាមួយលោក?

**ផ៖** បាទ បានដឹង។

[១៣:៤១:៣១]

**ស៖** អរគុណលោក។ តើក្នុងចំណោមបញ្ញាជនទាំងអស់ដែលធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជា? តើលោកមានបានដឹងទេសព្វថ្ងៃនេះ? តើមានអ្នកណាខ្លះដែលនៅរស់?

**ផ៖** ពេលដែលលោកអស់នោះមកភ្នំពេញ ក្រៅពីក្រសួងការបរទេស។ ខ្ញុំមិនដឹងការសុខទុក្ខរបស់លោកអស់ទាំងនោះយ៉ាងណាទេ។ ខ្ញុំដឹងតែពេលដែលខ្ញុំប្រមូលបងប្អូនអស់នោះចេញពីភ្នំពេញព្រាត់ប្រាសគ្នា ខ្ញុំដឹងថាបងប្អូនវេទនា ប៉ុន្តែការព្រាតប្រាសយ៉ាងណាស្លាប់រស់យ៉ាងណាក៏មិនដឹងដែរ។ បែកបាក់គ្នា ខ្លះក៏នៅបានក្នុងស្រុក ខ្លះទៅ ខ្លះក៏ទៅខាងក្រៅប្រទេសខ្លះទៅ!

**ស៖** សូមអរគុណលោក។ ពេលដែលបងប្អូនបញ្ញាជនទាំងនោះមកដល់កម្ពុជា តើលោក និងលោក អៀង សារី បានទៅធ្វើការអប់រំណែនាំ និងពង្រឹងសតិអារម្មណ៍ដល់បងប្អូនទាំងនោះទេ?

**ផ៖** ក្នុងក្របខ័ណ្ឌក្រសួងការបរទេស ខ្ញុំឃើញបង អៀង សារី រួមជាមួយនឹងខ្ញុំដែរ រួមហ្នឹងគឺថាមិនរួមទទួលខុសត្រូវទេ ខ្ញុំនោះ គ្រាន់តែថាឲ្យដឹងថា នេះជាអ្នកគ្រប់គ្រងតែប៉ុណ្ណឹងទេ។ ជាអ្នកទទួលខុសត្រូវអីៗអីចឹងទៅជាមួយគាត់ ក្របខ័ណ្ឌតែនៅក្នុងក្រសួងការបរទេសទេ។ ឯក្រៅក្របខ័ណ្ឌក្រសួងការបរទេស ខ្ញុំមិនដែលឃើញបង អៀង សារី ទៅអប់រំទេ។

[១៣:៤៣:៣១]

**ស៖** អរគុណលោក។ តើលោក និងលោក អៀង សារី ដែលបានទៅជាប់បងប្អូនទាំងអស់នោះហើយអប់រំណែនាំពីគោលនយោបាយរបស់បក្សកម្ពុជាទេ?

**ផ៖** ខ្ញុំមិនដែលឃើញបង អៀង សារី គាត់យកឯកសារបក្សទៅទេ។ គាត់អប់រំតាម ខ្ញុំចាំគឺត្រឹមក្របខ័ណ្ឌរណសិរ្សតែប៉ុណ្ណោះ។

**ស៖** អរគុណលោក។ ក្រៅពីការអប់រំណែនាំគោលការណ៍រណសិរ្សតើលោក អៀង សារី បាន

អប់រំណែនាំសតិអារម្មណ៍ ពង្រឹងសតិអារម្មណ៍ណែនាំប្រាប់ពីការលំបាកដល់បងប្អូនទាំងនោះទេ?

**ឆ៖** ពាក្យដែលខ្ញុំចាំក្នុងនោះ ខ្ញុំសរុបបានថា ការតស៊ូគឺជាការលំបាក ស្វិតស្វាញ មោះមុត អង់អាច ក្លាហាន ពេលខ្លះត្រូវលះបង់ជីវិត។

**ស៖** សូមអរគុណលោក។ ឥឡូវខ្ញុំសូមឆ្លងទៅចំណុចមួយទៀត តើលោក និងលោក អៀង សារី ធ្លាប់ទៅធ្វើទស្សនកិច្ចនៅក្រៅប្រទេសញឹកញាប់ទេ? ហើយតើប្រទេសណាខ្លះ?

**ស៖** លោក អៀង សារី ទៅទស្សនកិច្ចនៅក្រៅប្រទេសញឹកញាប់ដែរ។ តាមខ្ញុំចាំ ទៅប្រទេស ទៅក្រៅប្រទេសចូល-- មិនចូលបក្សសម្ព័ន្ធ ធ្វើការងារនៅក្នុងប្រទេសដែលមិនចូលបក្សសម្ព័ន្ធហ្នឹង គេហៅថា ទៅធ្វើការងារប្រទេសមិនចូលបក្សសម្ព័ន្ធនុ៎ង។ ដូច្នេះ ត្រូវឆ្លងកាត់ប្រទេសផ្សេងៗ ហើយនិងទស្សនកិច្ចនៅប្រទេសចិន ឆ្លងកាត់ប្រទេសបារាំង អីចឹង។ ឯទស្សនកិច្ចផ្សេងៗទៀតហ្នឹង ខ្ញុំភ្លេចមិនបានដែរ។

[១៣:៤៦:២៨]

**ស៖** សូមអរគុណលោក។ លោកជាអគ្គលេខាធិការក្រសួងការបរទេស តើរបៀបរបបធ្វើការ និងការប្រជុំនៅក្នុងក្រសួងការបរទេសមានលក្ខណៈដូចម្ដេចដែរលោក?

**ឆ៖** ខ្ញុំមានងារជាអគ្គលេខាធិការ។ ងារនេះ គឺមានតែងារទេ បើនិយាយពីខ្លឹមសារឥឡូវនេះ ដូចជាមិនត្រឹមត្រូវទេ ពីព្រោះខ្ញុំមិនចេះភាសា។ ដូច្នេះពាក្យថា "អគ្គលេខាធិការ" នេះ ភារកិច្ចខ្ញុំនេះ គឺដូចបានខ្ញុំជម្រាបពីមុនអីចឹង និយាយសរុបទៅ គឺថាខ្ញុំនេះសម្របសម្រួល គ្រាន់តែជាកម្មាភិបាលម្នាក់សម្របសម្រួលរវាងកសិករ។ ក្នុងនោះវាមានផ្នែកកសិករ និងបញ្ញាជនតែប៉ុណ្ណោះ។

**ស៖** អរគុណលោក។ ខ្ញុំចង់បញ្ជាក់លោកដែរថា តើរបៀបរបប ឬការ និងការដែលលោកធ្វើនៅក្រសួងការបរទេសវាមានតាំងពីមុនឆ្នាំ៧៥ ឬក៏ពេលដែលទើបអនុវត្តនៅឆ្នាំ៧៥?

[១៣:៤៨:១១]

**ឆ៖** គឺអនុវត្តនៅឆ្នាំ៧៥។

**ស៖** សូមអរគុណលោក។ រាល់ការប្រជុំនៅក្រសួងការបទេស តើមានការផ្សព្វផ្សាយពីគោលនយោបាយបក្សដែរឬទេ? ហើយគោលនយោបាយនោះមានខ្លឹមសារដូចម្ដេចដែរ?

**ឆ៖** គោលនយោបាយ ឯកសារជាគោលនយោបាយរបស់បក្ស គឺមិនបានរៀនទេ។ ដោយខ្ញុំមិនបានឃើញលក្ខន្តិកៈរបស់បក្ស អត់បានរៀនទេ។ ច្រើនតែរៀនអំពីទស្សនៈសភាពការណ៍បច្ចុប្បន្ន

និងការវិភាគសភាពការណ៍បច្ចុប្បន្ន និងទៅអនាគតយ៉ាងណាៗជម្រាបជូនបងប្អូនតែប៉ុណ្ណោះ ហើយមានការចាប់អារម្មណ៍លើទស្សនៈសភាពការណ៍យ៉ាងណាៗនោះទៅ។ ធ្វើម៉េចមានវិធានការលើសភាពការណ៍ ពង្រឹងខ្លួនឯង ពង្រឹងអត្តនោម័តិខ្លួនឯង ហើយពង្រឹងកិច្ចការពារប្រទេស និងកិច្ចកសាងប្រទេស។

[១៣:៥០:០១]

**ស៖** អរគុណលោក។ ផ្អែកលើចម្លើយដែលលោកឆ្លើយបញ្ជាក់ យើងខ្ញុំចង់ថា តើផែនការគោលនយោបាយរបស់បក្សបានលើកឡើងៗជាផែនការអីខ្លះ? សូមលោកអាចបញ្ជាក់បានទេចាស?

**ឆ៖** ផែនការរបស់បក្ស គឺមានតាម ទៅតាមសភាពការណ៍នីមួយៗបាទ។ ខ្ញុំមិនអាចរៀបរាប់ឲ្យគ្រប់សព្វបានទេ។ ឧបមាថា ខ្ញុំឧទាហរណ៍ ខ្ញុំជាអ្នកដាំបន្លែ ខ្ញុំត្រូវគ្រប់គ្រងមួយក្រុមដាំបន្លែនោះធ្វើការផែនការដាំបន្លែឲ្យបានល្អបាទ។ ក្រុមនោះជាអ្នកចិញ្ចឹមជ្រូក ធ្វើម៉េចឲ្យជ្រូកហ្នឹងឲ្យបានភ្ញៀវអីយកមកទទួលទានអ៊ីចឹងទៅ។ អ្នកខាងបរទេស ផែនការរបស់គេ ខាងការបរទេសអ៊ីចឹងទៅ។ ឯផ្នែកខ្ញុំនេះ មិនមែនខាងបច្ចេកទេស ខាងធ្វើការងារសតិអារម្មណ៍ផ្ទាល់ទៅដល់ខាងបញ្ញាជនទេ ខ្ញុំនេះធ្វើខាងផ្នែកកសិករ។

**ស៖** អរគុណលោក។ ខ្ញុំសូមឆ្លងចូលទៅចំណុចមួយទៀត តើនៅ ប-១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស តើមានបែងចែកការងារជាប៉ុន្មានផ្នែក? ហើយអ្នកណាជាអ្នកទទួលបន្ទុកផ្នែកនីមួយៗ?

[១៣:៥២:០៦]

**ឆ៖** ក្នុងរយៈកាលក្រោយពីរំដោះបានបីឆ្នាំបន្តិចបន្តួចនេះ ការគ្រប់គ្រងនៅក្រសួងនៅច្របូកច្របល់ណាស់។ ភាគច្រើនគឺសម្អាត គ្រាន់តែសម្អាតទីក្រុងដែលចេញពីភ្នក់ភ្លើងសង្គ្រាមនោះមួយឆ្នាំមិនទាន់ហើយផង។ ឯរៀបចំរចនាសម្ព័ន្ធផ្សេងៗនៅក្នុងក្រសួងការបរទេស ខ្ញុំចាប់នេះចាប់នោះមិនផ្តោះត្រង់ណាទេ ឲ្យតែកន្លែងណាត្រូវការ ខាងលើប្រើ ខ្ញុំទៅ។ ដូច្នេះ ខ្ញុំមិនចាំជាខ្សែសង្វាក់ទេ។ សូមអភ័យទោស។

**ស៖** សូមអរគុណលោក។ ខ្ញុំសូមឆ្លងចូលចំណុចមួយទៀត។ ពីព្រឹកមិញលោកបានបញ្ជាក់នៅមុខសហព្រះរាជអាជ្ញថា កាលនៅឆ្នាំ១៩៧៦ មានការចាប់ខ្លួនមនុស្សយ៉ាងច្រើន តើសមាសភាពដែលគេចាប់នោះ ជាសមាសភាពបែបណាខ្លះចាស?

**ឆ៖** ខ្ញុំបានបញ្ជាក់ពីពេលនោះថា ពីម្សិលមិញនោះថា ការចាប់ខ្លួនច្រើននេះមិនមែននៅការបរទេសទេ ទូទាំងប្រទេស។ ឯសមាសភាពដែលចាប់នោះ ភាគច្រើនគឺចេញមកពីជនបទ ភាគច្រើន។ ឯក្រសួងការបរទេសដែលត្រូវគេចាប់នោះ គឺគេយកមកធ្វើនឹងក្រសួងការបរទេស ហើយគេយកមកធ្វើហើយ គេយកទៅវិញបាត់។ យកទៅវិញបាត់នុ៎ងហើយ ដែលខ្ញុំហៅថាប្រហែលគេចាប់ហើយ មិនដឹងយកទៅណាទេ។

[១៣:៥៤:៤៩]

**ស៖** សូមអរគុណចាស។ តើនៅក្នុងសមាសភាពដែលយកមកធ្វើនៅក្រសួងការបរទេស លោកមាននៅចាំទេថា មានឈ្មោះលោក ចៅ សេង ទេ?

**ឆ៖** បាទ តាមខ្ញុំចាំមានឈ្មោះដែរ មានឈ្មោះលោក ចៅ សេង ប៉ុន្តែលោកមិនដឹងទៅណា។ ខ្ញុំក៏អត់បានដឹងដែរ។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់សូមឲ្យលោកជួយបំភ្លឺ តើក្នុងចំណោមបញ្ញាជន ដែលលោក អៀង សារី បានធ្វើការអំពាវនាវឲ្យត្រឡប់មកប្រទេសកម្ពុជាវិញនោះ តើមាននៅក្នុងចំណោមអ្នកទោសដែលត្រូវគេចាប់នៅឆ្នាំ៧៦ ទេចាស?

**ឆ៖** ខ្ញុំចាំអត់បាន។

[១៣:៥៦:១៦]

**ស៖** សូមអរគុណលោក។ ខ្ញុំចង់ជម្រាបសួរលោកថា តើអ្នកណាជាអ្នកចាប់អ្នកទាំងនោះ? ហើយអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការចាប់នោះ?

**ឆ៖** ចំពោះអ្នកខ្លះ ខ្ញុំអត់ដឹង ដូចឧទាហរណ៍ ដូចលោក ចៅ សេង ខ្ញុំអត់ដឹងរឿង។ ឯអ្នកដឹងគឺខ្ញុំឃើញលោក ប៉ង់ មកយក ឬក៏គាត់បញ្ជាឲ្យផ្នែកខាងគាត់មកយក មានសំបុត្រស៊ីញ៉េឈ្មោះលោក ប៉ង់។

**ស៖** សូមអរគុណលោក។ លោកបានបញ្ជាក់ថា អ្នកដែលចាប់នោះគឺឈ្មោះ ប៉ង់ ជាអ្នកទទួលខុសត្រូវ។ តើលោកអាចបញ្ជាក់បានទេថា នេះជាផែនការរបស់ថ្នាក់លើ?

**ឆ៖** ខ្ញុំមិនបានដឹងជាជម្រៅរឿងនេះដែរ។

**ស៖** សូមអរគុណលោក។ លោកបានបញ្ជាក់នៅមុខសហព្រះរាជអាជ្ញាព្រឹកមិញថា នៅរាល់ការប្រជុំធំៗ តែងតែមានការចូលរួមពី អៀង សារី តើមែនទេលោក?

**ឆ៖** បាទ។

**ស៖** សូមលោកជួយបញ្ជាក់ តើពាក្យដែលថា ការប្រជុំធំៗហ្នឹងយ៉ាងម៉េចដែរចាស?

**ឆ៖** ការប្រជុំធំៗ ជាសន្និបាត គឺមានគណៈ ផ្នែកខាងខ្ញុំ។ ខ្ញុំនិយាយឲ្យស្រួលស្តាប់ទៅគឺថា ផ្នែកកសិករ និងផ្នែកបញ្ញាជនចូលរួម មានគណៈខ្លះចូលរួមដើម្បីឲ្យយល់គ្នា។ ផ្នែកធំៗមួយទៀតគឺផ្នែក ដែលខ្ញុំមិនចូលរួមនោះ គឺផ្នែកខាងបញ្ញាជន ដូចជារៀបទៅអង្គការសហប្រជាជាតិអីៗផ្សេងៗ បង អៀង សារី គាត់ច្រើនតែហៅមកប្រជុំ។ នេះក៏ខ្ញុំយល់ឃើញថា ជាផ្នែកធំៗដែរ។

[១៣:៥៩:២៧]

**ស៖** សូមអរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថែមទៀតថា តើការប្រជុំធំៗនេះមានរយៈ ពេលប៉ុន្មានដងក្នុងមួយឆ្នាំ? ឬមួយមានរៀងរាល់ខែ?

**ឆ៖** តាមខ្ញុំចាំ ទីមួយ តាមសភាពការណ៍ដែលជំរុញឲ្យប្រជុំ។ ទីពីរ គឺសភាពការណ៍ដែលទំនេរ គឺសន្និបាតនេះ។ ឱកាសដែលទំនេរ ឱកាសដែលស្រួល ដែលគ្មានកិច្ចការងារច្រើននៅក្រៅប្រទេសនោះ បើកសន្និបាត។ ខ្ញុំឃើញថា កិច្ចការងារធំៗនេះ មួយឆ្នាំមិនលើសពីពីរដងទេ។

**ស៖** សូមអរគុណលោក។ លោកជាអគ្គលេខាក្រសួងការបរទេស តើលោកមានដឹងពីជន បរទេស និងឈ្លើយសឹកវៀតណាមដែលត្រូវជាប់ឃុំនៅស-២១ ទេ?

**ឆ៖** ខ្ញុំអត់បានដឹងរឿងនេះទេ។

**ស៖** ចុះលោក អៀង សារី លោកបានដឹងពីបញ្ហានេះទេ ចាស?

**ឆ៖** ខ្ញុំក៏មិនដឹងថា លោកដឹង ឬមិនដឹងដែរ។

**ស៖** តើកន្លងមក លោកក្តី លោក អៀង សារី ក្តី តើដែលមានទំនាក់ទំនងជាមួយនឹងប្រទេស ដែលៗគេមានជនជាតិគេ មកជាប់ឃុំនៅស-២១ ទេ ចាស?

**ឆ៖** បាទ សំណួរនេះ ខ្ញុំអត់សូវយល់បាទ។ សូមម្តងទៀត។

**ស៖** ក្នុងនាមលោកជាអគ្គលេខាក្រសួងការបរទេស លោកបានបញ្ជាក់ថា លោកមិនបានដឹង ពីជនជាតិបរទេស និងឈ្លើយសឹកវៀតណាមដែលជាប់ឃុំនៅស-២១ទេ។ ហើយលោកក៏បានបញ្ជាក់ ដែរថា លោក អៀង សារី ក៏ពុំបានដឹងពីបញ្ហានេះដែរ។ ប៉ុន្តែកន្លងមក តើលោកធ្លាប់បានទំនាក់ទំនងនឹង ប្រទេស ដែលមានជនជាតិរបស់គេជាប់នៅក្នុងស-២១ ទេ ចាស?

[១៤:០២:៤៣]

**ឆ៖** ខ្ញុំបានឆ្លើយថា បញ្ហានេះខ្ញុំមិនដឹងទេ។ ឯលោក អៀង សារី គាត់ដឹង ឬមិនដឹង ខ្ញុំក៏មិនដឹងដែរ។ ឯជនបរទេសអីៗ ដែលទៅជាប់នៅស-២១ ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំសូមឆ្លងចូលនូវចំណុចមួយទៀតគឺ បឹងត្របែក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ តើបឹងត្របែកមានទីតាំងនៅកន្លែងណាពិតប្រាកដ?

**ឆ៖** កាលណោះបឹងត្របែក ខ្ញុំមិនដឹងច្បាស់ទេ។ ពេលខ្ញុំ និងបង អៀង សារី ដែលវៀតណាមជិតចូលមកភ្នំពេញនេះ ខ្ញុំទៅៗ ភារកិច្ចជួបជុំបងប្អូននិយាយអំពីសភាពការណ៍។ ខ្ញុំក៏មិនដឹងបឹងត្របែកនៅចំណុចណាដែរ ប៉ុន្តែដល់ពេលដែលខ្ញុំក្រោយដែលខ្ញុំសមាហរកម្មមកភ្នំពេញនេះ ខ្ញុំទៅបឹងត្របែកខ្ញុំដឹងថាបឹងត្របែកហ្នឹង វានៅចំណុចក្បែរមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតពីដើម បាទ ខាងជើង។ ក្បែរៗផ្សារដើមថ្កូវ ក៏មិនដឹងដែរបាទ។

[១៤:០៤:៥៧]

**ស៖** សូមអរគុណលោក។ តើកន្លងមក លោក អៀង សារី ធ្លាប់ទៅបង្រៀនញឹកញាប់ទេនៅបឹងត្របែក? នៅឆ្នាំណា? ហើយប៉ុន្មានដងដែរ ចាស?

**ឆ៖** ខ្ញុំអត់បានដឹងលោកទៅបឹងត្របែកទេ។ ខ្ញុំដឹងតែពេលដែលលោកនាំខ្ញុំទៅបឹងត្របែក ពេលដែលវៀតណាមហៀបនឹងចូលភ្នំពេញ។

**ស៖** សូមអរគុណ។ តើលោក និងលោក អៀង សារី អញ្ជើញទៅបឹងត្របែក តើទៅធ្វើអីដែរលោក?

**ឆ៖** ដូចខ្ញុំបានជម្រាបពីមុនអ៊ីចឹង គឺទៅនេះ វៀតណាម សង្គ្រាញចូលជតិ កៀកៗភ្នំពេញហើយត្រូវរៀបចំវិធី យុទ្ធវិធីយ៉ាងណា ដើម្បីគេចចេញឲ្យផុតពីគ្រោះអាសន្ននៃវៀតណាមចូលភ្នំពេញ។

[១៤:០៦:៤២]

**ស៖** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើបឹងត្របែកនេះជាកន្លែងអីដែរលោក?

**ឆ៖** ពេលដែលខ្ញុំស្គាល់បឹងត្របែក ដែលទៅជាមួយលោក អៀង សារី ទៅបឹងត្របែក ទើបខ្ញុំស្គាល់ថា អូ៎! កន្លែងនេះហើយ ជាកន្លែងដែលលោក ប៉ង់ យកបញ្ជាជនមកដាក់ទីនេះ។

**ស៖** សូមអរគុណលោក។ តើសមាសភាពអ្នកដែលលោក ប៉ង់ យកទៅដាក់នៅបឹងត្របែកមានសមាសភាពអ្វីខ្លះ?

**ឆ៖** បញ្ញាជនដែលយកទៅដាក់បឹងត្របែក ខ្ញុំមិនស្គាល់សមាសភាពទេ។ ខ្ញុំ-- ក្រោយមកទៀតទេបានខ្ញុំស្គាល់ ស្គាល់ខ្លះៗ ក្រោយពេលដែលខ្ញុំទៅនុ៎ង។ បានខ្ញុំដឹងថា អូ!បញ្ញាជននេះធំៗណាស់ សុទ្ធតែសាស្ត្រាចារ្យបង្រៀនសាស្ត្រាចារ្យទៀត ធំៗណាស់ ហើយយកមកធ្វើយ៉ាងដូច្នេះ អារម្មណ៍ខ្ញុំគិតថាអត់ត្រឹមត្រូវទេ។ សមាសភាពទៀតគឺ ដូចជាលោកនែ៎! ហោ ណាំហុង សុទ្ធតែធ្វើកិច្ចការងារទូត ក៏យកលោកទៅដាក់ត្រង់នុ៎ងដែរ។ ដូច្នេះ ខ្ញុំដឹងតែសមាសភាពប៉ុណ្ណឹង ក្រោយពេលដែលខ្ញុំ-- អ៎! ពេលដែលខ្ញុំទៅធ្វើការជាមួយបង អៀង សារី ប៉ុណ្ណោះ។

[១៤:០៩:០៤]

**ស៖** អរគុណលោក។ លោកធ្លាប់អញ្ជើញទៅជាមួយលោក អៀង សារី ប៉ុន្មានដង? សូមលោកបញ្ជាក់កន្លែងនេះបន្តិច?

**ឆ៖** តាមខ្ញុំចាំ ខ្ញុំធ្លាប់ទៅជាមួយលោក អៀង សារី ពីរដង។ ក្រៅពីនោះខ្ញុំទៅខ្លួនឯងពីរដង។ ម្តងចុងក្រោយ គឺទៅប្រមូលកម្លាំងចេញពីៗបឹងត្របែករត់ ពីព្រោះពេលនោះយួនចូលកៀកដល់ ជិតដល់ភ្នំពេញហើយ។

**ស៖** អរគុណច៎ាសលោក។ តើពេលដែលលោក អៀង សារី និងលោកទៅបឹងត្របែក តើលោកមានបានសង្កេតឃើញជីវភាពរបស់បញ្ញាជនទាំងនោះយ៉ាងម៉េចដែរទេ ចាស?

**ឆ៖** បងប្អូនអបអរសាទរនឹងបង អៀង សារី និងខ្ញុំទៅ។ មើលទៅហាក់ដូចជាគេចេញពីរង្វង់ធ្វើទារុណកម្ម ឬក៏យើងថា ធ្វើទារុណកម្មអ៊ីចឹងក៏មិនត្រឹមត្រូវដែរបាទ។ គឺថា ដូចតែគ្នាវាអរ អបអរ ភិត -- មុនដំបូងគឺថា សភាពភិតភ័យ ដល់ឃើញបង អៀង សារី និងខ្ញុំទៅមានការអបអរ ហើយក៏បានឲ្យជីវភាព ជីអីហ្នឹងឡើងវិញឲ្យបានសមស្របទៅ គឺថាពេលនុ៎ង គឺថាឲ្យអង្ករអីៗពីរកំប៉ុងពីអីហ្នឹងជូនបងប្អូនទៅ ហើយឲ្យបងប្អូនរស់នៅឲ្យបានស្រួលត្រឹមត្រូវតែប៉ុណ្ណឹងទេបាទ។ ខ្ញុំឃើញទិដ្ឋភាពយ៉ាងដូច្នេះ។

**ស៖** អរគុណលោក។ តើលោកអាច-- សូមលោកជួយបញ្ជាក់បានទេថា តើបងប្អូនទាំងនោះដែលជាបញ្ញាជន មានបងប្អូនដែលជាបញ្ញាជនមកពីប្រទេសក្រៅទេ នៅបឹងត្របែក?

[១៤:១១:៥៣]

**ឆ៖** បាទ ភាគច្រើនៗតែម្តង ភាគច្រើនដាច់ខាតតែម្តង គឺសុទ្ធតែមកពីក្រៅប្រទេសបាទ។ បញ្ញាជននៅក្នុងប្រទេស ដូចខ្ញុំមិនឃើញមានទេបាទ ពីព្រោះបញ្ញាជននៅក្នុងប្រទេសគេច្រើនតែធ្វើការនៅមូលដ្ឋានលោក។

**ស៖** អរគុណលោក។ លោកបានបញ្ជាក់ថា ពេលដែលលោក អៀង សារី និងលោកទៅបឹងត្របែក គឺថាបងប្អូនដែលជាបញ្ញាជននៅបឹងត្របែកគឺថា ស្វាគមន៍ ហើយសប្បាយជាមួយលោក។ តើលោក សូមលោករំឭកឡើងវិញមើល៍! តើលោកមាននៅចាំឈ្មោះអ្នកណាទេ ខ្លះ ដែលលោកធ្លាប់ស្គាល់ចាស៎? លោកអាចប្រាប់ឈ្មោះខ្លះបានទេចាស?

[១៤:១២:៥៨]

**ឆ៖** អ្នកដែលចាំជាងគេឈ្មោះ ដារីដ។ ឃួន ដារីដ។ ខ្ញុំឮថា កាលនោះក្រសួងការបរទេស ខ្ញុំឮបញ្ញាជនដែលទៅលេង អ៎! ទៅធ្វើការនៅបរទេសហ្នឹងប្រាប់ខ្ញុំថា មានម្នាក់នោះឈ្មោះ ឃួន ដារីដ គាត់ហ្នឹងពូកែណាស់។ គាត់ទៅរៀនបរទេសហ្នឹង គឺថាគាត់ធ្វើសាស្ត្រាចារ្យលើសាស្ត្រាចារ្យទៀត។ ខ្ញុំឮយ៉ាងដូច្នេះ ខ្ញុំទៅប្រាប់ឪពុកមាខ្ញុំឈ្មោះ ប៉ុល ពត ពីព្រោះពេលដែលខ្ញុំនាំស្អីៗទៅដូចថា មានត្រីអីល្អៗអីអ៊ីចឹងទៅ គេអាចឲ្យខ្ញុំចូលបាន ទៅកន្លែងគេហៅថា ក-១ ហ្នឹងណ៎ះ! ខ្ញុំចូលទៅ ខ្ញុំថាអ៊្ហូ! គាត់ថា "អ្អឺ! មានគេបញ្ញាជនណាពូកែៗទេ?" ខ្ញុំថា "ដារីដ" "អឺ! អ៊ីចឹងទៅមើលមើល៍! ស៊ើបសួរមើល៍! ក្រែងលោយកមកជួយធ្វើការអីបាន"។ នេះខ្ញុំឃើញ ខ្ញុំស្គាល់ឈ្មោះហ្នឹងមួយទេដែលច្បាស់បាទ។ ក្រៅពីហ្នឹងបងហ៊ីង អ៊ុន ហេងអីហ្នឹង អាហ្នឹងស្គាល់ក្រោយៗមកទៀតទេ។ ខ្ញុំធ្លាប់ន៎ែ! ដល់ទៅៗចេះតែស្គាល់គ្នាតៗទៀតទៅ។ ប៉ុន្តែ ដារីដ ហ្នឹង ខ្ញុំស្គាល់ឈ្មោះដែលគេល្បីៗមកអ៊ីចឹងទេបាទ។

[១៤:១៤:៥៦]

**ស៖** អរគុណលោក។ លោកថា លោក ដារីដ ជាសាស្ត្រាចារ្យមួយដ៏ពូកែ ហើយលោកក៏-- លោក ប៉ុល ពត ចង់ឲ្យលោកទៅយកលោក ដារីដ មកនៅជាមួយគាត់ មែនទេលោក?

**ឆ៖** *(និយាយមិនបើកមីក្រូហ្វូន)*

**ស៖** តើពេលដែលលោកត្រឡប់ទៅយកលោក ដេរីដ វិញ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! អត់ទាន់ឆ្លើយទេអំមិញ អត់មាន-- គាត់-- ក្បាលមីក្រូអត់មានភ្លើងក្រហមផង។ សូមឆ្លើយ-- ឆ្លើយចាំមានក្បាលមីក្រូមានភ្លើងចាំឆ្លើយបាទ!

[១៤:១៥:៣៧]

**លោក សាឡុត បាន៖**

**ឆ៖** បំណាងគាត់អ៊ីចឹងឯង ចង់បានអ៊ីចឹង។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អរគុណលោក។ តើបំណងដែលលោក ប៉ុល ពត ចង់បានលោក ដេវីដ មកជួយធ្វើការគាត់ តើបំណងរបស់លោក ប៉ុល ពត បានសម្រេចទេចាស?

**ឆ៖** ដល់គាត់ប្រាប់ខ្ញុំយ៉ាងដូច្នេះ ខ្ញុំទៅប្រាប់ឈ្មោះ ប៉ង់។ ខ្ញុំដឹងថា ប៉ង់ ហ្នឹងគ្រប់គ្រង យកបញ្ញាជនហ្នឹងទៅណាៗ មិនដឹងទេ ប៉ុន្តែអាចហើយ អាមាន អាគាត់គ្រប់គ្រងហើយ។ ខ្ញុំប្រាប់ឈ្មោះថា មើលឈ្មោះហ្នឹងផង។ ដូច្នេះ រហូតមកដល់ពេលឥឡូវនេះអត់បានមកដូចបំណងរបស់លោក ប៉ុល ពត ទេបាទ។

[១៤:១៦:៤៣]

**ស៖** គាត់ទៅណាទៅចាស?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** ពេលដែលលោកត្រឡប់ទៅវិញ លោកមានឃើញឈ្មោះ ដេវីដ ហ្នឹងទៀតទេចាស?

**ឆ៖** បាទ អត់ឃើញ។

**ស៖** អរគុណលោក។ លោកគិតថា លោក ដេវីដ ហ្នឹង ប៉ង់ យកទៅបាត់ ឬយ៉ាងម៉េច?

**ឆ៖** បាទ មិនដឹង។

**ស៖** សូមអរគុណលោក។ លោកនៅក្រសួងការបរទេស តើលោកធ្លាប់ដឹងឮពីការិយាល័យ២១ នៅតាខ្មៅទេ?

[១៤:១៨:១៥]

**ឆ៖** មិនដែលឮទេ ក្រោយមកពេលវៀតណាមចូលស្រុកហើយបានខ្ញុំដឹង។

**ស៖** តើការិយាល័យ២១ នេះ កន្លងមកអត់មានស្ថិតនៅក្រោមក្រសួងការបរទេសទេលោក?

**ឆ៖** បាទ អត់ទេ។

**ស៖** តើលោកមានដឹងទេ ថាអ្នកណាជាអ្នកគ្រប់គ្រងការិយាល័យ២១ នៅតាខ្មៅ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណលោក។ តើលោកស្គាល់ ខៀវ ធីរ៉ាត់ ទេ?

**ឆ៖** បាទ ខ្ញុំស្គាល់។

**ស៖** គាត់ត្រូវជាម៉េច គាត់ត្រូវជាអ្វីនឹងលោក អៀង សារី លោក?

[១៤:១៩:៥៤]

**ឆ៖** គាត់ត្រូវជាបងថ្លៃរបស់បង អៀង សារី។

**ស៖** តើលោកបានដឹងអំពីការស្លាប់របស់ ខៀវ ធីរ៉ាត់ ទេចាស នៅតាខ្មៅ?

**ឆ៖** បាទ ខ្ញុំបានដឹង។

**ស៖** តើគាត់ស្លាប់ដោយមូលហេតុអីដែលលោក?

**ឆ៖** ពេលដែលស្លាប់នៅតាខ្មៅ ខ្ញុំបានយកសពនោះមកដុតនៅវត្ត វត្តអីនៅជិតអូឡាំពិក អំនៅជាប់ស្តាតអូឡាំពិកខាងជើង វត្តៗៗព្រះពុទ្ធ បាទ។ ខ្ញុំបានយកសពលោក យកមកដុតនៅវត្តព្រះពុទ្ធដោយខ្លួនឯងៗផ្ទាល់បាទ។ ខ្ញុំបានអញ្ជើញលោក ជួន ជឿន មកពិនិត្យ លោកថា សពនេះគឺច្រូបាច់ក។

**ប្រធានអង្គជំនុំ៖**

ផ្អាកៗបន្តិចសិនសឹម--

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:២១:៤១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ខ្ញុំធ្វើអន្តរាគមន៍ ពីព្រោះខ្ញុំគិតថាមានបញ្ហាក្នុងការបកប្រែជាភាសាបារាំង។ ខ្ញុំគិតថាយើងនិយាយអំពី ខៀវ ធីរិទ្ធ ឬក៏ ខៀវ ធីរ៉ាត់ គឺជាបងរបស់ ខៀវ ធីរិទ្ធ ហើយវាមិនមែនជា-- ហើយមិនមែនជាមនុស្សប្រុសទេ គឺជាមនុស្សស្រី។ តើអ៊ីចឹងមែនទេ? ព្រោះមានបញ្ហាខាងការបកប្រែ។

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន ឈ្មោះ ខៀវ ធីរ៉ាត់ ភេទស្រី ត្រូវជាបងរបស់ ខៀវ ធីរិទ្ធ និងត្រូវជាប្អូនថ្លៃរបស់លោក អៀង សារី ចាស។ អំ ជាបងថ្លៃចាស បងថ្លៃរបស់លោក អៀង សារី។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** សូមអរគុណលោក។ តើលោក អៀង សារី បានដឹងពីបញ្ហានេះទេលោក?

**លោក សាឡុត បាន៖**

**ឆ៖** ពេលនោះខ្ញុំដូចជាឃើញតែដូចជាគាត់នៅក្រៅប្រទេស ឬក្នុងប្រទេសមិនដឹងទេ។ ពីព្រោះការដែលទៅយកសពនោះមកបូជា មានតែខ្ញុំ ហើយនិងនែកូនលោក អៀង សារី ហ្នឹងម្នាក់ពីរនាក់

ហើយនិងអ្នកជំនួយការខ្ញុំខាងក្រសួងការបរទេសហ្នឹងម្នាក់ពីរហ្នឹងយកទៅបាទ។ ខ្ញុំចាំមិនច្បាស់ដែរលោក។

[១៤:២៣:៤២]

**ស៖** អរគុណលោក។ លោកមានដឹងទេថា អ្នកស្រី ខៀវ ធីរ៉ាត់ ហ្នឹងគឺជាបញ្ញាជនមកពីប្រទេសបារាំងមែនទេ?

**ឆ៖** បាទ គាត់ជាបញ្ញាជនមកពីប្រទេសបារាំង គាត់ជាសាស្ត្រាចារ្យខាងខ្មែរ។

**ស៖** ខ្ញុំសូមឱ្យលោកជួយបញ្ជាក់បន្តិចថា តើការិយាល័យនៅតាខ្មៅ ២១ នៅតាខ្មៅ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកណាលោក?

**ឆ៖** រឿង ២១ នៅតាខ្មៅ នេះខ្ញុំងងឹតសូន្យហើយ មិនដឹងអ្នកណាទេ បាទ ងងឹតសូន្យហើយបាទ។

**លោកស្រី ជេត វណ្ណលី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារលេខ E3/91 ERN ខ្មែរ 00204097 រហូតដល់ 00204098, ERN ជាភាសាអង់គ្លេស 00223593 និង ERN ជាភាសាបារាំង 00503936 ដល់ 00503937។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអានលេខ ERN ជាភាសាអង់គ្លេសសាជាថ្មីម្តងទៀត ព្រោះមិនមានការបកប្រែ។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ERN ជាភាសាអង់គ្លេស 00223593 ERN ជាភាសាបារាំង 00503936 ដល់ 00503937។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមបុគ្គលិកជំនួយការ បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

[១៤:២៧:១០]

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ ខ្ញុំសូមអានចាស។

"បងស្រីរបស់ ខៀវ ធីរិទ្ធ ឈ្មោះ ខៀវ ធារ៉ាត់ ដែលជាបញ្ញាជនមកពីប្រទេសបារាំង ពេលនោះត្រូវអង្គការឲ្យសម្រាកនៅតាខ្មៅ ហើយក្រោយមកក៏ត្រូវស្លាប់ដោយមានស្នាមច្របាច់ក ក្នុងរយៈពេលដែលគាត់ឋិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ប៉ង់ នៅតាខ្មៅ។ ក្រោយមកលោក ជួន ជឿន បានទៅពិនិត្យសពឃើញថាស្លាប់ដោយសារច្របាច់ក"។ សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកសាក្សី តើលោកមានចង់ធ្វើអត្ថាធិប្បាយអី ថែមលើហ្នឹងទៀតទេចាស ក្នុងការស្លាប់របស់បង ខៀវ ធីរ៉ាត់?

**ឆ៖** ខ្ញុំអត់មានធ្វើអត្ថាធិប្បាយអី ថែមទៀតទេ។

**ស៖** សូមអរគុណលោក។

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ តើគួរដល់ពេលសម្រាក ឬក៏យើងខ្ញុំអាចបន្តទៀតបានចាស?

[១៤:២៨:៥៣]

**ប្រធានអង្គជំនុំ៖**

បន្តដប់មីនុតទៀត។ ម៉ោងបីខ្វះម្ភៃនាទីទើបសម្រាក។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ខ្ញុំសូមគោរពលោកសាក្សីម្តងទៀត។ ឥឡូវ យើងឆ្លងទៅចំណុចមួយទៀត គឺច្រាំងចំរេះ។ សូមលោកសាក្សីជួយបំភ្លឺយើងខ្ញុំ តើច្រាំងចំរេះបង្កើតឡើងនៅឆ្នាំណាដែរចាស?

**ឆ៖** បាទ ច្រាំងចំរេះខ្ញុំមិនដឹងកើតឡើងពីឆ្នាំណាទេ ពីព្រោះជាកន្លែងរបស់ភូមិភាគ៣០៤។ តែគេប្រគល់ឲ្យក្រសួងការបរទេសពីឆ្នាំ ប្រហែលមួយពាន់-- បើខ្ញុំចាំ១៩៧៧ ប្រហែលឆ្នាំហ្នឹងបាទ ៧៧ រហូតមក។

**ស៖** អរគុណលោក។ តើលោកអាចបញ្ជាក់បានទេ ថាច្រាំងចំរេះពេលនុំងនៅម្តុំណា? នៅខាងណាភ្នំពេញ ចាស?

**ឆ៖** ច្រាំងចំរេះ គឺច្រាំងចំរេះសព្វថ្ងៃ គឺនៅខាងជើងភ្នំពេញបាទ។

**ស៖** អរគុណលោក។ ប៉ុន្តែខ្ញុំចង់ដឹង តើមន្ទីរហ្នឹង នៅម្តុំណា? នៅកន្លែងចាស? លោកអាចនៅចាំទេចាស?

**ផ៖** ដល់ៗខ្ញុំចូលមកទៅ វាប្រែប្រួលអស់ ប្រែប្រួលអស់ហើយ ខ្ញុំមិនអាចចាំបានទេ លោក។ វាយូរឆ្នាំដែរហើយ។

**ស៖** អរគុណលោក។ តើជាប់នឹងផ្លូវជាតិទេ ចាស? ឬមួយក៏ចូលទៅក្នុង?

**ផ៖** បាទ ជាប់នឹងផ្លូវជាតិ។ ដល់ឥឡូវទៅ គេធ្វើស្អីៗ ចិញ្ចឹមត្រី ចិញ្ចឹមអីស្រេះអីចឹងទៅ ខ្ញុំវង្វេងអស់ហើយ។

**ស៖** អរគុណលោក។ តើច្រាំងចំរេះ ជារបស់ក្រសួងការបរទេស ឬរបស់ភូមិភាគ?

[១៤:៣១:៥៤]

**ផ៖** ដូចខ្ញុំបានជម្រាបអីចឹង ច្រាំងចំរេះមិនដឹងកើតកពីឆ្នាំណាទេ។ ប៉ុន្តែខ្ញុំទៅទទួលខុសត្រូវពីភូមិភាគ៣០៤ ហ្នឹង ឆ្នាំ១៩៧៧ រហូតមក។

**ស៖** អរគុណលោក។ តើអ្នកណាជាអ្នកគ្រប់គ្រងច្រាំងចំរេះ?

**ផ៖** ច្រាំងចំរេះជាផ្នែកខាងដាំដុះស្រូវ និងបន្លែបង្កាបន្តិចបន្តួច។ តាមខ្ញុំចាំអ្នកគ្រប់គ្រងនោះឈ្មោះ តាជាង គេហៅថា តាជាងៗ ប្រពន្ធគាត់ឈ្មោះ សើ។ នៅក្រោមក្រសួងការបរទេសនេះ មានខ្ញុំ និងមាន ជាម លោក ជាម។

**ស៖** អរគុណលោក។ តើលោក អៀង សារី បានសម្រេចតែងតាំងលោកឲ្យទៅគ្រប់គ្រងនៅច្រាំងចំរេះមែនទេ?

**ផ៖** បាទ ជួយមើលការខុសត្រូវនៅច្រាំងចំរេះ។

**ស៖** អរគុណលោក។ តើលោកអញ្ជើញទៅមើលការខុសត្រូវទីនោះនៅឆ្នាំណាដែរលោក?

**ផ៖** តាមខ្ញុំ ឆ្នាំ១៩៧៧ បែបចុងឆ្នាំ១៩៧៧ បាទ។

[១៤:៣៣:៤៧]

**ស៖** អរគុណលោក។ តើអ្នកណាខ្លះដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក? មានប៉ុន្មាននាក់នៅទីនោះចាស?

**ផ៖** តាមខ្ញុំចាំ មិនដល់១០០នាក់ទេបាទ ប្រហែលជា៧០នាក់អី លើសល្អសបន្តិចបន្តួចបាទ។

**ស៖** ក្រៅពីលោកដែលជាអ្នកគ្រប់គ្រងនៅច្រាំងចំរេះ តើមានអ្នកណាទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រង ការទទួលខុសត្រូវរបស់លោក? ពេលដែលលោកមិននៅ-- លោកនៅក្រសួងការបរទេស តើអ្នកណាអ្នកមើលការខុសត្រូវនៅទីនោះចាស?

**ឆ៖** គឺមានលោក ជាម។

**ស៖** អរគុណលោក។ តើចំនួនមនុស្សទាំងអស់សរុបនៅទីនោះប៉ុន្មានដែរចាស?

**ឆ៖** ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង គឺមិនលើសពី៧០នាក់ទេ តាមមើល។

**ស៖** តើគេធ្វើអីនៅទីនោះលោក?

**ឆ៖** ធ្វើស្រែ និងដាំបន្លែ និងចិញ្ចឹមត្រី។

**ស៖** អរគុណលោក។ តើនេះជាផ្នែកមួយរបស់ក្រសួងការបរទេសមែនទេលោក?

**ឆ៖** បាទ ចាប់ផ្ដើមពីឆ្នាំ១៩៧៧ មក ជាផ្នែកមួយនៃក្រសួងការបរទេស។

**ស៖** អរគុណលោក។ តើសមាសភាពមនុស្សដែលរស់នៅទីនោះចេញមកពីកន្លែងណាខ្លះចាស?

**ឆ៖** គឺជាសមាសភាពរបស់ភូមិភាគ៣០៤ ដែលនៅទីនោះស្រាប់បាទ។

[១៤:៣៦:២៥]

**ស៖** អរគុណលោក។ តើនៅទីនោះមានបញ្ហាជននៅទេចាស?

**ឆ៖** ពេលដែលខ្ញុំគ្រប់គ្រងមិនមានបញ្ហាជនទេ។

**ស៖** តើនៅទីនោះ អ្នកដែលនៅទីនោះភាគច្រើនជាប្រជាជនថ្មី ឬក៏ជាប្រជាជនចាស់?

**ឆ៖** ភាគច្រើនជាប្រជាជនថ្មី-- អ៎! ប្រជាជនចាស់បាទ ដែល ៣០៤ គេផ្ដល់មក។

**ស៖** អរគុណលោក។ លោកខ្ញុំចង់ឲ្យលោកបញ្ជាក់ តើប្រជាជន-- ខ្ញុំនៅគេនិយាយថា មានប្រជាជនថ្មី ហើយនិងប្រជាជនចាស់ តើប្រជាជនទាំងពីរហ្នឹងវាមានការខុសគ្នាម៉េចដែរចាស់?

**ឆ៖** បងប្អូនដែលនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ គឺភាគច្រើន គឺមូលដ្ឋានបញ្ជូនមក មិនមានអំពាវនាវអីចូលមកទេ។ គឺខាងលើបញ្ជូនមកទេ មិនមែនខ្ញុំជាអ្នកជ្រើសរើសៗតាមដូចសម័យ*អ៊ីនធឺណេត*អ៊ីចឹង រើសអីអ៊ីចឹងទេ! គេបញ្ជូនមកពីខាងលើ បញ្ជូនមកពីមូលដ្ឋាន។ ពេលដែលចូលមក អារម្មណ៍ខ្ញុំដឹកនាំនេះ អត់មានថា អ្នកឯងប្រជាជនចាស់ ឬប្រជាជនថ្មីទេ។ គឺចូលមក គឺជាប្រជាជនតែមួយធម្មតាដូច្នេះក្នុងការដឹកនាំរបស់ខ្ញុំពេលនោះ អត់មានបែងវណ្ណៈទេ។ កន្លែងណាគេបែងវណ្ណៈអីផ្សេងៗ ខ្ញុំអត់បានដឹងទេ។ ឯចំពោះខ្ញុំអត់មានបែងវណ្ណៈអ៊ីចឹងទេ។ ខ្ញុំអត់យល់។ បាទសូមមានប៉ុណ្ណោះបាទ។

[១៤:៣៩:១៦]

**ស៖** សូមអរគុណលោក។ ហេតុអ្វីបានជានៅច្រាំងចំរេះ គេយកតែពីប្រជាជនចាស់ដាក់នៅទីនោះចាស?

**ឆ៖** បាទ ប្រហែល ខ្ញុំប្រហែលទេ ប៉ុន្តែប្រហែលហ្នឹងក៏បែបជាត្រូវដែរ ដើម្បីឲ្យស្អាត ក្បែរភ្នំពេញកុំឲ្យមានអ្វីជាអសន្តិសុខ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី! អរគុណសាក្សី។ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅទីកន្លែងសម្រាកសម្រាប់សាក្សីដែលបានរៀបចំទុករួចហើយ ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីបន្ត។

សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល និងសូមគោរពជាថ្មីម្តងទៀតលោកសាក្សី។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អម្បាញ់មិញយើងមកដល់កន្លែងច្រាំងចំរេះ ដូច្នេះសូមបន្តជាមួយលោកសាក្សីបន្តិចទៀត

នៅលើវិន័យរបស់ច្រាំងចំរេះ។ តើនៅច្រាំងចំរេះលោកអាចបញ្ជាក់បានទេថា អ្នកដែលនៅច្រាំងចំរេះហ្នឹងអាចដើរចេញចូលរហេតរហូតដោយសេរីបានទេចាស?

**លោក សាឡុត បាន៖**

**ឆ៖** បាទ អ្នកនៅច្រាំចំរេះដើររហេតរហូតអត់បានទេ នៅតែក្នុងបរិវេណរបស់ខ្លួនឯង។

**ស៖** អរគុណលោក។ ចុះចំពោះការហូបចុកវិញយ៉ាងម៉េចដែរចាស?

**ឆ៖** ចំពោះការហូបចុកជាគោលការណ៍ គឺខ្លួនឧបត្ថម្ភខ្លួន ខ្វះខាតអ្វីផ្សេងដែលមិនអាចធ្វើបាន និងខាងផ្នែកផ្សេងទៀតគេឧបត្ថម្ភ។

[១៥:០៣:៣៣]

**ស៖** អរគុណលោក។ តើនៅទីនោះ ការហូបចុកមានជារួមអីលោក?

**ឆ៖** បាទ ជារួម។

**ស៖** អរគុណលោក។ នៅទីនោះបើសិនជាមានអ្នកប្រព្រឹត្តខុសវិន័យ ឬក៏រឹងទទឹង តើនៅមន្ទីរច្រាំងចំរេះហ្នឹងមានវិធានការបែបណាដែរលោក?

**ឆ៖** នៅច្រាំងចំរេះមានការប្រជុំកសាងគ្នា។ ពេលដែលខ្ញុំទៅនៅច្រាំងចំរេះ ដោយបង អៀង សារី ឲ្យខ្ញុំទៅជួយមើលការខុសត្រូវនៅទីនោះ ខ្ញុំបានប្រជុំការងារសតិអារម្មណ៍ និងការងារបង្កបង្កើនផល ឲ្យគេយល់អំពីភារកិច្ចរបស់ខ្លួន។ ពេលនោះ មិនមានអ្វីជា-- មានបងប្អូន គ្មានអ្វីជាកំហុសអីដែលចាប់អារម្មណ៍ឲ្យខ្ញុំចាប់អារម្មណ៍ ថាជាជនប្រឆាំងទេ។

**ស៖** សូមអរគុណលោក។ តើលោកដែលគ្រប់គ្រងនៅច្រាំងចំរេះ លោកតែងរាយការណ៍ជាប្រចាំជូនលោក អៀង សារី ទេចាស?

**ឆ៖** បាទ ខ្ញុំតែងរាយការណ៍ជាប្រចាំទៅលោក។

**ស៖** អរគុណលោក។ តើលោក អៀង សារី ធ្លាប់ទៅនោះញឹកញាប់ទេចាស?

**ឆ៖** ពេលដែលខ្ញុំទៅជួយការងារនៅទីនោះ លោក អៀង សារី មិនបានទៅញឹកញាប់ទេ។ កាលៈទេសៈនោះ លោករវល់ទៅក្រៅប្រទេសញឹកញាប់។

[១៥:០៦:៣៧]

**ស៖** សូមអរគុណលោក។ តើ-- សូមលោករំឭកឡើងវិញមើល តើលោក អៀង សារី ដែលអត់ដែលទៅសោះច្រាំងចំរេះ ឬមួយក៏ធ្លាប់ទៅម្ដងម្កាលដែរចាស?

**ឆ៖** ពេលដែលខ្ញុំទៅជួយការងារទីនោះ ខ្ញុំមិនបានឃើញលោកទៅញឹកញាប់ទេ។ ប៉ុន្តែមុននឹងខ្ញុំទៅទទួលនៅទីនោះ ច្រាំងចំរេះដែលនៅជាមួយ គេហៅថា ក្នុងភូមិភាគនៅឡើយ លោក អៀង សារី និងខ្ញុំនាំភ្ញៀវចុះឡើងកាត់ទីនោះ លោកចូលទៅពិសាបាយនៅទីនោះពីរបីដងដែរ។

**ស៖** ពេលដែលលោកទៅ តើលោកមានដែលប្រជុំរៀនសូត្រ គោលនយោបាយដល់បងប្អូនដែលនៅទីនោះទេចាស?

**ឆ៖** នៅទីនោះ ខ្ញុំទៅប្រជុំ ប៉ុន្តែប្រជុំមិនជាធំដុំទេ។ ប្រជុំដកពិសោធន៍ការងារតែប៉ុណ្ណោះ។

**ស៖** សូមលោក--

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន ខ្ញុំសូមអញ្ញាតឲ្យអ្នកជំនួយការ ជួយបង្ហាញឯកសារលេខ D369/36 ចាស។ ចំណុចសួរលេខ ៩៤ ចាស។

[១៥:០៨:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកជំនួយការដាក់បញ្ចាំងឯកសារ នៅលើកញ្ចក់អេក្រង់កុំព្យូទ័រ!

**លោកស្រី ជេត វណ្ណលី៖**

សូមទោសលោកប្រធាន ចំណុច១០៦ ចាស ១០៦ មិនមែន៩៤ ទេចាស។ សំណួរឆ្លើយ។

ខ្ញុំសូម-- លោកប្រធានខ្ញុំសូមអនុញ្ញាតអាន។ សូមអរគុណចាស។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** "សំណួរ៖ ចំពោះអ្នកដែលប្រព្រឹត្តខុស តើមានទណ្ឌកម្មអ្វីខ្លះ? ឆ្លើយ៖ ជំនាន់នោះ គឺមានការប្រជុំរាល់ថ្ងៃ ពេលដែលមានបញ្ហាមិនធម្មតា ប្រធានមន្ទីរនឹងធ្វើរាយការណ៍មកខាងលោក អៀង សារី ប៉ុន្តែអំពើប្រព្រឹត្តខុស មិនមានយកទៅធ្វើទោសអ្វីទេ។ បញ្ហាមិនធម្មតា គឺសំដៅទៅលើរឿងដែលមានការចោទប្រកាន់ពីខាងក្រៅថា អ្នកច្រាំងចំរេះជាប់ខ្សែខ្មាំង"។ សូមអរគុណ។

នៅលើចំណុចនេះ ខ្ញុំសូមឲ្យលោកសាក្សីបញ្ជាក់ថា តើប្រធានមន្ទីរនេះជាអ្នកណាចាសលោក?

[១៥:១០:៤៦]

**ឆ៖** ប្រធានមន្ទីរនៅពេលនោះ តាមខ្ញុំចាំគឺលោក ឈ្មោះ តាជាង បាទ តាជាង ហើយប្រពន្ធគាត់ឈ្មោះ សើ។

**ស៖** សូមអរគុណលោក។ ហើយខ្ញុំសូមឲ្យលោកបញ្ជាក់មួយចំណុចទៀតដែរ គឺបញ្ហាមិនធម្មតា តើមានន័យម៉េចទៅចាសបញ្ហាមិនធម្មតា?

**ឆ៖** បញ្ហាមិនធម្មតា បានន័យថា ខ្ញុំប្រជុំទៅ ឬមួយ តាជាង ដែលជាប្រធានមន្ទីរហ្នឹងប្រជុំមនុស្សហ្នឹងអត់មានបញ្ហាទេ ដល់គេចោទមកគេថាមានបញ្ហា នេះហើយដែលហៅថា មិនធម្មតា។

**ស៖** សូមអរគុណលោក។ ខ្ញុំសូមសួរមួយចំណុចទៀតចាស អ្ហឺ! អ្នកច្រាំងចំរេះជាប់ខ្សែខ្មាំង តើមានន័យថាម៉េចដែរអាហ្នឹង? អរគុណ។

**ឆ៖** ពាក្យថា ធម្មតា ខ្ញុំក៏មិនសូវយល់ដែរ ពីព្រោះខ្ញុំធ្វើទៅវាធម្មតា ដល់គេចោទមកថា មិនធម្មតា។ ដូច្នេះ គេថាមិនធម្មតាហ្នឹងជាខ្សែខ្មាំងនុំងឯងបាទ។

[១៥:១២:៤៨]

**ស៖** ខ្ញុំសូមអរគុណលោក។ ហើយខ្ញុំមានសំណួរពីរទៀតចុងក្រោយ មុននឹងប្រគល់ទៅឲ្យមេធាវីអន្តរជាតិចាស។ តើលោកស្គាល់លោក ហួត សម្បត្តិ ទេចាស?

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះ មិនស្គាល់មុខ ហើយក៏មិនដែលបានជួប។

**ស៖** អរគុណលោក។ តើនៅក្នុងសម័យ លន់ នល់ និងសម័យ សីហនុ តើលោក ហួត សម្បត្តិ ធ្វើអីដែរលោក?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** អរគុណលោក។ ខ្ញុំសួរសំណួរមួយជាសំណួរចុងក្រោយរបស់ខ្ញុំ តើលោកបានដឹងទេពីការចាប់ខ្លួនរបស់លោក ហួត សម្បត្តិ ពីច្រាំងចំរេះ នៅឆ្នាំ១៩៧៦ ចាស?

[១៥:១៤:១០]

**ឆ៖** ឆ្នាំ១៩៧៦ ខ្ញុំអត់ដឹងរឿងរ៉ាវអីនៅក្នុងច្រាំងចំរេះទេលោក។

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ដោយពេលវេលាមានកំណត់ ខ្ញុំសូមប្រគល់ជូនសហភាតាអន្តរជាតិដើម្បីសួរសំណួរបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១៥:១៥:០០]

**លោកស្រី អេលីហ្សាបេត វ៉ាបេសាន់ជ្រាតាណា៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមទាំងអស់។ សូមគោរពមេធាវីការពារក្តី។ ជម្រាបសួរលោកសាក្សី។ ខ្ញុំជាមេធាវីអន្តរជាតិដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ យោងទៅតាមពេលវេលាខ្លី ខ្ញុំនឹងព្យាយាមសួរដោយខ្លី។ ជាដំបូង ខ្ញុំសូមចាប់ផ្តើមពីសំណួរដើម្បីទទួលការបំភ្លឺពីលោក ពាក់ព័ន្ធទៅនឹងដំណើរការទូទៅ។ ប៉ុន្មានថ្ងៃមកនេះលោកបាននិយាយអំពីដំណើរការនៅក្រសួងការបរទេស ហើយនិងនៅមន្ទីរដែលនៅចំណុះឲ្យក្រសួង។ បន្ទាប់មកទៀត ខ្ញុំនឹងនិយាយអំពីករណីមនុស្សមួយចំនួន។ ជាពិសេស ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងតំណាងឲ្យ ហើយយើងជាអ្នកនាំពាក្យឲ្យពួកគាត់។ ចំពោះសំណួរបំភ្លឺ ខ្ញុំមានសំណួរដំបូងគេ ប្រសិនបើខ្ញុំនិយាយលឿនពេកនោះ សូមឲ្យលោកប្រាប់ខ្ញុំផង។

**សួរដោយលោកស្រី អេលីហ្សាបេត វ៉ាបេសាន់ជ្រាតាណា៖**

**ស៖** សំណួរទីមួយ ពាក់ព័ន្ធនឹងចំណុចមួយដែលត្រូវបានពិភាក្សារួចមកហើយ ដោយសហភាតារបស់ខ្ញុំ គឺការស្លាប់ដោយការច្របាច់ក គឺការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់។ ឥឡូវនេះ យើងដឹងអំពីអង្គហេតុ ហើយនិងស្ថានភាពនោះហើយ។ សំណួររបស់ខ្ញុំមានដូចតទៅនេះ៖ តើមានការដាក់ពិន័យអ្វីចំពោះ ប៉ង់ ទេ ចំពោះការស្លាប់នេះ?

[១៥:១៧:០១]

**លោក សាឡុត បាន៖**

**ឆ៖** ពេលនោះ ខ្ញុំឃើញថា មិនទាន់មានដាក់វិន័យទេ ប៉ង់ នៅជា ប៉ង់ រហូត។ ក្រោយមកបានឮថា ប៉ង់ បាត់ខ្លួន។ បាត់ខ្លួនរឿងអី ក៏ខ្ញុំមិនដឹងដែរ បាទ។

**ស៖** សូមអរគុណ។ តើលោកគិតថា មានទំនាក់ទំនងរវាងការបាត់ខ្លួនរបស់ ប៉ង់ ហើយនិងរឿងហេតុដែលពាក់ព័ន្ធទៅនឹងការស្លាប់របស់លោកស្រី ខៀវ ធីរ៉ាត់ ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំៗអាលឆ្លើយតបនឹងសំណួរ។ សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវ៉ាស!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ជាគោលការណ៍ លោកសាក្សីគាត់បានលើកឡើងហើយថា គាត់មិនដឹងអំពីហេតុការណ៍ដែល ប៉ង់ បាត់ខ្លួន។ ដូច្នេះ នៅពេលនេះ ហាក់ដូចជាមេធាវីសួរឲ្យធ្វើការ

សន្និដ្ឋាន។ យើងមិនអាចឲ្យសាក្សីទាញការសន្និដ្ឋាន សន្មតណាមួយនោះទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅលើការសួរសំណួរបែបនេះ។ ហើយយើងក៏មិនសួរសាក្សីណាម្នាក់ឲ្យគាត់ធ្វើសេចក្ដីសន្និដ្ឋាន ឬសន្មតនោះទេ។ សូមអរគុណ។

[១៥:១៨:៤០]

**លោកស្រី អេលីហ្សាបេត វ៉ាបេសាន់ដ្រាតាណា៖**

លោកប្រធាន ខ្ញុំមានការកត់សម្គាល់ពីរ។ សាក្សីបានឆ្លើយថា មានពីរចំណុច គឺថាមិនមានការដាក់វិន័យអីទេ។ ហើយទីពីរ គឺខ្ញុំកត់សម្គាល់ឃើញថាបន្ទាប់មក គឺលោក ប៉ង់ បាត់ខ្លួន។ ខ្ញុំគិតថា មិនមែនជាការព្រាវៗស្មានអ្វីទេ គឺខ្ញុំព្យាយាមធ្វើការសំយោគទៅលើចំណុចនេះ។ ដូច្នេះ នេះមិនមែនជាការសួរសំណួរឲ្យសាក្សីស្មានៗនោះទេ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីការពារក្ដីមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរអម្បាញ់មិញនេះទេ។

**សួរដោយលោកស្រី អេលីហ្សាបេត វ៉ាបេសាន់ដ្រាតាណា៖**

**ស៖** ខ្ញុំនឹងចោទសួរសំណួរផ្សេងទៀតទៅកាន់លោក និយាយអំពីបឹងត្របែក។ លោកបាននិយាយថា លោកបានទៅប្រាប់ប៉ង់ ឲ្យយកចិត្តទុកដាក់ចំពោះបញ្ញវន្តដែលឈ្មោះ ឃួន ដារីដ បន្ទាប់ពីឃើញគាត់នៅបឹងត្របែក។ ដូច្នេះលោកបានប្រាប់យើងថា លោកបានទៅបឹងត្របែកមុនពេលចាប់ខ្លួនប៉ង់។ ក៏ប៉ុន្តែលោកក៏បាននិយាយថា មិនមានទំនាក់ទំនងគ្នាទេ រវាងក្រសួងការបរទេស និងមន្ទីរបឹងត្របែកមុនពេលចាប់ខ្លួន ប៉ង់។ តើលោកអាចពន្យល់បានទេថា លោកទៅបឹងត្របែកនៅពេលដែលបឹងត្របែកស្ថិតនៅក្រោមអំណាចរបស់ ប៉ង់? ហើយហេតុអីបានជាលោកអាចទៅអ៊ីចឹងបាន?

**ឆ៖** ពេលដែលជួបប៉ង់ ពីរឿង ឃួន ដារីដ ខ្ញុំមិនជួបប៉ង់ នៅបឹងត្របែកទេ គឺជួប ប៉ង់ នៅកន្លែងណាមួយខ្ញុំមិនចាំ។ មិនមែនជាក្រសួង មិនមែនជាអីទេ ដូចតែនៅតាមផ្លូវ ឬមកជួបគ្នាត្រង់ណាកន្លែងគេហៅថា ទទួលភ្ញៀវ។ ខ្ញុំបានសួរទីនោះ ខ្ញុំមិនទៅ-- ខ្ញុំមិនជួបនៅបឹងត្របែកទេ។ ខ្ញុំផ្ដាំផ្ញើថាមើល ឃួន ដារីដ ផង តើយ៉ាងណាៗ ពីព្រោះខាងលើចង់បាន។ នេះមិនមែនជួបនៅបឹងត្របែកទេបាទ។

[១៥:២២:៣៦]

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកបានទៅបឹងត្របែកមុនពេលវៀតណាមចូល

មកដល់ គឺទៅទីនោះ ដើម្បីជម្លៀសៗទាហាននៅបឹងត្របែក។ តើលោកមានអំណាចអីទៅលើយោធាទាំងអស់នេះ? តើជាសមាជិកសន្តិសុខរបស់ក្រសួង ឬក៏ជាអង្គភាពការពាររបស់ក្រសួង?

**ប្រធានអង្គជំនុំ៖**

មេធាវី-- សាក្សីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកមេធាវីការពារក្តី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំកាត់សំណួរ។ ខ្ញុំដូចជាមិនចាំដែលថា សាក្សីឆ្លើយថា គាត់ទៅគ្រប់គ្រង ទៅប្រមូលទាហាន ទៅជម្លៀសទាហាន។ ខ្ញុំដូចជាចាំថា គាត់មិនបាននិយាយដូច្នេះនោះទេ ហើយយើងក៏មិនមានប្រតិចារឹកណាមួយបង្ហាញចំណុចនេះដែរ។ ខ្ញុំមិនចង់ឲ្យមេធាវីសួរសំណួរនេះទេ ដោយសារតែសាក្សីនោះគាត់មិនបានឆ្លើយថាគាត់បានទៅកន្លែងនោះដើម្បីធ្វើការជម្លៀសទាហាននោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:២៤:១៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានកត់ត្រាទុក ហើយខ្ញុំការ-- ហើយខ្ញុំបានកត់ត្រាច្បាស់ណាស់ គាត់ថាគាត់បានទៅបឹងត្របែកពីរដងជាមួយ អៀង សារី ហើយទៅពីរដងតែម្នាក់ឯង។ ហើយម្តងគាត់ទៅដើម្បីជម្លៀសទាហាននៅបឹងត្របែកមុនពេលវៀតណាមចូលមកដល់។ ខ្ញុំបានកត់ច្បាស់ណាស់លោកប្រធាន សាក្សីបានឆ្លើយអ៊ីចឹងមែន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំ គឺថាគ្រាន់តែជួយអន្តរាគមន៍ ដើម្បីសម្រួលចំពោះការយល់ច្រឡំនេះ។ តាមខ្ញុំស្តាប់បានមិនមែនសាក្សីថាទៅជម្លៀសទាហានទេ គឺគាត់ទៅជម្លៀសអ្នកដែលជាបញ្ញាជននៅទីនោះបាទ។ អ៊ីចឹងសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីការពារក្ដីមានប្រសិទ្ធភាព។ មិនមានចម្លើយសាក្សីឆ្លើយថាខ្លួនហ្នឹងបានទៅជម្លៀសទាហាននៅតំបន់បឹងត្របែកទេ។ គាត់ពិតជាបានទៅប្អូនដង ពីរដងទៅដោយតែម្នាក់ឯង ហើយនិងពីរដងទៀតទៅជាមួយលោក អៀង សារី មែន។ ប៉ុន្ដែគោលបំណងចុងក្រោយដែលគាត់ទៅហ្នឹងគឺមានសំណួររហូតដល់ពីរបីដងឯណោះ គឺគាត់ទៅរៀបចំដើម្បីជម្លៀសបញ្ញាជននៅបឹងត្របែកហ្នឹង ដើម្បីធ្វើដំណើរចាកចេញចៀសផុតពីការវាយលុករបស់វៀតណាមចូលទីក្រុងភ្នំពេញ បានន័យថាហៀបនឹងដល់ហើយក៏ចាត់ចែងរៀបចំធ្វើដូច្នេះ។

[១៥:២៦:៣០]

**លោកស្រី អេលីហ្សាបេត ស៊ីបេសាន់ដ្រាតាណា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់-- ខ្ញុំគិតថា ឯកសារជាភាសាបារាំងនុ៎ង គឺថាមើលទៅដូចជាមិនត្រូវហ្នឹងឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេសទេ។ ដូច្នេះ សូមពិនិត្យមើលករណីនេះ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីបេសាន់ដ្រាតាណា៖**

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងបញ្ហានៃដំណើរការជាទូទៅ គឺនិយាយអំពីតួនាទីរបស់ការិយាល័យ-- របស់មន្ទីរ៨៧០ តើលោកឃើញ ប៉ង់ ជាញឹកញាប់ទេនៅមន្ទីរ៨៧០?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំឃើញ ប៉ង់ នៅ៨៧០ ញឹកញាប់បាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ញឹកញាប់កម្រិតណាដែរ? តើមួយថ្ងៃម្ដង ឬក៏មួយសប្ដាហ៍ម្ដង?

**ឆ៖** ខ្ញុំនៅក្រសួងការបរទេស។ ពេលដែលខ្ញុំទៅដូចជា ឧទាហរណ៍មួយខែទៅពីរដងអីហ្នឹង ខ្ញុំឃើញលោក ប៉ង់ នៅទីនោះ។ ប៉ុន្ដែលោក ប៉ង់ តាមខ្ញុំដឹង គាត់ដើរចល័តគ្រប់កន្លែង ដែលញឹកញាប់នុ៎ងគឺឃើញនៅគ្រប់កន្លែងដែលខ្ញុំឃើញ។ គឺថាជួបញឹកញាប់ហ្នឹង គឺគ្រប់កន្លែង។ ជួនកាលឃើញគាត់នៅក្រសួង ៨៧០ ទៅ ជួនកាលឃើញគាត់នៅជួបជុំទាហានកងទ័ពអីនេះណោះទៅ ដូចជាកម្មាភិបាលមួយចល័តរបស់ ៨៧០។

[១៥:២៩:២៣]

**ស៖** តើភារកិច្ចចល័តហ្នឹងយ៉ាងម៉េចដែរ? ជាពិសេសភារកិច្ចរបស់ ប៉ង់?

**ឆ៖** ខ្ញុំសូមជម្រាបថា ដូចជាមានសិទ្ធិណ៎ះ! មានសិទ្ធិទៅណាក៏បាន មានសិទ្ធិខ្ពស់ណាស់ទៅណាក៏បានដែរ។ ចូលកន្លែងណាក៏បាន។ នេះហើយដែលថា ចល័តគ្រប់កន្លែងបានបាទ។

**សៈ** សូមអរគុណ។ តើលោកៗអាចមានសិទ្ធិដើរហើរសេរីនៅទូទាំងប្រទេសអ៊ីចឹងមែនទេ?

**ឆ៖** លោកៗ ប៉ង់ អ៊ីចឹង? សូមសួរថាលោក ប៉ង់ ឬយ៉ាងណា? ឬសួរខ្ញុំ ខ្ញុំស្តាប់អត់ច្បាស់។

**សៈ** សូមទោសខ្ញុំនិយាយអំពី ប៉ង់ គឺក្នុងក្របខ័ណ្ឌជាមន្ទីរចល័ត ចង់និយាយថា គាត់មានសិទ្ធិដើរហើរដោយសេរីនៅទូទាំងប្រទេសឬ?

**ឆ៖** បាទ តាមខ្ញុំដឹងគាត់មានសិទ្ធិដើរសេរីមិនទូទាំងប្រទេសទេ គឺដើរសេរីបានក្របខ័ណ្ឌភ្នំពេញ។

**សៈ** តើអ្នកណាជាប្រធានគណៈកម្មាធិការ បន្ទាប់ពីចាប់ខ្លួន ប៉ង់ ទៅ?

[១៥:៣១:៣៥]

**ឆ៖** តើប្រធានគណៈកម្មាធិការអី?

**សៈ** គឺខ្ញុំចង់សំដៅទៅដល់មន្ទីរ៨៧០។

**ឆ៖** ប្រធានគណៈកម្មា-- ប្រធានមន្ទីរៗ គឺ ប៉ង់ នេះឯង ឯ៨៧០ មានលោក ប៉ុល ពត មានលោក នួន ជា អីជាដើម ដែលលោកទាំងអស់គ្នាបានដឹងហើយ ខ្ញុំមិនបានរៀបទេបាទ។

**សៈ** សំណួររបស់ខ្ញុំចង់ដឹងថា តើអ្នកណាមកជំនួស ប៉ង់ នៅពេលដែល ប៉ង់ បាត់ខ្លួន?

**ឆ៖** ខ្ញុំអត់បានដឹងទេពេលនោះ។

**សៈ** ហើយចុះថ្ងៃនេះ តើលោកដឹងទេ?

**ឆ៖** ថ្ងៃនេះក៏ខ្ញុំអត់ដឹង ពេលដែល ប៉ង់ ទៅគឺចលាចលហើយ។ ខ្ញុំមិនសួរនាំអ្នកណាជាប្រធានអ្នកណាទេ ខ្ញុំរកតែរួចខ្លួនរបស់ខ្ញុំដែរ។ ខ្ញុំរៀបចំមន្ទីររបស់ខ្ញុំដែរ ធ្វើម៉េចរៀបរយក្រសួង រៀបរយសមាជិករបស់ក្រសួងរបស់ខ្ញុំឱ្យរួចផុតពីការវៀតណាមចូលលុក។

[១៥:៣៤:១៣]

**សៈ** តើមានន័យថា តាមពិតទៅ គឺថាលោកទទួលខាងផ្នែកចាត់តាំងជំនួស ប៉ង់ នៅក្នុងមន្ទីរនេះមែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថាៗ "លោក" ហ្នឹងគឺខ្ញុំ ឬអ្នកណា?

**សៈ** ពិតហើយ គឺខ្ញុំសំដៅដល់លោក ពីព្រោះខ្លួនឯងផ្ទាល់នោះ លោកបានបញ្ជាក់ថាលោកមិនចង់ដឹងថាអ្នកណាជំនួសគាត់ទេ គឺលោកៗគិតតែពីរឿងរៀបចំ ហើយនិងគ្រប់គ្រងមន្ទីររបស់លោក

ដើម្បីឲ្យបានដំណើរការល្អនៅពេលដែលមានភាពរឹករវនោះ គឺថាដូចនៅពេល-- ព្រោះថាពេលនោះ គឺវៀតណាមបានជិតចូលមកដល់ហើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាមានបញ្ហាពាក់ព័ន្ធនឹងការបកប្រែ តាមភាសាអង់គ្លេស គឺមានលក្ខណៈខុសពីអ្វីដែលមេធាវី រៀបចំសំណួរទៅកាន់សក្ខីកម្មរបស់សាក្សី។ ប្រហែលជាលោកស្រីនោះចង់រៀបចំសំណួរសួរឡើងវិញ ឬក៏យ៉ាងណា? សាក្សីមិនដែលនិយាយថា មិនដែលនិយាយដូចដែលអ្វីដែលមេធាវីគាត់បានចង្អុលយោងអម្បាញ់មិញនោះទេ។

[១៥:៣៦:១៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**លោកស្រី អង់តា ហ្គីស៖**

លោកប្រធាន បើខ្ញុំសូមគាំទ្រការជំទាស់នេះ ព្រោះខ្ញុំស្តាប់ជាភាសាបារាំងដែរ ហើយក្នុងជាភាសាបារាំងនោះ មិនមាននិយាយអំពីការជំនួសមន្ទីរ៨៧០នោះទេ គឺថាគាត់គិតគូរតែពីមន្ទីររបស់គាត់នោះទេ។ ដូច្នេះត្រូវតែបំភ្លឺបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់ក្រុមមេធាវីការពារក្តីមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរចុងក្រោយនេះទេ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចកែសម្រួលនូវសំណួរឲ្យបានត្រឹមត្រូវ ហើយនិងជាក់ច្បាស់ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីតាំងសំណួរចំពោះសាក្សី។

[១៥:៣៧:១៦]

**លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំនឹងមិនចោទសំណួរនេះឡើងវិញទេ។ ចម្លើយរបស់សាក្សីអម្បាញ់មិញនេះ គឺថាជួយបំភ្លឺខ្ញុំហើយ ព្រោះគាត់បាននិយាយថា ពុំមានអ្នកណាជំនួស ប៉ង់ ដើម្បីគ្រប់គ្រងគណៈកម្មការនោះទេ។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីទិដ្ឋភាពជាលក្ខណៈបុគ្គលជាង ពីព្រោះថាយើងទាំងអស់គ្នាជាអ្នកតំណាង

ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលព្យាយាមយល់ស្ថានភាព ហើយនិងកាលៈទេសៈដែលសមាជិកគ្រួសាររបស់ជនរងគ្រោះទាំងអស់នេះបានបាត់ខ្លួន ហើយជាទូទៅនោះ គឺថាក្រោយពីមានការអំពាវនាវអំពីសំណាក់ជនជាតិខ្មែរនៅប្រទេសខ្មែរ ដើម្បីឱ្យគាត់ចូលមកប្រទេសកម្ពុជាវិញ ហើយខ្ញុំសូមអរគុណដល់សាក្សីក្នុងការជួយរកការពិត ឱ្យជនរងគ្រោះទាំងអស់នោះ។ ដូច្នេះខ្ញុំសូមលើកករណីមួយចំនួន ដែលជានិមិត្តរូប ហើយនិងសូមពិចារណាជាមួយលោក បើសិនជាករណីទាំងអស់នេះថាលោកដឹងរឿងអីខ្លះ ឬក៏ចង់ធ្វើការកត់សម្គាល់អ្វីមួយទៅលើខ្សែជីវិតរបស់ជនរងគ្រោះទាំងអស់នេះ។

ខ្ញុំនឹងបង្ហាញរូបថតមួយចំនួន ហើយបើសិនជាអង្គជំនុំជម្រះអនុញ្ញាត។

[១៥:៣៨:៥១]

**សួរដោយលោកស្រី អេលីហ្សាបេត វ៉ាបេសាន់ជ្រាតាណា៖**

**ស៖** បុគ្គលទីមួយដែលខ្ញុំចង់បង្ហាញជូនលោកនេះ គឺលោក ចៅ សេង។ តើលោកស្គាល់លោក ចៅ សេង នេះទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីឱ្យអត្តសញ្ញាណឯកសាររូបថតនុ៎ងមក តើវាលេខអត្តសញ្ញាណលេខប៉ុន្មាន។ ជារូបថតដែលមាននៅក្នុងសំណុំរឿងក្តីដែរឬទេ?

**លោកស្រី អេលីហ្សាបេត វ៉ាបេសាន់ជ្រាតាណា៖**

ន៎ែបានបញ្ចូលក្នុងសំណុំរឿងហើយ យោងគឺ D22289.12។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអំពីសំណាក់លោកប្រធាន ដើម្បីបង្ហាញរូបថតនេះទៅលើអេក្រង់លោកប្រធាន។

[១៥:៤០:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

បើកក្បាលមីក្រូនិយាយ! ពេលវេលាដូចជាកាន់តែលឿនហើយ ធ្វើឱ្យរអាក់រអួលបន្តបន្ទាប់អ៊ីចឹង។

**សួរដោយលោកស្រី អេលីហ្សាបេត វ៉ាបេសាន់ជ្រាតាណា៖**

**ស៖** ក្នុងរូបថតនេះ ដែលបានថតនៅក្នុងសន្និសីទកាសែត នៅទីក្រុងប៉ារីសនៅឆ្នាំ១៩៧១។ លោក ចៅ សេង បានខ្ញុំសូមអភ័យទោស បើសិនជាខ្ញុំអានឈ្មោះមិនច្បាស់ នៅពេលដែលគាត់ឆ្លើយទៅ

នឹងអ្នកកាសែត ដែលកាន់មីក្រូទាំងអស់នេះ ហើយនៅជិតគាត់គឺមានព្រះអង្គម្ចាស់ នរោត្តម សីហនុ។ សំណួររបស់ខ្ញុំសាមញ្ញបំផុត តើលោកស្គាល់បុគ្គលនេះទេ ហើយស្គាល់ឈ្មោះ ចៅ សេង នេះទេ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំស្គាល់ឈ្មោះ ចៅ សេង តាមកាសែត តាមអី ប៉ុន្តែរូបនេះ ខ្ញុំអត់ស្គាល់ទេបាទ។

[១៥:៤១:៥០]

**ស៖** សូមអរគុណ។ តើលោកចាំបានដែរទេថាតើនៅពេលណា ដែលបុគ្គលរូបនេះបានមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ។

**ស៖** ដូច្នេះលោកមិនបានទៅទទួលគាត់ទេឬ នៅពោធិ៍ចិនតុងនោះ?

**ឆ៖** បាទ ខ្ញុំអត់បានទៅទទួលគាត់ទេ។

**ស៖** តើពេលក្រោយមក តើលោកដឹងថា បុគ្គលរូបនេះត្រូវបានបញ្ជូនទៅទីណាដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។

**ស៖** បុគ្គលរូបនេះ ត្រូវបានបញ្ជូនទៅបឹងត្របែកនៅពេលដំបូង ហើយបន្ទាប់មកទៀតត្រូវបានបញ្ជូនទៅមន្ទីរស-២១។ តើលោកដឹងអំពីការចាប់ខ្លួនគាត់ដែរឬទេ?

**ឆ៖** បាទ អត់បានដឹងទេ។

**ស៖** បើតាមលោកនោះ តើលោក អៀង សារី ដឹងអំពីការចាប់ខ្លួននេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងគាត់យល់យ៉ាងណាដែរ។

**ស៖** តើលោកដឹងថាអ្នកណាមកចាប់លោក ចៅ សេង ដែរឬទេ?

[១៥:៤៥:០២]

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើមិនមែន ប៉ង់ ទេឬ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើមនុស្សដែលនៅក្រោមឱវាទក្រសួងការបរទេសធ្លាប់ចេញពីក្រសួងនេះ ដោយ អៀង សារី មិនត្រូវបានគេជូនដំណឹងទេឬ?

**ឆ៖** គឺមានពេលដែល ប៉ង់ មកយក ឬសំបុត្រប៉ង់ ដែលមកយកត្រូវតែបងអៀង សារី អត់ដឹង។

**ស៖** បសូមអរគុណ។ ការពិតនោះគឺថា ថៅ សេង នេះ ត្រូវបានគេចាប់ខ្លួននៅបឹងត្របែក ហើយបន្ទាប់មកបញ្ជូនទៅស-២១ ដោយដូរឈ្មោះគាត់ គឺឈ្មោះ-- គឺឈ្មោះ ចិន សួន តើលោកធ្លាប់ឮគេនិយាយពីឈ្មោះ ចិន សួន នេះទេ?

**ឆ៖** បាទ អត់ធ្លាប់ទេ។

**ស៖** យើង-- សំណួរ តើគេមិនដែលនិយាយអំពីបញ្ហាទាំងអស់នេះ នៅក្រសួងការបរទេសទេឬ?

[១៥:៤៧:៥៥]

**ឆ៖** បាទ អត់ទេ ស្វាត់ជ្រាប។

**ស៖** គាត់ជា-- នេះគឺអ្នកដែលទទួលមនុស្សសំខាន់នៅក្នុងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលទទួលបន្ទុកខាងកិច្ចក្រៅនៅអមនរោត្តម សីហនុ ហើយពេលដែលគាត់ត្រឡប់មកវិញហ្នឹង គឺអ្នកណាក៏ដឹងដែរ។ អ៊ីចឹង សំណួរដែលខ្ញុំចង់សួរថា តើលោករក្សាចម្លើយដែលថាលោកបានមិនដឹងឮអ្វីទាំងអស់មែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ជាដំបូង ត្រូវតែមានមូលដ្ឋានជាមុនសិន ថាតើយើងដឹងដែរឬទេ ថាមានការយកបុគ្គលនេះចេញទៅ? ប្រសិនបើសាក្សីដឹង ហើយអ្នកផ្សេងដឹងថាមានការយកទៅស-២១ ទើបយើងអាចសួរបាន។ យើងសួរសិន ថាសាក្សីដឹងមកពីណា? ហើយប្រសិនយកទៅ យកទៅនោះ នៅពេលណា? តើយើងឲ្យសាក្សីនិយាយដូចម្តេច បើសិនបើសាក្សីមិនដឹង។

[១៥:៤៩:២៥]

ដូច្នេះ មេធាវីត្រូវតែផ្តល់ បង្កើតជាមូលដ្ឋានជាមុនសិន ដើម្បីសួរទៅកាន់សាក្សី។ យើងដឹងហើយមានបុគ្គលម្នាក់ទៅពីកន្លែងមួយ ទៅកន្លែងមួយទៀត ហើយបន្ទាប់មកបាត់ខ្លួន។ ហើយៗយើងដឹងហើយថា យើងត្រូវតែសួរមានការ យើងត្រូវតែបង្កើតមូលដ្ឋានជាមុន ទើបយើងអាចសួរសំណួរបន្តដូច្នេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ការកត់សម្គាល់របស់លោកមេធាវី ម៉ៃខល កាណាវាស ត្រឹមត្រូវ។

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ គប្បីពិចារណាឡើងវិញលើការតាំងសំណួរមិនអាចប្រើពាក្យថា ថៅ សេង ត្រឡប់មកកម្ពុជាវិញ អ្នកណាក៏ដឹងដែរនោះទេ វាមិនប្រាកដទេ។ សូម្បីតែស្គាល់ឈ្មោះ ថៅ សេង ហ្នឹង មិនទាន់ប្រាកដថាអ្នកណាក៏ស្គាល់ឈ្មោះ ថៅ សេង នោះទេ។

[១៥:៥០:៤៣]

**លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា៖**

ខ្ញុំសូមយោងទៅកំណត់ហេតុស្ដាប់ចម្លើយថ្ងៃទី០៧ មេសា ឆ្នាំ២០១០ គឺ E346 ដែលនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ លោកសាក្សីត្រូវបានសួរចម្លើយ ហើយមានឈ្មោះលោក ថៅ សេង នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ។ គឺសំណួរចុងក្រោយគេនៃចម្លើយ។ សំណួរដូចតទៅនេះ គឺថានៅទំព័រចុងក្រោយគេបំផុត។ ចម្លើយរបស់គាត់គឺថា ចម្លើយ១១៤៖ សាក្សីម្នាក់បានបង្ហាញឈ្មោះអតីតការទូតដែលធ្លាប់នៅតម្រាំងចំរេះគឺមានឈ្មោះដូចជា លោក ថៅ សេង ជាដើម។ តើលោកដឹងថា តើបុគ្គលទាំងអស់នេះត្រូវបានបញ្ជូនទៅត្រាំងចំរេះដែរឬទេ? គាត់បានឆ្លើយថា "ខ្ញុំមិនដឹងអ្វីទាំងអស់។ ខ្ញុំដឹងតែបងរបស់លោក សារិន ឆាក ដែលគាត់តែងតែទៅត្រាំងចំរេះជាមួយ អៀង សារី គាត់មិនធ្វើការនៅទីនោះទេ គាត់មិនដែលបាននៅត្រាំងចំរេះនោះដែរ"។ ដូច្នេះ លោកសាក្សី លោកសាក្សីដឹងថាមានឈ្មោះ ថៅ សេង ដែរ យ៉ាងហោចណាស់ក៏នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរ។ គឺថានៅខែមេសា ឆ្នាំ២០១០។

[១៥:៥៣:២៤]

ខ្ញុំមិនមែននៅទីនេះ ដើម្បីបង្កើតជាជម្លោះស្លាបប៉ាកានោះទេ ក៏ប៉ុន្តែដើម្បីពិភាក្សាជាមួយសាក្សីនេះអំពីខ្សែជីវិតរបស់ជនរងគ្រោះ និងដើម្បីធ្វើការកត់សម្គាល់មួយចំនួនលើការចូលរួមនៃ-- របស់ដំណើរការនៃក្រសួងការបរទេស ហើយនិងស្ថាប័ននៅក្រោមឱវាទក្រសួងនេះ។ ហើយដោយសារតាមរយៈសាក្សីនេះហើយ ដែលអាចធ្វើឲ្យយើងអាចមើលឃើញការពិតដោយផ្នែក។

ហើយខ្ញុំសូមឈានចូលទៅនិយាយអំពីឥស្សរជនម្នាក់ទៀត គឺលោក១ ភឹង គុន ដែលជាសាស្ត្រាចារ្យមហាបរិញ្ញាផ្នែកច្បាប់ ហើយខ្ញុំក៏មានរូបថតគាត់មួយដែរ។ ខ្ញុំគិតថាជាការសំខាន់ណាស់គឺថាបុគ្គលទាំងអស់នេះមនុស្សទាំងអស់នេះគឺថា គាត់ជាមនុស្សដែលគេទទួលស្គាល់ គាត់មានសមត្ថ-

ភាព គាត់ជាមនុស្សក្នុងចំណោមមនុស្សឆ្នើមនៅប្រទេសកម្ពុជា។ ដូច្នេះយើងត្រូវតែបង្ហាញរូបថតគាត់ឲ្យគេឃើញតាមរយៈទូរទស្សន៍ជាដើម។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីសំណាក់អង្គជំនុំជម្រះ ដើម្បីបង្ហាញរូបថតគាត់គឺ D289.1--។

[១៥:៥៤:៥0]

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យគាត់ឲ្យលេខឯកសារម្តងទៀត ព្រោះអីខ្ញុំតាមអត់ទាន់អម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីឲ្យលោកឯកសាររូបថត ភឹង គុន សាជាថ្មីម្តងទៀត! អ្នកបកប្រែស្តាប់លោកស្រីនិយាយអត់ទាន់ទេ មិនអាចបកប្រែបានទេ។

**លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា៖**

លេខឯកសារ គឺ D288-6.17.3។ លេខកូដ P00384759 ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតនេះទៅសាក្សីលោកប្រធាន។

ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតនេះទៅសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកជូនសាក្សីពិនិត្យ!

[១៥:៥៧:១៤]

**សួរដោយលោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា៖**

**ស៖** លោកសាក្សីតើលោកស្គាល់ឈ្មោះគាត់ដែរឬទេ? ឈ្មោះរូបដែលមានគូសក្រហមជុំវិញនេះ ការេក្រហមជុំវិញ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

**ស៖** គឺជាសាស្ត្រាចារ្យច្បាប់មហាបរិញ្ញា ដែលគាត់ អង្គាល់ណោះគាត់បានបង្រៀននៅក្នុងមហាវិទ្យាល័យបារាំងមួយចំនួន ហើយគាត់ជាអ្នកជំនាញផ្នែកកងទ័ពសមុទ្រ អ៎! ជើងទឹកនៅក្រសួងការបរទេស នៅក្នុងដើមទសវត្សរ៍ឆ្នាំ៧៥ នៅពេលដែលមានបញ្ហាកោះពូលូវៃ ដែលវាជាជម្លោះព្រំប្រទល់រវាងប្រទេសវៀតណាម ហើយនិងប្រទេសកម្ពុជា។ ហើយគាត់បានត្រឡប់មកប្រទេសខ្លួន

វិញនៅឆ្នាំ១៩៧៥--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាង អ៎! លោកមេធាវីការពារក្តីលោក អៀង សារី!

[១៥:៥៨:៥៣]

**លោក ម៉ៃខល កាណាវាស៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមទោសដែលខ្ញុំស្កាត់នៅត្រង់នេះ។ យើងដឹងថា ជិតដល់ម៉ោងហើយ ហើយមេធាវីនោះគាត់ចង់សួរឲ្យបានច្រើន។ ក៏ប៉ុន្តែការសួរដូចដែលធ្វើឡើងនេះ គឺការផ្តល់ចម្លើយដូចដែលសាក្សីបានលើកឡើងនេះ អ្វីដែលមេធាវីសួរគឺមិនត្រូវ ត្រឹមត្រូវទៅតាមកិច្ចដំណើរការនីតិវិធីនោះទេ។ គឺយើងដឹងហើយថា បុគ្គលរូបនេះធ្វើការនៅក្រសួងការបរទេសមុនឆ្នាំ១៩៧៥ វាអាចមិនមានភាពពាក់ព័ន្ធនៅក្នុងការសួរសំណួរនេះទេ។ ហើយវាមិនស្ថិតនៅក្នុងហេតុផលដែលយើងត្រូវសួរពាក់ព័ន្ធទៅនឹងអង្គហេតុនេះទេ។ យើងដឹងហើយថា យើងមិនចង់ឲ្យមានការពន្យារពេលនោះទេ ហើយយើងក៏មិនចង់ឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបាត់បង់សិទ្ធិរបស់គាត់នោះដែរ។ យើងមិនចង់ឲ្យមានការសក្ខីកម្មវែងនោះទេ។ សូមអរគុណ។

[១៥:៥៩:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រីមេធាវីតើមានសំណួរអីផ្សេងទៀតទេ? លោកស្រីអាចមានមួយសំណួរឬពីរសំណួរទៀត ឥឡូវអស់ម៉ោងហើយ។

បញ្ហានេះលោកស្រីអាចទៅសួរគេ-- សួរសាក្សីបាន មិនឲ្យលោកស្រីយកមករូបថតបង្ហាញហើយលោកស្រីមករៀបរាប់ ធ្វើអត្ថាធិប្បាយអំពីជីវប្រវត្តិហ្នឹងទេ។ នីតិវិធីដែលយើងធ្វើនេះ គឺយើងកំណត់សួរដេញដោលសាក្សីអំពីបញ្ហា អំពីព្រឹត្តិហេតុ ហេតុការណ៍ពាក់ព័ន្ធនឹងបទចោទប្រកាន់ ដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ហើយអង្គជំនុំជម្រះបានកំណត់បំបែកសំណុំរឿងមកធ្វើសវនាការសំណុំរឿង០០២/០១។

[១៦:០០:៥០]

**លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំមិនយល់-- ខ្ញុំអត់បានឮចម្លើយខាងភាគីការពារក្តីនោះទេ ព្រោះថាខ្ញុំមានបញ្ហាប្រដាប់ស្តាប់ខ្ញុំ

នេះ ស្តាប់មិនឮ។

**សួរដោយលោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា៖**

**ស៖** ខ្ញុំមានសំណួរ។ សំណួរខ្ញុំដូចតទៅ៖ បុគ្គលរូបនេះត្រូវបានគេបញ្ជូនទៅបឹងត្របែក។ យើងមានជីវប្រវត្តិរបស់គាត់។ សំណួរខ្ញុំទាក់ទងទៅនឹងប-១។ តើអ្នកជាអ្នកបញ្ជាដើម្បីឱ្យអ្នកដែលនៅប-១ នោះសរសេរប្រវត្តិរូបរបស់ខ្លួន?

[១៦:០១:៤៧]

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំមិនស្គាល់ឈ្មោះ ហើយខ្ញុំក៏មិនដឹងនរណាដែលសរសេរប្រវត្តិរូបដែរ។

**ស៖** ឯកសារ D22/10.6 ខ្ញុំផ្តល់លេខឯកសារ ហើយខ្ញុំនឹងពន្យល់ដល់អង្គជំនុំជម្រះអំពីការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងឯកសារ D22/10.6 លេខ ERN គឺជាភាសាខ្មែរ និងភាសាបារាំង ភាសាអង់គ្លេស។ ឯកសារនេះ គឺជាឯកសារដែលមាននៅក្នុងសំណុំរឿង ហើយដែលភាគីការពារក្តីជាអ្នកស្នើ។ ឯកសារនេះមិនទាន់បានបង្ហាញជូនដល់សាក្សីទេ ដោយសារសាក្សី-- ដោយសារដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ឯកសារក្នុងដំណាក់កាលស៊ើបអង្កេត ហើយនិងក្នុង-- ហើយឯកសាររបស់-- ដែលគាត់ដាក់នោះ ដើមបណ្តឹងរដ្ឋប្បវេណីដាក់នោះ មិនមានសាក្សីណាបានមើលទេ ព្រោះថាមិនទាន់មានការប្រឈមមុខនៅឡើយ តទល់គ្នានៅឡើយ។

[១៦:០៣:២៥]

ដូច្នេះ នៅរាល់ពេលដែលមានសាក្សីមកបង្ហាញខ្លួននៅទីនេះ ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិន-- សាក្សីនឹងមិនស្គាល់ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ អ៊ីចឹងថាសួរថាតើឱ្យនិយាយអំពីសំណុំឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េច? ក្នុងខណៈដែលឯកសារទាំងអស់នេះមានក៏-- ក្នុងលក្ខខណ្ឌដែលថាត្រូវ-- ឯកសារទាំងអស់នេះត្រូវទទួលហើយនោះ ហើយបើយើងមិនយកបង្ហាញនៅក្នុងអង្គជំនុំជម្រះនេះទេ គឺថាគ្មានសាក្សីណានឹងស្គាល់ឯកសាររបស់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណីនេះនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

[១៦:០៤:១៨]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ជាបឋម ការសួរសំណួរទៅកាន់សាក្សី អំពីសាក្សី ដែលធ្វើឲ្យសាក្សីមិនអាចឆ្លើយបាននោះ ហើយការបង្ហាញឯកសារក៏មិនអាចជួយឲ្យសាក្សីចងចាំឡើងវិញនោះដែរ។ វាមិនមែនជាការជួយទៅដល់សាក្សីនោះទេ។ ដំណើរការនេះធ្វើដូច្នេះ នឹងវាធ្វើឲ្យយើងចំណាយពេលវែង។ សំណួរគួរតែសួរទៅកាន់សាក្សី ចំពោះអង្គហេតុណាសំខាន់។ យើងមិនអាចធ្វើការយករឿងក្តីអង្គហេតុទាំងអស់ ដែលវែងមកឲ្យសាក្សីនេះឆ្លើយនោះទេ។ សាក្សីរូបនេះមានសមត្ថភាពឆ្លើយនៅក្នុងចម្លើយជាក់លាក់។ ហើយប្រសិនបើមានកំណត់ហេតុដែលបានឆ្លើយយ៉ាងណាថា ស្គាល់បុគ្គលនេះឬនោះៗ គឺថាយើងអាចសួរបាន។ សាក្សីនេះបានបញ្ជាក់រួចហើយ ដូចដែលគាត់បានលើកឡើង។

[១៦:០៥:១៧]

យើងមានវិធីក្នុងការសួរទៅកាន់សាក្សីនៅពេល-- តាមរយៈការបង្ហាញចម្លើយមុនៗ។ ក៏ប៉ុន្តែនៅពេលដែលមេធាវីលើកឡើងថា គាត់ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យមានការបង្ហាញភស្តុតាងឲ្យច្រើននោះ ហើយយកឯកសារមកបង្ហាញដូច្នេះ គឺមិនមែនការល្អនោះទេ។ យើងដឹងថាមានសាក្សីជាច្រើនទៀត ដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះ ហើយខ្ញុំដឹងថាមានសាក្សីដទៃទៀត ដែលយើងអាចបង្ហាញឯកសារនេះជូនពួកគាត់បាន។ អង្គជំនុំជម្រះនៅទីនេះចង់ឲ្យមានការជំនុំជម្រះឲ្យបានលឿនតាមដែលធ្វើទៅបាន ហើយនិងអនុញ្ញាតឲ្យប្រើប្រាស់ឯកសារមួយចំនួនទោះបីជាឯកសារទាំងអស់បានទទួលយកនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡនេះក៏ដោយ។

[១៦:០៦:០៧]

ខ្ញុំយល់ថា មិនមានផលប្រយោជន៍ចំណេញពីការបង្ហាញឯកសារនេះនោះទេ។ ម៉ោងបួនរួចទៅហើយ។ ហើយយើងដឹងហើយថាសាក្សីបានឆ្លើយហើយ ឯកសារនោះគាត់មិនដែលធ្លាប់ឃើញ។ ដូច្នេះមិនចាំបាច់ឲ្យមានការពន្យល់ពីសាក្សី ហើយមិនចាំបាច់ធ្វើការពន្យល់ហេតុផលក្នុងការបង្ហាញឯកសារភស្តុតាងនោះទេ។ ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំជំទាស់នៅត្រង់ចំណុចនេះ ក៏ប៉ុន្តែយើងត្រូវតែមានលក្ខណៈជាក់ច្បាស់ចំពោះកិច្ចដំណើរការនីតិវិធីរបស់យើង។

**លោកស្រី អេលីហ្សាបេត វ៉ាបេសាន់ដ្រាតាណា៖**

លោកប្រធានខ្ញុំសូមឆ្លើយតបទៅនឹងភាគីការពារក្តីលោក អៀង សារី។

នេះមិនមែនជាការចោទសំណួរទៅសាក្សីពាក់ព័ន្ធនឹងអ្វីដែលគាត់មិនដឹងនោះទេ។ យើងបាន

ពិភាក្សាមួយសប្តាហ៍ពេញហើយ លើបញ្ហាប្រវត្តិរូប ពីព្រោះថាគាត់បានពន្យល់ថា តួនាទីរបស់គាត់គឺជាតួនាទីខាងអប់រំ។ ហើយគាត់ក៏បាននិយាយផងដែរអំពីប្រវត្តិរូបស្អាតស្អំ។ ដូច្នេះ អ្វីដែលខ្ញុំចង់និយាយនោះគឺថា ចង់និយាយនោះគឺថាដើមបណ្តឹងរដ្ឋប្បវេណី អាចឲ្យយើងមើលឃើញតថភាពជាលក្ខណៈរបស់មនុស្សតាមរយៈភស្តុតាង តាមរបាយការណ៍ ដែលបានធ្វើឡើងកាលពីសម័យនោះ។

[១៦:០៧:៣១]

សព្វថ្ងៃនេះគឺថាអ្វីដែលយើងនិយាយឥឡូវនេះ អ្វីដែលខ្ញុំនិយាយគឺថាវាមិនចាកប្រធានទេ គឺវាឯកសារទាំងអស់នេះធ្វើនៅបឹងត្របែក។ ក៏ប៉ុន្តែ ខ្ញុំមិនយល់ថា ខ្ញុំមិនអាចនិយាយអំពីបញ្ហានេះបានភស្តុតាងនេះបាន ព្រោះសាក្សីគាត់ថាគាត់មិនស្គាល់ឯកសារនេះ ក៏ប៉ុន្តែការពិតគឺថាអ្វីដែលនិយាយនេះគឺថាមិនចង់ឲ្យសាក្សីនិយាយព្រាវៗនោះទេនៅថ្ងៃស្អែក ឬខានស្អែកទៀត នឹងមានប្រធានបទផ្សេងទៀតហើយខ្ញុំមិនជឿថា ឬក៏ខ្ញុំមិនចង់បង្ហាញឯកសារនេះថាដាច់ខាតនោះទេ ខ្ញុំគ្រាន់តែចង់បង្ហាញថាពីការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីភាពជូរចត់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដែលថា ព្រោះថាមានព័ត៌មានទាក់ទងនឹងជនរងគ្រោះ។

[១៦:០៨:២៥]

**ប្រធានអង្គជំនុំ៖**

លោកស្រីអាចសង្ខេបខ្លីជាងនេះបានទេ ម៉ោងដូចជាលើស១០នាទីហើយ។

លោកស្រីអាចត្រូវការប៉ុន្មាននាទីទៀតក្នុងការនិយាយនេះ? ត្រូវការប៉ុន្មាននាទីទៀត? ពេលវេលាលើសប្រាំបីនាទីហើយ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីបេសាន់ជ្រាតាណា៖**

**ស៖** សាក្សីបានឆ្លើយមកសំណួរខ្ញុំ ចង់ដឹង ដែលសំណួរចង់-- សុំឲ្យគាត់ឆ្លើយថាតើអំមិញនេះថាតើអ្នកណាគេបញ្ជាឲ្យធ្វើប្រវត្តិរូប? ហើយខ្ញុំនឹងបញ្ចប់ត្រង់នេះ ហើយខ្ញុំនឹងចូលបុគ្គលមួយរូបទៀត។ និយាយអំពីបុគ្គលមួយរូបទៀត គឺលោក រស់ សារិន ហើយនិងភរិយារបស់គាត់ ដែលឈ្មោះ រស់ ស្អីគេ ស្រុះស៊ី-- តើលោកស្គាល់ឈ្មោះនុ៎ងដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

**ស៖** លោកស្រី ស្រុះស៊ី និងកូនទាំងពីររបស់គាត់ ត្រូវបានបញ្ជូនទៅបឹងត្របែក។ តើលោក

អត់ស្គាល់--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំស្តាប់ឈ្មោះអត់បានទេលោកប្រធាន។ សូមឱ្យគាត់និយាយឈ្មោះឡើងវិញ។ លោកមេធាវីខ្មែរ លោកប្រធាន មេធាវីជួយអានឈ្មោះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីខ្មែរអានមើល៍ ឈ្មោះអីគេ ឈ្មោះលោកស្រីអីគេ?

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ លោកដែលលោកស្រីមេធាវីលើកនេះឈ្មោះ រស់ សារិន ហើយប្រពន្ធរបស់គាត់ រស់ ឈួស៊ីអ៊ី។

**ប្រធានអង្គជំនុំ៖**

សាក្សីស្គាល់ទេ? ស្គាល់ឈ្មោះ រស់ សារិន ហើយនិងប្រពន្ធរបស់គាត់ឈ្មោះ រស់ ឈួស៊ីអ៊ី ដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ អត់ស្គាល់ទេ។

[១៦:១១:៥៤]

**សួរដោយលោកស្រី អេលីហ្សាបេត រ៉ាបេសាន់ជ្រាតាណា៖**

**ស៖** បុគ្គលរូបនេះត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរស-២១ ក្នុងពេលដំណាលគ្នាជាមួយនឹងលោក ភឹង គុន។ បន្ទាប់មក ក៏មានការបាត់ខ្លួន តើលោកមិនដឹងអំពីការបាត់ខ្លួនរបស់លោក រស់ សារិន នេះទេ មែនទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

**ស៖** នៅក្រសួងការបរទេស តើមានបញ្ជីមនុស្សដែលត្រូវបញ្ជូនបន្តដែរឬទេ លោកធ្លាប់មានបញ្ជីនេះទេ?

**ឆ៖** បាទ អត់ធ្លាប់មានទេ។

**ស៖** តើលោកដឹងយ៉ាងម៉េចបាន អំពីការផ្ទេរ ផ្លាស់ ឬក៏ផ្លាស់ប្តូរភារកិច្ចក្នុងករណីដែលថាលោកនិយាយថា អត់ដឹងអម្បាញ់មិញនេះ?

**ធ៖** ខ្ញុំអត់សួរយល់សំណួរ។

**ស៖** បុគ្គលនេះត្រូវបានមកដល់ព្រលានយន្តហោះ បន្ទាប់មកទៀត គេបញ្ជូនទៅមន្ទីរប-១ ហើយក្រោយមកក៏ត្រូវផ្ទេរឲ្យទៅរៀនសូត្រ ឬក៏អប់រំ ឬក៏កសាងខ្លួននៅតាមជំរំ ហើយបន្ទាប់មកក៏បាត់ខ្លួន។ ប្រសិនបើលោកមិនទទួលបានបញ្ជីឈ្មោះទេ តើលោកធ្វើការផ្ទេរភារកិច្ចអីយ៉ាងម៉េចកើតទៅ? អ៊ីចឹងតើលោកបញ្ជូនមនុស្សទាំងអស់នោះទៅយ៉ាងម៉េច បើលោកអត់មានបញ្ជីនោះ?

[១៦:១៤:៤៦]

**ធ៖** ខ្ញុំអត់សួរយល់សំណួរនេះទេ ប៉ុន្តែខ្ញុំប្រឹងឆ្លើយបាទ គឺថាខ្ញុំអត់មានទទួលភារកិច្ចទៅផ្លាស់ប្តូរអីទេ។ បើនិយាយពីរឿងរាវរកក្រុមគ្រួសារហ្នឹង គឺថាអារម្មណ៍ខ្ញុំ ខ្ញុំគិតថាគាត់រាវរកគ្រួសារហ្នឹង ដើម្បីឲ្យឃើញតាមសំណូមពររបស់បងប្អូន។ ឯចំពោះខ្ញុំវិញនេះ គ្រួសារក៏បាត់ដែរ បងប្អូនក៏បាត់ដែរ ខ្ញុំរាវរកក៏មិនឃើញដែរ ទៅឲ្យខ្ញុំទៅរាវរកគ្រួសារពីឯណាទៀតទៅដឹង។ ដូច្នេះ ខ្ញុំពិបាកឆ្លើយណាស់ដែរបាទ។

**ប្រធានអង្គជំនុំ៖**

លោកស្រីអស់ពេលវេលាហើយ លើសដប់ប្រាំនាទីហើយ។ អរគុណសាក្សី។

ឥឡូវនេះ ពេលវេលាឃើញថាលើសម៉ោងដប់ប្រាំនាទីហើយ ដប់ប្រាំទៅម្ភៃនាទីហើយ។ ដូច្នេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ សមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តនៅថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនព្រឹក ហើយសាក្សី ហើយនិងលោកមេធាវី ដោយបញ្ហានូវមិនទាន់ចប់នៅឡើយទេ ហើយទំនងជាស្អែកមួយថ្ងៃទៀត យើងនឹងអាចប៉ាន់ស្មានបានហើយ ថាតើពេលវេលានុ៎ង ត្រូវបន្តយ៉ាងដូចម្តេច?

[១៦:១៦:៣០]

អ៊ីចឹង គឺអង្គជំនុំជម្រះសូមអញ្ជើញសាក្សីមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកជាបន្តទៀត ដោយសូមទាំងអញ្ជើញទាំងមេធាវីប្រឹក្សាផង ដើម្បីមកអមក្នុងរយៈពេលនៃសាក្សីផ្តល់ចម្លើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីផ្តល់មធ្យោបាយទៅមក ហើយនិងព្រឹកស្អែក សម្រួល និងអញ្ជើញគាត់មកដល់កន្លែងផ្តល់សក្ខីកម្មនេះនៅម៉ោងប្រាំបួនព្រឹក។ ហើយជម្រាបដល់ភាគីផងដែរថា ថ្ងៃស្អែកនេះ គឺព្រលឹមឡើងយើងនឹងបន្តដោយការតាំងសំណួរមួយចំនួន ដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងចំពោះសាក្សី ប្រសិនបើមាន។

ហើយជាបន្ទាប់ទៅទៀត អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ជាមុន ដោយបញ្ហានៃភាពពាក់ព័ន្ធ យើងឃើញថា ហើយមេធាវីក៏បានឯកភាពគ្នាពីម្សិលមិញដែរ គួរផ្តល់ពេលវេលានេះទៅឲ្យក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការតាំងសំណួរដេញដោលសាក្សីនេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចដូច្នេះ វាអាចខុសពីអ្វីដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងអនុស្សរណៈ អំពីវិធីសាស្ត្រក្នុងការការកំណត់កាលបរិច្ឆេទ និងពេលវេលាសម្រាប់សួរដេញដោលនៅគោលការណ៍ គឺយើងថាអ្នកណា ភាគីណាជាអ្នកស្នើសុំ គឺភាគីនោះ ជាអ្នកតាំងសំណួរមុន ប៉ុន្តែករណីនេះ គឺករណីមានលក្ខណៈដោយឡែក។ ដូច្នេះយើង អង្គជំនុំជម្រះឯកភាពគ្នាសម្រេចដូច្នេះ។

[១៦:១៨:០៧]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៨ នាទី)*